The villagers were wrong to see the site selection as magic; they were right to see it as a sacramental moment. They may be superstitious, but they haven't forgotten that the supernatural surrounds and indwells our activities all the time.

But this story has another side—a more disturbing darker one. If many of the operational elements of well digging are potentially sacramental moments, then what message do we send to our village friends when we fail to act as if this were true? When we treat the site selection as a simple matter of technical skill, we are doing one of two

things, both of them bad. If we are insensitive to how the village folk may interpret the activity, and make no explanation, we are reinforcing their pre-scientific worldview. Christian technical folk appear to be doing magic.

If we are wise enough to understand how they might interpret site selection, but provide the wrong explanation (the activity is merely a technical activity having nothing to do with magic or the supernatural), we are secularizing their worldview. In fact, we are passing on our own cultural blind spot.

Whether we overlook their interpretation to explain the activity as science, the message is a secular one: God and the supernatural are not present here.



# ការអភិវឌ្ឍន៍ របស់អង្គការគ្រិស្តបរិស័ទ នៅក្នុងប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា

*លោក គ្លេន មៀលល័រ*

## សេចក្តីផ្តើម

មានអង្គការអន្តរជាតិក្រៅរដ្ឋាភិបាល (INGOs) ជាង២០០អង្គការ ជាមួយគ្នានោះ ប្រហែលជា ២០០០នាក់ ដែលជាជនបរទេស សព្វថ្ងៃនេះ រស់នៅ ហើយធ្វើការនៅក្នុងប្រទេសកម្ពុជា ។ តាមរយៈមធ្យោបាយជាច្រើន ដែលអង្គការ និងមនុស្សទាំងអស់ ខំប្រឹងប្រែងធ្វើឲ្យជីវិតប្រជាជនកម្ពុជាមានភាពប្រសើរឡើង ក្រោយពីការបំផ្លិចបំផ្លាញជីវិតមនុស្សអស់យ៉ាងច្រើនក្នុងរបបប៉ុលពតប្រល័យពូជសាសន៍ ។ ការយល់ដឹងពីប្រពៃណីក្នុងស្រុក គឺជាសារៈសំខាន់សំរាប់កិច្ចការអភិវឌ្ឍន៍របស់អង្គការក្រៅរដ្ឋាភិបាលទាំងនេះ ។

ដើម្បីយល់ដឹងពីប្រពៃណីកម្ពុជា តំរូវឲ្យមានការយល់ដឹងអំពីជំនឿព្រះពុទ្ធសាសនា និងតួនាទីរបស់សាសនានៅក្នុងសង្គមនេះជាមុនសិន ។ សម្តេចព្រះនរោត្តម សីហនុ បានចង្អុលបង្ហាញពីសារៈសំខាន់នៃជំនឿព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា ព្រះអង្គមានបន្ទូលនៅក្នុងឆ្នាំ ១៩៧០

ថា "ប្រទេសកម្ពុជា ប្រៀបបានទៅនឹងរទេះដែលទ្រទ្រង់ដោយកង់ពីរ ។ កង់ទីមួយគឺ រាជរដ្ឋាភិបាល ហើយកង់មួយទៀតគឺ ព្រះពុទ្ធសាសនា ។ ខាងមុខជានិមិត្តសញ្ញានៃអំណាច ខាងក្រោយជានិមិត្តសញ្ញានៃសីលធម៌សាសនា ។ កង់ទាំងពីរនេះត្រូវតែវិលក្នុងល្បឿនដូចគ្នាដើម្បីទ្រទ្រង់រទេះ ។ ឧទាហរណ៍ ប្រទេសកម្ពុជាចង់អភិវឌ្ឍទៅមុខដោយភាពសុខស្រួលក្នុងផ្លូវសន្តិភាព និងវឌ្ឍនភាព" ។[១]

## កម្លាំងអភិវឌ្ឍន៍គ្រីស្ទបរិស័ទក្នុងប្រទេសផ្សេងៗដែលគ្មានការអភិវឌ្ឍន៍

ក្នុងពេលប្រជុំបំប៉នស្មារតីថ្មីៗនេះរបស់បុគ្គលិក អឹមស៊ីស៊ី (MCC) ខ្ញុំបានសួរបុគ្គលិកស្ម័គ្រចិត្ត អឹមស៊ីស៊ី ឲ្យប្រៀបធៀបពីអ្វីដែលប្រជាជនកម្ពុជាបានវាយតម្លៃពួកគេ ទៅនឹងអ្វីដែលពួកគេចង់ឲ្យប្រជាជនកម្ពុជាវាយតម្លៃ ។ ចម្លើយដ៏សាមញ្ញបំផុតនោះគឺ ពួកគេចង់ឲ្យអ្នកដទៃមើលមកខ្លួនថា ជាមនុស្សម្នាក់ដែលមានកិត្យានុភាព និងអំណាច ឬជាមនុស្សម្នាក់ដែលមានជំនាញបច្ចេកទេសច្បាស់លាស់ ។ តែផ្ទុយទៅវិញ ចម្លើយរបស់បុគ្គលិកស្ម័គ្រចិត្តជាច្រើនបែរជាចង់ឲ្យអ្នកដទៃមើលឃើញថា ពួកគេកំពុងតែបំរើដើម្បីបង្ហាញពីព្រះគ្រីស្ទ ឬជាគ្រីស្ទបរិស័ទដែលមានចិត្តអាណិតអាសូរម្នាក់ទៅវិញ ។ វាមានភាពខុសគ្នាដាច់ស្រឡះរវាង អំណាច កិត្យានុភាព និងអ្នកជំនាញការ ហើយនិងការដែលយើងចង់ឲ្យគេវាយតម្លៃ ក្នុងនាមយើងជាគ្រីស្ទបរិស័ទ ។

បុគ្គលិកស្ម័គ្រចិត្ត អឹមស៊ីស៊ី និងបុគ្គលិកអង្គការអភិវឌ្ឍន៍មកពីបស្ចិមប្រទេស ជាទូទៅចេញមកពីប្រទេសជឿនលឿន និងបច្ចេកវិជ្ជាឈានមុខ ។ គេឃើញខ្លួនគេដូចជាមនុស្សដែលត្រូវបានភ្លឺដោយប្រព័ន្ធនៃ "សេចក្តី

---

[១] *ហែនរិច ឌុមូលីន និង ចន ស៊ី ម៉ារ៉ាលដូ, ព្រះពុទ្ធសាសនានៅក្នុងសម័យពិភពលោកទំនើប (ទីក្រុងឡុងដ៍: ខូលៀ ម៉ាកមីលៀន, ១៩៧០) ។*

ពិត" នានាដែលនៅពីក្រោយ ពួកគេអួតពីសមត្ថភាពរបស់ខ្លួនគេដើម្បីឲ្យគិតអំពីទិសដៅ និងការធ្វើចលនាចេញពីគំរោងផែនការដើម្បីសំរេចគោលដៅ ។ ឧបសគ្គដល់ការឈោងចាប់ទិសដៅដែលចង់បាន គឺមើលឃើញទុកដូចជាការខិតខំដើម្បីឈ្នះដោយមានការរួមបញ្ចូលរវាងការជំរុញ និងពត៌មានត្រឹមត្រូវ ។ ក្នុងពេលជាមួយគ្នា បុគ្គលិកអភិវឌ្ឍន៍គ្រីស្តបរិស័ទមកពីបស្ចិមប្រទេសមើលឃើញខ្លួនគេ ថាជាអ្នកដែលដើរតាមព្រះយេស៊ូគ្រីស្តដ៏មានចិត្តអាណិតអាសូរម្នាក់ ។

ចំពោះអ្នកបស្ចិមប្រទេស "ការអភិវឌ្ឍន៍" មានន័យថា ភាពទំនើបវិទ្យាសាស្ត្រអប់រំ ផ្តត់គំនិតដែលមានហេតុផល ចលនាចេញពីភាពដែលគិតតែពីខ្លួនឯងទៅដល់ការគិតពីគ្នាទៅវិញទៅមក ពីអបិយជំនឿទៅដល់សេចក្តីពិត ។ គោលដៅ គឺជាភាពគ្រប់គ្រាន់ខ្លួនឯង ការសង្កេតយល់ដឹងខ្លួនឯង និងភាពឯករាជ្យ ដើម្បីរំដោះប្រជាជាតិឲ្យរួចផុតពីជំនឿលើព្រេងវាសនា និងទំនៀមទំលាប់ដ៏ងងឹតងងល់ដែលគ្របដណ្តប់លើការរីកចំរើន ។ ដើម្បីរំដោះឲ្យមានសេរីភាព ហើយដោយព្រោះយើងជាប្រភពធនធានខាងថវិកា ពួកយើងមានអារម្មណ៍ថា យើងមានសិទ្ធិក្នុងការបង្កើតច្បាប់ និងពិនិត្យសង្កេតនូវលទ្ធផល ។

ចំពោះប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍ អង្គការអន្តរជាតិក្រៅរដ្ឋាភិបាលលេចធ្លោឡើងដូចជាមានអំណាចខ្ពស់ខាងបច្ចេកវិជ្ជា និងថវិកាដែលគ្មានព្រំដែន ។ ដោយសារថវិកា និងបច្ចេកវិជ្ជាទាំងនេះហើយ ទើបបង្កើតឲ្យមានកិត្យានុភាព និងអំណាចដ៏អស្ចារ្យ ។ នៅក្នុងហេតុការណ៍នេះ ប្រជាជនក្នុងស្រុកប្រហែលជាយល់ព្រម និងអនុញ្ញាតឲ្យអ្នកបស្ចិមប្រទេសកំណត់បញ្ហា បង្ហាញពីដំណោះស្រាយ ហើយនិងអនុវត្តនូវការកែច្នៃ ។ លទ្ធផលដូចដែលបានកំណត់ដោយអ្នកផ្តល់អំណោយមកពីបស្ចិមប្រទេសប្រហែលជាបានកំណត់ឲ្យប្រទេសកំពុងអភិវឌ្ឍ ធ្វើការទៅមុខឆ្ពោះទៅដល់

សង្គមមួយដែលសមស្របទៅនឹងប្រទេសផ្តល់អំណោយ ។ ការហ្វឹកហ្វឺន ផ្តល់មកឲ្យ ដើម្បីបំពាក់បំប៉នកម្លាំងដល់មនុស្សនៅក្នុងប្រទេសកំពុងអភិវឌ្ឍ គឺប្រហែលជាឧត្តមគតិក្នុងការរៀបចំពួកគេសំរាប់គោលដៅនៃសង្គមបស្ចិម ប្រទេស ប៉ុន្តែប្រហែលជាអាចបង្កើតសេចក្តីសង្ឃឹមមិនពិត និងភាពទ្រទ្រង់ មិនបាន ។ នៅក្នុងហេតុការណ៍នេះ ទោះបីជាមានការអាណិតអាសូរ ឬការ ដាក់ខ្លួនស្របទៅនឹងការផ្លាស់ប្តូរយ៉ាងណាក៏ដោយ ពួកគេត្រូវតែមើលទៅ ដូចជា "អ្នកឧបត្ថម្ភ" ឬជាភ្ញៀវ ។ ការនេះបង្កើតឡើងជាទំនាក់ទំនងមួយរវាង អ្នកឧបត្ថម្ភ និងអ្នកទទួលមរតក អ្នកផ្តល់អំណោយ និងអ្នកទទួល អ្នកមាន អំណាចខ្ពស់ និងអ្នកមានអំណាចទាប ឬចៅហ្វាយ និងអ្នកបំរើ ។ នៅក្នុង ហេតុការណ៍នេះ អ្នកដែលទទួលនឹងធ្វើចលនាឆ្ពោះទៅរកភាពឯករាជ្យ ។ ដូចដែលបានកើតឡើងដូច្នេះ ភាពរស់រវើកដែលមានតាំងតែពីកំណើតមក និងប្រភពធនធានដ៏ពេញបរិបូរណ៍នឹងត្រូវបានកាត់បន្ថយ ឬបាត់បង់ ។

ក្នុងការបន្ថែមទៅនឹងបញ្ហាបស្ចិមប្រទេស និងបូព៌ាប្រទេស ការ ប្រាស្រ័យទាក់ទងដ៏សាមញ្ញមួយ គឺជាការចាំបាច់ ។ ទោះបីជាអ្នកបស្ចិម ប្រទេស និងមនុស្សនៅក្នុងប្រទេសកំពុងអភិវឌ្ឍ អាចនិយាយភាសាដូចគ្នា យ៉ាងស្ទាត់ជំនាញក៏ដោយ ក៏កង្វះខាតក្នុងការយល់ដឹងមួយចំនួនធំនៅតែ កើតមានជាដរាប ។ សូមឲ្យយើងពិចារណាយោងទៅតាមឧទាហរណ៍ទាំង នេះដែលចេញពីស្ថានភាពរបស់ប្រទេសកម្ពុជា ។

"សហគមន៍" នៅក្នុងឧត្តមគតិលោកខាងលិច បង្កើតឲ្យមានរូបភាព មួយនៃក្រុមមនុស្ស ដែលរស់នៅជាមួយគ្នាដោយចុះសំរុងប្រកបដោយ សន្តិភាព និងយុត្តិធម៌ ក្នុងការទំនាក់ទំនង ។ ទោះជាយ៉ាងណាក៏ដោយ ក្រោយពីសម័យប៉ុលពត សហគមន៍នៅក្នុងប្រទេសកម្ពុជាមានគំនិតដែល មានពាក្យបង្កប់ន័យនៃក្រុមមនុស្សរស់នៅជាមួយគ្នា ដែលគ្មានគិតពីការធ្វើ ការប្រាស្រ័យទាក់ទងយ៉ាងជិតស្និទ្ធរវាងមនុស្សដូចគ្នា ប៉ុន្តែបង្កើតឡើង

សំរាប់ផលប្រយោជន៍នៃរដ្ឋ និងគោលបំណងនានារបស់រដ្ឋតែប៉ុណ្ណោះ។ នៅក្នុងបរិបទនេះ "សហគមន៍" បំពាក់បំប៉នអារម្មណ៍នៃការបង្ខិតបង្ខំ និងការគាបសង្កត់ ។

"សន្តិភាព" នៅក្នុងប្រពៃណីនៃសង្គមគ្រីស្តបរិស័ទតែងតែគិតអំពីន័យពាក្យសង្គម និង សេចក្តីពន្យល់ពីកង្វះនៃជម្លោះរវាងមនុស្ស និងមនុស្ស និងក្នុងចំណោមមនុស្ស ។ ក្នុងមធ្យោបាយមួយទៀត ពេលដែលព្រះពុទ្ធមានពុទ្ធដីកាថា សន្តិភាព គឺសំដៅទៅលើសន្តិភាពខាងក្នុង និងការវៀរចាកកិលេសនៃចំណង់ផ្សេងៗ ។

> សន្តិភាពនៅក្នុងប្រពៃណីនេះមានន័យថា ការបំបាត់ចោលនូវចំណង់ដែលជាឫសគល់នៃទុក្ខ ។ គឺមានភាពខុសប្លែកពីសន្តិភាព (Shalom) នៅក្នុងព្រះគម្ពីរ ដែលផ្សារភ្ជាប់ជាមួយនឹងសុខមាលភាពសង្គម និងយុត្តិធម៌យ៉ាងល្អ[២] ។

ពាក្យថា "ព្រះជាម្ចាស់" "God" ចំពោះគ្រីស្តបរិស័ទលោកខាងលិចគឺតែងតែគិតចំពោះភាពគង់នៅសព្វទីកន្លែង សព្វញ្ញុតញ្ញាណ ជាអង្គដែលសំខាន់បំផុត ជាអាទិករ និងជាអ្នកដែលរក្សាជីវិត ។ ចំពោះអ្នកកាន់ព្រះពុទ្ធសាសនា "ព្រះ" "god" មានន័យថា ជាអង្គដ៏អស្ចារ្យលើសជាងមនុស្ស ដែលមានការល្អ និងអាក្រក់លាយឡំគ្នានៅក្នុងនោះ ប៉ុន្តែខ្វះគុណភាព "គ្រប់យ៉ាង" "omni" ដូចជាព្រះរបស់គ្រីស្តបរិស័ទ ។ មានពួកកាតូលិកមួយក្រុមបានបើកការប្រាស្រ័យទាក់ទងជាមួយព្រះសង្ឃនៃពុទ្ធសាសនាដោយសួរសំនួរនេះ "តើជាការត្រឹមត្រូវដែរឬទេ ដែលថាព្រះពុទ្ធគឺជាព្រះ?" ។ ដោយគ្មានការបង្អង់

---

[២] *ស៊ី ណរម៉ែន ក្រូស, អ្នកនាំដំណឹងល្អ? បេសកកម្មគ្រីស្តបរិស័ទទៅមុនសម័យ ពិភពលោកទំនើប (ដោនើស៍ ហ្គ្រូវ, អ៊ីលីណយស៍: អ៊ិនធើ វ៉ាស៊ីធី, ១៩៩៨), ៨២ ។*

យូរ ព្រះសង្ឃមានសង្ឃដីកាឆ្លើយតបថា "មិនត្រូវទេ ព្រះពុទ្ធធំជាងព្រះណាៗទាំងអស់" ។ ព្រះសង្ឃទាំងនោះបានពន្យល់ថា គឺជាព្រះធម៌ (សេចក្តីបង្រៀន) ដែលនាំមកនូវការរំដោះ ហើយព្រះពុទ្ធផ្តល់ព្រះធម៌មក ។ នៅក្នុងគំនិតពួកគេ ព្រះទាំងអស់មានភាពទាបជាងព្រះពុទ្ធ ហើយគ្មានអំណាចអ្វីឡើយ[៣]។

បញ្ហាចំពោះការអភិវឌ្ឍន៍បែបលោកខាងលិច ដូចដែលបានឲ្យនិយមន័យខាងលើ គឺមានចេតនាចែងជ្រុលដើម្បីឲ្យមានការងាយយល់ គឺថាការដែលមានចេតនាល្អ និងភាពយកចិត្តទុកដាក់ មិនគ្រប់គ្រាន់ក្នុងការជៀសវាងគ្រោះថ្នាក់នៃការអភិវឌ្ឍន៍នោះឡើយ ។ អង្គការអភិវឌ្ឍន៍មកពីលោកខាងលិចភាគច្រើនយល់ពីហេតុការណ៍នេះ ហើយកំពុងធ្វើការអភិវឌ្ឍន៍យ៉ាងអស្ចារ្យ ដែលធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងជីវិតមនុស្សដែលពួកគេកំពុងតែបំរើ ។

## តម្លៃនៃអ្នកកាន់ព្រះពុទ្ធសាសនា និងការអភិវឌ្ឍន៍

សម្តេចព្រះនរោត្តម សីហនុ បានចង្អុលបង្ហាញដល់សារៈប្រយោជន៍នៃព្រះពុទ្ធសាសនានៅក្នុងសង្គមកម្ពុជា ។ ដោយមានសេចក្តីយោងថា ការយល់ដឹងអំពីព្រះពុទ្ធសាសនា គឺជាសារៈសំខាន់ដើម្បីទទួលជោគជ័យយ៉ាងល្អនៅក្នុងប្រទេសកម្ពុជា ។ តើគំនិតជាទូទៅរបស់អ្នកកាន់ព្រះពុទ្ធសាសនាមានការប៉ះទង្គិចដល់ការអភិវឌ្ឍន៍យ៉ាងណាដែរ? តើតម្លៃអ្វី ដែលអ្នកកាន់ព្រះពុទ្ធសាសនាកាន់យ៉ាងខ្ជាប់ខ្ជួនទាក់ទងទៅនឹងការអភិវឌ្ឍន៍? តើតម្លៃនៃអ្នក

---

[3] *ហ្វ្រង់ស្វ័រ ប៉ុងស្វដ៍*, The Cathedral of the Rice Paddy, *៤៥០ ឆ្នាំនៃប្រវត្តិសាស្ត្រក្រុមជំនុំក្នុងប្រទេសកម្ពុជា ។ មជ្ឈមណ្ឌលណាទស៊ី កិកនា និងប៊ីធប សាលាស កាតូលិកកម្ពុជា (ទីក្រុង ប៉ារីស: ហ្វាយ៉ាត, ១៩៩០), សេចក្តីបន្ថែម ១, "ការជ្រៀតចូលទៅក្នុងប្រវត្តិសាស្ត្រនៃសាសនារបស់ខ្មែរ" ។*

កាន់ព្រះពុទ្ធសាសនាមានភាពល្បីរន្ទឺដល់តម្លៃរបស់គ្រីស្ទបរិស័ទ ដោយរបៀបណា?

អ្នកធ្វើការអភិវឌ្ឍន៍ទាំងឡាយដែលជួបប្រទះនូវសំនួរទាំងអស់នេះ ត្រូវតែបើកចំហដើម្បីប្រាស្រ័យទាក់ទងដោយសេចក្តីគោរព និងទទួលយកនូវភាពខុសគ្នានៃគំនិតទូទៅផ្សេងៗ ។ យើងត្រូវតែសង្ឃឹមចង់បានការកែប្រែ ទោះបីជាយើងកំពុងស្វែងរកការកែប្រែនោះក៏ដោយ ដើម្បីបើកចំហចូលទៅក្នុងដំណើរការកែប្រែដ៏កណ្តាលមួយ ។ ចំពោះអ្នកធ្វើការអភិវឌ្ឍន៍ បញ្ហានេះពាក់ព័ន្ធទៅនឹងរង្វង់ដែលវិលហើយវិលទៀតក្នុងការជួបប្រទះយ៉ាងស៊ីជំរៅ ការដកថយ ការឆ្លុះបញ្ចាំង និងការរួមជាមួយភាពដែលអាចកែប្រែបាន ។

មានតម្លៃប្រពៃណីនៃអ្នកកាន់ព្រះពុទ្ធសាសនាជាច្រើនដែលអាចរួមចំណែកយ៉ាងសំខាន់ទៅក្នុងទំរង់នៃការអភិវឌ្ឍន៍ ។

## មជ្ឈិមបដិបទា (ផ្លូវកណ្តាល)

ព្រះសក្យមុនី ដែលជាព្រះនាមដើមរបស់ព្រះពុទ្ធ ពេលមានព្រះជន្ម ២៧ ព្រះវស្សា បានចាកចេញពីជីវិតដ៏ស្តុកស្តម្ភក្នុងនាមជាព្រះអង្គម្ចាស់ និងចាកចេញពីការសប្បាយទាំងឡាយដើម្បីស្វែងរកការរំដោះខ្លួនឲ្យរួចផុតពីវាលវដ្តសង្សារ ។ ជាច្រើនឆ្នាំបន្ទាប់មក ទ្រង់បានបួស និងធ្វើទុក្ករកិរិយា ។ នៅក្នុងអំឡុងពេលនោះ ទ្រង់បានបំភ្លឺ "អរិយមគ្គៈ" (ផ្លូវទាំងប្រាំបី) ដើម្បីនាំទៅរកសម្មាអាជីវៈ (ការរស់នៅឲ្យបានត្រឹមត្រូវ) ។ ផ្លូវនេះប្រាប់ពីដំណើរឆ្ពោះទៅរកការរំដោះឲ្យរួច ជាផ្លូវកណ្តាលដែលមិនមានលក្ខណៈសេរីហួសហេតុ ឬការធ្វើទុក្ករកិរិយាខ្លាំងពេក ។

> សំរាប់អ្នកកាន់ព្រះពុទ្ធសាសនាភាគច្រើន សេចក្តីបង្រៀនអំពី មជ្ឈិមបដិបទា (ផ្លូវកណ្តាល) ត្រូវបានគេកាន់តាមដូចដែលបានផ្តល់មកឲ្យ និងជាការពិតដែលគេអាចទទួល

យកបាន... ពួកគេកាន់តាមដូចដែលព្រះពុទ្ធបង្រៀន ហើយបន្ទាប់មកដឹកនាំជីវិតគេ ឲ្យវៀរចាកនូវភាពអួតអាង ហួសហេតុ និងការបួសដែលមិនមានលំនឹងត្រឹមត្រូវ ព្យាយាមរក្សាក្ដីរំពឹងអំពីរបស់ផ្សេងៗរួមទាំងខ្លួនគេផង ដែលមានភាពប្រាកដនិយម ការដាក់ខ្លួន និងការរួចផុតពីការបំភាន់ខ្លួនឯង[៤]។

គំនិតនេះជាតំណាងនៅក្នុងផ្លូវកណ្ដាល និងការចូលរួមនៃរបៀបរស់នៅដែលជាផ្នែកមួយនៃទស្សនៈរបស់ភ្នាក់ងារអភិវឌ្ឍន៍ ។ ផ្លូវកណ្ដាលនៃការអភិវឌ្ឍន៍ គឺមិនមែនជាភាពក្រីក្រនៃឧត្ដមគតិ ឬក៏ជាការឃោសនានៃអ្នកប្រើប្រាស់នោះឡើយ ។ ការធ្វើរបៀបនេះនឹងប្រើបច្ចេកវិជ្ជាឲ្យបានត្រឹមត្រូវ។ ថម ឌូឡេ (Tom Dooley) ជាវេជ្ជបណ្ឌិត និងជាអ្នកអភិវឌ្ឍន៍នៅក្នុងប្រទេសឡាវ នៅដើមឆ្នាំ ១៩៦០ បាននិយាយថា គាត់មិនបានសំរេចចិត្តនាំជនជាតិឡាវ ទៅកាន់ជំនាន់ទាន់សម័យដូចគ្នានោះទេ ប៉ុន្តែគ្រាន់តែនាំពួកគេទៅក្នុងសតវត្សដូចគ្នាប៉ុណ្ណោះ ។ "មានគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់អ្នកទទួលប្រើប្រាស់ ខ្លាំងជាងការស្ថិតនៅក្នុងភាពក្រីក្ររបស់កសិករ"[៥] ។

## បដិច្ចសមុប្បាទ (ភាពជាប់ទាក់ទងគ្នា)

អ្នកកាន់ព្រះពុទ្ធសាសនាមើលឃើញបដិច្ចសមុប្បាទ (ភាពជាប់ទាក់ទងគ្នា) នៅក្នុងគ្រប់របស់ទាំងអស់ដែលមានជីវិត និងរបស់ដែលគ្មានជីវិតនៅលើផែនដី និងក្នុងពិភពលោកនេះ ។ ដូច្នេះ អ្វីៗទាំងអស់ដែលយើងធ្វើ

---

[៤] *វីលៀម អាវ័ឡាហ្វី, ព្រះពុទ្ធសាសនា: ទស្សនៈវិស័យនៃវប្បធម៌ (អេង្គលវូដ គ្លីហ្វស៍, ញូ ជើសេយ៍:* Prentice Hall, *១៩៩៨), ៨០ ។*

[៥] *ដាវីដ ក៉ាចុន, អតីតព្រះសង្ឃពុទ្ធសាសនាទៅក្នុងកិច្ចសម្ភាស ខែតុលា ឆ្នាំ១៩៩៩ ។*

សុទ្ធតែមានភាពជំពាក់ទាក់ទងគ្នាទាំងអស់ ហើយទោះជាភាពវិជ្ជមាន ឬអវិជ្ជមាន គឺមានការប៉ះទង្គិចគ្នាទៅនឹងសភាពរបស់យើងក្នុងលោកនេះ ។

> "ព្រះពុទ្ធសាសនាក្តោបនូវទស្សនៈនៃតថភាព ដែលនៅក្នុងគ្រប់ទាំងផ្នែកនៃលោកនេះ ទោះជារស់នៅ ឬមិនរស់នៅក្តី គឺបានយល់ថា ជាសភាពដែលមានទំនាក់ទំនងគ្នា ហើយពឹងផ្អែកគ្នាទៅវិញទៅមក ។ ម្យ៉ាងវិញទៀត គ្មានអ្វីដែលកើតឡើងដោយខ្លួនវា ប៉ុន្តែនៅក្នុងទំនាក់ទំនងទៅរបស់ដទៃទៀតលើផែនដី និងលើលោកនេះ"[៦] ។

ផល្លីស (Pallis) សរសេរចេញពីទស្សនៈពុទ្ធនិយម បានស្នើមធ្យោបាយនៃការទទួលការតភ្ជាប់ជាមួយគ្នាតាមរយៈការបកស្រាយរឿងរបស់គ្រីស្តបរិស័ទអំពីប្រភពដើមនៃវិញ្ញាណអាក្រក់នៅសួនច្បារ អេដែន[៧] ។ ដើមជីវិតបញ្ជរនៅស្ថានសួគ៌ ជាកន្លែងដែលគ្មានជម្លោះ ឬការភ័យខ្លាច ។ អ័ដាម និងអេវ៉ាចូលរួមយ៉ាងពេញលេញ ប៉ុន្តែមានភាពវិជ្ជមាននៅក្នុងការកំណត់នោះ ។ សត្វពស់ល្បួងអ័ដាម ឲ្យភ្លក់នូវបទពិសោធន៍ថ្មីតាមរយៈនាងអេវ៉ា ។

បទពិសោធន៍ថ្មីបានឲ្យតម្លៃទៅលើវត្ថុ តាមគោលបំណងរបស់ខ្លួនឯង ហាក់បីដូចជាពួកគេមានការបែកចេញពីសង្គមមនុស្សទាំងស្រុងទៅហើយ ។ អ័ដាម និងអេវ៉ាបានភ្លក់ផ្លែនៃដើមជីវិត ពួកគេបានដឹងគ្រប់ការទាំងអស់ថា ពួកគេត្រូវបែកចេញពីគ្នា ហើយចេញពីរបស់ផ្សេងទៀតដែលនៅ

---

[៦] *ទំនួញសោកពីព្រៃឈើ: "សហគមន៍សិក្សាពីព្រះពុទ្ធសាសនា និងបរិស្ថានវិទ្យា", គម្រោងកម្មវិធីអប់រំស្តីពីបរិស្ថានតាមរយៈព្រះសង្ឃ, វិទ្យាស្ថានពុទ្ធសាសនា, ភ្នំពេញ, កម្ពុជា, ១៩៩៩ ។*

[៧] *ម៉ាក្រូ ផល្លី, វេទិកាពុទ្ធសាសនិក: ការចូលរួមកិច្ចសន្ទនារវាងពុទ្ធបរិស័ទ និងគ្រីស្តបរិស័ទ (ញូយ៉ក: Seabury, ១៩៨១) ។*

ជុំវិញគេ ។ ដោយព្រោះតែការយល់ដឹងថ្មីរបស់ពួកគេពីការញែកពីគ្នា ធ្វើឲ្យពួកគេមានការដឹងខ្លួនអំពីភាពអាក្រាតរបស់ពួកគេ ហើយព្យាយាមលាក់បំបាំងសេចក្តីខ្មាសរបស់ពួកគេដោយការបិទបាំងខ្លួន ។ សភាពនៃខ្លួនគេដែលធ្វើឲ្យខុសពីភាពដើមនេះ បានក្លាយទៅជាគំរូដើមដល់គ្រប់មនុស្សទាំងអស់ ។

ដើមជីវិតក្លាយទៅជាដើមដឹងខុសត្រូវ អោនចុះបង្កើតនូវផលផ្លែល្អ និងផលផ្លែអាក្រក់របស់វាដែលមានគ្រាប់ក្លាយជាល្អ និងអាក្រក់ ។ ដែលធ្វើឲ្យឥឡូវនេះមានការល្អ និងការអាក្រក់ ។

សូមឲ្យយើងកត់សំគាល់ឲ្យបានល្អថា នៅក្នុងសួនអេដែនមានសត្វពស់ ។ សត្វពស់ គឺមានការចាំបាច់នៅក្នុងសួនច្បារ ពីព្រោះបើស្ថានសួគ៌គ្មានពស់ទេនោះ គឺមានតែព្រះប៉ុណ្ណោះ ។ សត្វពស់ គឺជាតំណាងនៃភាពមិនគ្រប់លក្ខណ៍ ។ គ្រប់របស់ទាំងអស់ដែលបានបង្កើតឡើង គឺមានកំរិតនៃភាពគ្រប់លក្ខណ៍របស់ខ្លួន ប៉ុន្តែភាពគ្រប់លក្ខណ៍នោះ គឺជាញាតិនឹងគ្នា ។ អ្វីដែលនៅក្រៅព្រំដែននៃសុក្រឹត បណ្តាលឲ្យមានការវេទនា និងការកែប្រែ ។ ការសន្មតជាមូលដ្ឋាននៃព្រះពុទ្ធសាសនាគឺថា ការរងទុក្ខ គឺជាលទ្ធផលនៃការចូលរួមនៃជីវិតក្រៅរង្វង់របស់សុក្រឹតភាព ។

នៅក្នុងព្រះពុទ្ធសាសនា គ្មានការគិតគូរដល់ការបង្កបង្កើតពិភពលោកឡើយ ។ អ្នកកាន់ព្រះពុទ្ធសាសនាទាមទារលើ "អនត្តា" (ភាពមិនមែនជាខ្លួនឯង) ហើយគ្រប់របស់ទាំងអស់ចង្អុលចេញពីគំនិតនៃការជួសជុលខ្លួន និងការញែកចេញពីជីវិតដទៃទៀត ។ ពួកគេគិតថា អវត្តមាននៃការបង្កបង្កើតលោក ក៏ជាអវត្តមាននៃការចាប់ផ្តើមដែរ ។ ប៉ុន្តែនៅក្នុងគំនិតរបស់ព្រះពុទ្ធសាសនា គឺមានសេចក្តីបញ្ចប់ ។ សេចក្តីបញ្ចប់ គឺជាការរួមបញ្ចូលគ្នាទៅក្នុងចំណុចកណ្តាលនៃការត្រាស់ដឹង "ជាកន្លែងដែលចាកផុតពីវដ្តសង្សារ" ហើយអស់អ្នកណាដែលបានរំដោះចេញពីទុក្ខ ។

ដោយទទួលស្គាល់ថា ការអាក្រក់ គឺជាផ្នែកមួយនៃរបស់ដែលបាន បង្កើតឡើងក្នុងលោកយើងនេះ តើយើងដែលជាមនុស្សអាចត្រឡប់ទៅស្ថានសួគ៌ ទៅដើមជីវិតដូចម្តេចបាន? ផល្លីស សន្មតថា យើងធ្វើយ៉ាងដូច្នេះ ដោយការដើរត្រឡប់តាមជំហានដដែលរបស់ពួកជីដូនជីតារបស់យើង ។ អ័ដាមបានទាញចិត្តចេញពីរង្វង់នៃបរិមណ្ឌល ។ យើងត្រូវតែវិលត្រឡប់ចេញពីបរិមណ្ឌល ឆ្ពោះទៅរករង្វង់ចេញពីការញែកដាច់ចេញពីគ្នាទៅភាពតភ្ជាប់គ្នាវិញ ។ យើងបានកើតឡើងនៅក្នុងគតិបណ្ឌិតនៃដើមដឹងខុសត្រូវ។ តាមរយៈដើមឈើនេះ យើងត្រូវស្វែងរកឲ្យឃើញដើមនៃជីវិត ។ ការត្រាស់ដឹង គឺជាគន្លឹះទៅរកការរួមបញ្ចូលគ្នាជាថ្មីទៅក្នុងរង្វង់នោះ ។ ដើម្បីរួមបញ្ចូលជាថ្មីចូលក្នុងរង្វង់ យើងត្រូវការពន្លឺនៃការត្រាស់ដឹង ។ ដើម្បីឲ្យយើងអាចទទួលការរួមបញ្ចូលគ្នាជាថ្មី ភាពសំខាន់រវាងសេចក្តីល្អ និងសេចក្តីអាក្រក់ទាំងពីរនេះ មានការទទួលទុកដូចជាផ្នែកនៃការបង្កបង្កើត ។ បន្ទាប់មកពិសនៃសត្វពស់នោះនឹងគ្មានប្រសិទ្ធភាពឡើយ ។

ទោះបីជាយ៉ាងណាក៏ដោយ យើងទទួលទេវវិទ្យារបស់ផល្លីស និងផ្លូវទៅរកការអភិវឌ្ឍន៍តភ្ជាប់គ្នា អ្នកធ្វើការអភិវឌ្ឍន៍អាចធ្វើបានល្អដើម្បីរក្សាគំនិតអំពីជំហាននៃការកែប្រែដែលយើងសំរបសំរួលជាមួយសហគមន៍ក្នុងស្រុក និងជាពិសេសពិភពលោកនេះ ។ អ្នកភូមិប្រហែលជាដឹងច្បាស់នូវគំនិតនេះជាងការដែលយើងគិតទៅទៀត ។ ខ្ញុំនឹកចាំកាលដែលខ្ញុំទៅលេងភូមិមួយនៅប្រទេសឥណ្ឌា ភូមិនោះនៅឆ្ងាយដាច់ស្រយាលដោយមានទន្លេបួនដែលគ្មានស្ពាន គ្មានវិទ្យុទាក់ទង ឬកាសែតអានឡើយ ។ មនុស្សនៅក្នុងភូមិនេះបានដឹងអំពីសន្និសិទអន្តរជាតិនៃបរិស្ថាន ដែលបានធ្វើឡើងបីសប្តាហ៍មុននៅអាមេរិកខាងត្បូង ។

## ការរងទុក្ខ

ការរួចផុតពីទុក្ខ គឺជាចំណុចសំខាន់នៃគំនិតរបស់អ្នកកាន់ព្រះពុទ្ធសាសនា ។ ការរំដោះចេញពីទុក្ខជាតំណាងឲ្យសេរីភាព ។ សេចក្តីពិតដ៏មានតម្លៃបួនយ៉ាងរបស់អ្នកកាន់ព្រះពុទ្ធសាសនាបង្កើតឲ្យមានប្រព័ន្ធគំនិតមួយដើម្បីបង្ហាញអត្តសញ្ញាណ និងបង្ហាញពីភាពរំដោះរួចពីទុក្ខ ។ អរិយសច្ចៈទាំងបួនយ៉ាងនេះស្ថិតនៅក្នុងមូលដ្ឋាននៃវេជ្ជសាស្ត្រ ៖

- ទុក្ខៈ ទទួលស្គាល់នូវរោគសញ្ញានៃទុក្ខ (ការរងទុក្ខ)
- សមុទយៈ ស្រាវជ្រាវរកឲ្យឃើញនូវមូលហេតុនៃទុក្ខ (ដាក់ឈ្មោះឲ្យទុក្ខនោះ)
- និរោធៈ វិភាគពីមូលហេតុនៃទុក្ខ ហើយនិង
- មគ្គៈ អនុវត្តនូវមធ្យោបាយដោះស្រាយដើម្បីរំងាប់ទុក្ខនោះ ។

ទុក្ខកំពុងរីករាលដាលនៅក្នុងពិភពលោក ។ យើងអាចរត់គេចចេញពីទុក្ខ យើងអាចសង់ជញ្ជាំងដើម្បីបិទមិនឲ្យទុក្ខនោះចូលមកបាន ឬក៏ប្រើភាពសាមញ្ញមួយដោយវៀរចាកភាពដែលមាននៅពីមុនរបស់វា ។ មនុស្សដែលមានការចាប់អារម្មណ៍នៅក្នុង "ការអភិវឌ្ឍន៍" ជាដំបូងត្រូវសម្លឹងឲ្យចំតែម្តងចំពោះទុក្ខនោះ ហើយទទួលស្គាល់ថាទុក្ខ គឺមាននៅក្នុងពេលបច្ចុប្បន្ននេះ ។ នេះជាតម្រូវការ ព្រោះវាមិនមែនគ្រាន់តែក្រឡេកទៅមើលមួយភ្លែតតែប៉ុណ្ណោះនោះឡើយ ។ ម្នាក់ៗត្រូវមានអារម្មណ៍ដឹងពីទុក្ខនោះ នៅពេលដែលទទួលស្គាល់ថា អស់អ្នកណាដែលគ្មានបទពិសោធន៍ ទុក្ខនេះនឹងមានការលំបាកក្នុងការបញ្ចេញឲ្យដឹងដល់អស់អ្នកដែលជួបប្រទះនឹងទុក្ខ ។

ចំពោះការដែលមានអារម្មណ៍ដឹងចំពោះវត្តមាននៃទុក្ខ គឺត្រូវតែដាក់ឈ្មោះឲ្យវា ។ ទុក្ខដែលគ្មានឈ្មោះ ងាយស្រួលក្នុងការធ្វើមិនដឹង មិនឮណាស់ ។ ការឲ្យឈ្មោះទុក្ខ នាំចូលមកក្នុងគំនិតនៃភាពដឹងខ្លួនដែលពិបាកធ្វើឲ្យយើងធ្វើមិនដឹង មិនឮបាន ។

ជំហានបន្ទាប់ គឺការស្រាវជ្រាវរកឲ្យឃើញនូវមូលហេតុនៃការរងទុក្ខ ទោះជាទុក្ខខាងរូបកាយ ដូចជាការឈឺចាប់នៃសេចក្ដីស្រេកឃ្លាន ការរងទុក្ខខាងអារម្មណ៍ដែលគិតថាខ្លួនឯងមានតម្លៃទាប ឬការរងទុក្ខខាងវិញ្ញាណ ដូចជាមានភាពឯកោ និងការបែរចេញ ។ ដូចនៅក្នុងគំរូវេជ្ជសាស្ត្រ ការត្រឹមត្រូវក្នុងការឲ្យឈ្មោះ និងការស្រាវជ្រាវរកពីមូលហេតុនៃការរងទុក្ខ នោះគឺចាំបាច់ណាស់ដើម្បីរកឲ្យឃើញនូវមធ្យោបាយដ៏ត្រឹមត្រូវ ។

ចំពោះមធ្យោបាយនេះ ត្រូវតែធ្វើតាមលំដាប់លំដោយវេជ្ជសាស្ត្រ "ជាដំបូង មិនត្រូវធ្វើឲ្យអន្តរាយ" ។ គោលដៅ និងរូបមន្តនៃមធ្យោបាយដោះស្រាយ គឺមានទំនាក់ទំនងទៅនឹងភាពត្រូវការជាបន្ទាន់ ។ មធ្យោបាយបន្ទាប់ពីការគ្រោះថ្នាក់នៃធម្មជាតិ គំរូវឲ្យមានការជួយជាបន្ទាន់សំរាប់ផ្គត់ផ្គង់នូវសេចក្ដីត្រូវការជាចាំបាច់ដូចជាអាហារ ទីជំរក និងសំលៀកបំពាក់ ។ គោលដៅនេះ គឺមានភាពខុសគ្នាយ៉ាងច្បាស់ពីការអភិវឌ្ឍន៍រយៈពេលយូរ ។ នៅក្នុងគំនិតនៃការអភិវឌ្ឍន៍រយៈពេលយូរ គឺពិតជាត្រូវការណាស់ ។ មធ្យោបាយនៃការដោះស្រាយរយៈពេលខ្លី ហើយលឿនប្រហែលជាបង្កើតឲ្យមានការពឹងពាក់យ៉ាងខ្លាំងដែលបណ្ដាលឲ្យមានការរងទុក្ខកាន់តែខ្លាំងឡើងនៅក្នុងរយៈពេលយូរ ។

ការរងទុក្ខរបស់អ្នកកាន់ព្រះពុទ្ធសាសនា គឺជាការដែលចេញក្រៅពីជំហាននៃគោលការណ៍របស់អាទិទេព ។ គោលការណ៍របស់អាទិទេព គឺមានវត្តមានគ្រប់ទីកន្លែងទាំងអស់នៅលើពិភពលោក ប៉ុន្តែមនុស្សមិនបានអនុវត្តឲ្យត្រឹមត្រូវនៅក្នុងគោលការណ៍នោះទេ ។ ដូច្នេះ លទ្ធផល ដែលត្រូវទទួលគឺការរងទុក្ខ ។ កម្លាំងរបស់មនុស្សដើម្បីបង្កើតការល្អ ឬកំចាត់ចេញនូវការអាក្រក់ និងបង្កើតឲ្យមានភាពជាខ្លួនឯង ហើយការនោះឯងដែលបណ្ដាលឲ្យមានការរងទុក្ខ ។

> ទំរង់នៃការរងទុក្ខទាំងអស់ គឺបានទទួលស្គាល់ថា ជារង្វាស់នៃការឃ្លាតឆ្ងាយយ៉ាងច្បាស់របស់ពិភពលោកចេញពីគោលការណ៍របស់អាទិទេព ។ គោលការណ៍ពិតជានៅគ្រប់ទីកន្លែងទាំងអស់ក្នុងពិភពលោក ប៉ុន្តែពិភពលោកគ្មានវត្តមានជាមួយគោលការណ៍នោះទេ ។ ភាពផ្ទុយគ្នាដ៏ច្បាស់លាស់រវាង "ខ្លឹមសារ" និង "ការចៃដន្យ" គឺទទួលនូវការរងទុក្ខ[8] ។
>
> ដូច្នេះដំណើរការមិនដែលឈប់ឡើយ ហើយ
>
> ការព្យាយាមជាច្រើនរបស់យើងដើម្បីកំចាត់ចោលនូវរាល់ការអាក្រក់ទាំងឡាយ នឹងនៅតែចាំបាច់ក្នុងការព្យាបាលរោគសញ្ញាទាំងនោះនូវមូលហេតុដ៏ធ្ងន់ធ្ងរបណ្តាលឲ្យខូចសុខភាពដែលមិនអាចប៉ះពាល់បាន ពីព្រោះបញ្ហានៃការសង្កេតឲ្យស្គាល់នោះ គឺជាការចាំបាច់ក្នុងការធ្វើរោគវិនិច្ឆ័យ[9] ។

ការទទួលស្គាល់ការរងទុក្ខ ការដាក់ឈ្មោះការរងទុក្ខ ការបង្កើតឡើងនូវឱសថសំរាប់ព្យាបាល និងការប្រើឱសថសំរាប់ព្យាបាល គឺជាចតុរារិយសច្ច ឬសេចក្តីពិតដ៏ប្រពៃទាំងបួន ។ កម្មវិធីអភិវឌ្ឍន៍គ្រីស្តបរិស័ទត្រូវតែអនុវត្តការពិតសំខាន់ទាំងបួនយ៉ាងនេះសំរាប់ផលប្រយោជន៍ពួកគេ ។ វិន័យទាំងនេះអាចអនុវត្តបានដល់បុគ្គលម្នាក់ៗ ដល់ក្រុមផ្សេងៗ ដល់ភូមិផ្សេងៗ និងដល់ជនជាតិផ្សេងៗផងដែរ ។

---

[8] Ibid., 46.

[9] Ibid., 48.

## គតិលោកនៃអ្នកកាន់ព្រះពុទ្ធសាសនាជីវចលនិយម

នៅក្នុងការព្យាយាមរបស់គាត់ដើម្បីពន្យល់ ហេតុអ្វីបានជាការអាក្រក់កើតឡើង អ្នកជីវចលនិយមផ្តល់មកនូវការបំភ័យដែលគួរឲ្យព្រឺខ្លាច ឬអាថ៌កំបាំងដល់វិញ្ញាណផ្សេងៗ ឬវិញ្ញាណនៃជីដូនជីតារបស់គេ ។ អ្នកកាន់ព្រះពុទ្ធសាសនានៅតាមជនបទ មានជំនឿលើវិញ្ញាណផ្សេងៗ ក្នុងកិរិតនៃការបំរើ ពួកគេនៅក្នុងការពន្យល់ឲ្យដឹងអំពីសំណាងអាក្រក់ដែលនឹងកើតមានដល់ពួកគេ[10]។

អ្នកជីវចលនិយមមានអារម្មណ៍ថា បញ្ហាដែលពួកគេជួបប្រទះ គឺស្ថិតនៅលើការញែកចេញទាំងស្រុង និងអានុភាពនៃសត្រូវខាងក្រៅ ។ គេអាចព្យាយាមជៀសចេញពីអានុភាពទាំងនេះបាន ដោយការសែនព្រេន ឬព្យាយាមក្នុងការសំរបសំរួលទៅតាមកម្លាំងទាំងនោះ ដោយប្រើមន្តអាគម ប្រសិនបើគេមានអំណាចអាចធ្វើបាន ។

ផ្ទុយទៅវិញនៅក្នុងគំនិតអ្នកកាន់ព្រះពុទ្ធសាសនា ការអាក្រក់ហាក់បីដូចជាធ្វើការនៅខាងក្នុងមនុស្ស ។ ការអាក្រក់ គឺជាការប៉ុនប៉ងព្យាយាមដើម្បីធ្វើវិទ្ធង្សនាដល់បុគ្គលនោះ នៅក្នុងការដែលគាត់ស្វែងរកការត្រាស់ដឹង ។ ការអាក្រក់អាចឈ្នះវាបានដោយវិន័យនៃការស៊ើងស្មាធខាងក្នុង ។ ព្រះពុទ្ធមានពុទ្ធដីកាថា "ការអាក្រក់អាចឈ្នះបានដោយកម្លាំងរបស់ខ្លួនផ្ទាល់"។ នៅពេលដែលព្រះពុទ្ធជិតចូលនិព្វាន្ត ព្រះអង្គមានពុទ្ធដីកាថា "សង្ឃទាំងឡាយ ចូរព្យាយាមធ្វើការឡើង ដើម្បីសង្គ្រោះខ្លួនឯង" ។

ដើម្បីជៀសចេញពីជំងឺ ឬទទួលភោគសម្បត្តិជាអ្នកមាន ឬជាអ្នកមានអំណាចបាន ត្រូវតែមានភាពប៉ិនប្រសប់ដល់លោកីយ៍ខាងក្រៅ ដោយ

---

[10] *ទ្រីវ័រ លីង. ព្រះពុទ្ធសាសនា និង ទេវកថាវិទ្យាដែលនិយាយអំពីខ្មោចព្រាយបិសាច (សាកលវិទ្យាល័យ អុកស្វដ:* Oneworld,១៩៩៧), ៧៨ ។

មានការរក្សាឲ្យបានល្អចេញពីផ្លូវរបស់ការអាក្រក់ ឬវិញ្ញាណខ្មោចបិសាចផ្សេងៗដែលមានការសែនព្រេនឲ្យបានត្រឹមត្រូវដើម្បីផ្តល់ឲ្យពួកគេមានភាពសប្បាយរីករាយ ឬឲ្យមានអំណាចកាន់តែខ្ពស់ឡើង ។ គតិលោកនៃអ្នកជីវចលនិយម មានភាពផ្ទុយទៅនឹងអ្នកកាន់ពុទ្ធសាសនា ដែលពណ៌នាពីសេចក្តីអាក្រក់ធ្វើការនៅខាងក្នុងមនុស្ស ហើយមានការផ្តោតទៅលើបុគ្គលិកលក្ខណៈខាងក្នុងទៅវិញ (សូមឲ្យយើងធ្វើការពិចារណាពីបញ្ហារបស់អ្នកជីវចលនិយមជនបទមួយ ដែលមានបំណងចង់ក្លាយជាសង្ឃរបស់ព្រះពុទ្ធ គឺគាត់ត្រូវតែលះចោលផ្នត់គំនិតទាំងអស់ដែលជឿថា សេចក្តីអាក្រក់មានមកពីភាពខាងក្រៅខ្លួនគាត់ ដោយមានការផ្តោតទាំងស្រុងទៅលើបញ្ហាខាងក្នុងវិញ ទើបអាចឆ្ពោះទៅរកភាពគ្រប់លក្ខណ៍បាន) ។

ក្នុងកម្លាំងដែលខំប្រឹងស្វែងយល់ពីគតិលោករបស់អ្នកភូមិនោះ លោក បណ្ឌិត រ៉ាវី ចាយ៉ាការ៉ាន់ (Dr. Ravi Jayakaran) ប្រើ "រូបមន្តដប់គ្រាប់"[១១] បានសួរដល់អ្នកចាស់ទុំនៅក្នុងភូមិឲ្យធ្វើការវិភាគថា តើអ្វីទៅដែលគ្រប់គ្រងជីវិតពួកគេ ហើយតើដល់កំរិតណា ដែលពួកគេគិតថាការគ្រប់គ្រងនោះមានការគ្រប់គ្រងដោយខ្លួនឯង ដោយអ្នកដទៃ ឬដោយអបិយជំនឿ ។ ពួកគេត្រូវបានសូមឲ្យធ្វើជាតួលេខនៅក្នុងការស្រាវជ្រាវនេះក្នុងភូមិទាំងមូល ទោះជាអ្នកមាន ឬអ្នកក្រ ។ លទ្ធផលមានដូចខាងក្រោម ៖

| ក្រុម | ផ្ទាល់ខ្លួន | អ្នកដទៃ | អបិយជំនឿ |
|---|---|---|---|
| ភូមិទាំងមូល | ៥ | ៣ | ២ |
| អ្នកមាន | ៨ | ០ | ២ |
| អ្នកក្រ | ២ | ៦ | ២ |

[១១] "រូបមន្តដប់គ្រាប់" ជាមធ្យោបាយមួយដែលគ្មានការគំរាមកំហែងដល់អ្នកភូមិ ជារូបមន្តសំរាប់បង្ហើនតម្លៃនៃទំនាក់ទំនងឲ្យទៅជាពហុជំរើស ។

គាត់បានធ្វើការស្ទង់អត្ថន័យឲ្យបានជ្រៅជាងនេះទៅទៀតជាមួយចាស់ទុំ ៖

| | |
|---|---|
| ព្រះពុទ្ធ | ២០% |
| វិញ្ញាណផ្សេងៗ | ២០% |
| វិញ្ញាណរបស់ជីដូនជីតា | ៣០% |
| កុសលមកពីជាតិមុន | ៣០% |

បន្ទាប់មកគាត់បានសួរពីអត្ថន័យនៃវិញ្ញាណផ្សេងៗ តួលេខរបស់ពួកចាស់ទុំ មានដូចតទៅ ៖

| | |
|---|---|
| វិញ្ញាណល្អ | ៧០% |
| វិញ្ញាណអាក្រក់ | ២០% |
| វិញ្ញាណដែលអាក្រក់ផង ល្អផង | ១០% |

វិញ្ញាណជាច្រើន និងព្រះជាច្រើន គឺហាក់បីដូចជាមានតួនាទីសំខាន់ណាស់នៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នកភូមិទាំងអស់នោះ ។ នេះគឺជាការរួមបញ្ចូលរវាងពុទ្ធនិយម និងជីវចលនិយម ដែលវាជាលក្ខណសម្បត្តិរបស់មនុស្សនៅតាមជនបទភាគច្រើនក្នុងអាស៊ីខាងត្បូង ។

មានពេលខ្លះ ព្រះពុទ្ធសាសនានៃអាស៊ីខាងត្បូងនិយាយថា គ្មានអ្វីប្រសើរជាងបន្ទះឈើយ៉ាងស្តើងមួយ ដែលគ្របយ៉ាងជ្រៅទៅលើជីវចលនិយម និងចាក់ឫសយ៉ាងមាំនៅក្នុងជំនឿនៃវិញ្ញាណខ្មោចព្រាយបិសាច ហើយជីវចលនិយមនោះ គឺជាសាសនាដ៏ពិតប្រាកដនៃទឹកដីទាំងនេះ[១២]។

---

[12] *លីង, ព្រះពុទ្ធសាសនា និងទេវកថាវិទ្យាដែលនិយាយអំពីខ្មោចព្រាយបិសាច*, ១២ ។

## ការអភិវឌ្ឍន៍របស់គ្រីស្ទបរិស័ទនៅក្នុងប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាជីវចលនិយម

តើយើងអាចធ្វើដំណើរយ៉ាងដូចម្ដេចអំពីការងារអភិវឌ្ឍន៍? តើយើងគួរធ្វើយ៉ាងណាដែលជាការជួយដ៏ពិតប្រាកដ ហើយត្រឹមត្រូវ? តើយើងអាចនាំការសំរេចចិត្តកែប្រែយ៉ាងដូចម្ដេចបាន ដោយគ្មានការបំផ្លាញការផ្ដើមគំនិតរបស់អ្នកក្នុងស្រុក ប្រឌិតញ្ញាណ និងធនធានដ៏ពេញលេញ? តើសេចក្ដីត្រូវការពិតណាដែលត្រូវកែប្រែ? តើយើងអាចធ្វើសហប្រតិបត្តិការយ៉ាងណាជាមួយប្រជាជន ជាមួយពុទ្ធសានិកជន ឬពុទ្ធសាសនិកជនជីវចលនិយមដែលមានគតិលោករៀងៗខ្លួនរបស់ពួកគេ?

លោកគ្រស (Kraus)[១៣] បានសរសេរចេញពីគំនិតនៃការមើលឃើញរបស់គ្រីស្ទបរិស័ទនៅក្នុងសៀវភៅរបស់គាត់មួយឈ្មោះ "ការលយចូលនៃដំណឹងល្អ" បានស្នើការប្រាំយ៉ាង ដែលត្រូវការផ្លាស់ប្ដូរនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ។ តទៅនេះ ជាការផ្លាស់ប្ដូរប្រាំយ៉ាងដែលបានយកចេញមកពីកិច្ចការរបស់គាត់ ៖

- ផ្លាស់ប្ដូរពីរបៀបនៃការរំលោភ និងការចង់បានប្រយោជន៍ផ្ទាល់ខ្លួនទៅវិញទៅមកនៅក្នុងសហគមន៍
- ផ្លាស់ប្ដូរអ្នកនិយមជឿលើព្រេងវាសនា ដែលធ្វើឲ្យទប់ស្កាត់ដល់សេចក្ដីសង្ឃឹមដល់អ្នកដែលនិយមចូលចិត្តធ្វើការងារ
- ផ្លាស់ប្ដូររចនាសម្ព័ន្ធសង្គម ដែលមានការគាបសង្កត់មកពីអ្នកដែលមានបុណ្យសក្ដិ ដោយផ្ដល់នូវឱកាសដល់មនុស្សទាំងអស់រួមបញ្ចូលទាំងអ្នកដែលគ្មានផលប្រយោជន៍ដល់សង្គមផងដែរ
- ផ្លាស់ប្ដូរគំនិតដែលបំរើការអាក្រក់ និងគ្រោះថ្នាក់ធម្មជាតិដល់ប្រព័ន្ធ

---

[១៣] *លោកគ្រស, អ្នកផ្សាយដំណឹងល្អ, ៨២ ។*

ធ្វើការដែលបានទុកជាភស្តុតាងរួចមកហើយ ទោះជាសម័យដើម ឬសម័យទំនើប ។

- ផ្តល់នូវការណែនាំអំពីបច្ចេកទេសត្រឹមត្រូវ ។

សកម្មជនជាអ្នកកាន់ព្រះពុទ្ធសាសនាក៏បាននិយាយដែរ សំដៅទៅរកការចង់បានការផ្លាស់ប្តូរនៅក្នុងការអភិវឌ្ឍន៍សង្គម ។ សកម្មភាពសង្គមនៃអ្នកកាន់ព្រះពុទ្ធសាសនា គឺឆ្ពោះទៅរកការកាត់មន្ថយទុក្ខវេទនា ហើយផ្តោតទៅលើការអាណិតអាសូរ ចិត្តនឹងធឹង ការអត់អោន ការទុកចិត្តខ្លួនឯង និងការទទួលខុសត្រូវផ្ទាល់ខ្លួន ។ ដើម្បីសំរេចនូវគោលដៅនេះបាន វាជាការចាំបាច់ណាស់ដែលយើងត្រូវតែ ៖

- ជួយប្រជាជនឲ្យឈ្នះអំនួតរបស់ខ្លួនដែលធ្លាប់ចង់ឲ្យមានអ្នកនៅក្រោមបង្គាប់ ឬការជញ្ជក់យកផលប្រយោជន៍អ្នកដទៃ ការឲ្យតម្លៃខ្លួនឯងខ្ពស់ពេក និងបង្កើតឲ្យមានភាពខ្ពស់ទាបរវាងគ្នានឹងគ្នា
- ផ្តល់ឲ្យគ្នាទៅវិញទៅមកនូវសេរីភាព ដែលមានលក្ខខ័ណ្ឌតែមួយគត់ គឺសេរីភាព និងកិត្តិយសរបស់អ្នកដទៃដើម្បីអភិវឌ្ឍការទុកចិត្តដល់ការទទួលខុសត្រូវខ្លួនឯង
- មានការគិតគូរជាដំបូង និងជាមុនគេបំផុតជាមួយសម្ភារៈ និងលក្ខខ័ណ្ឌសង្គមសំរាប់ការអភិវឌ្ឍន៍ផ្ទាល់ខ្លួន ។ សម្តេចសង្ឃ ដាឡាយឡាម៉ា មានដីកាថា "មនុស្សមានឧត្តមភាព ជាងការរីកចំរើន"
- ផ្តត់ផ្តង់បច្ចេកវិជ្ជាលំដាប់កណ្តាល ដែលធ្វើឲ្យកិរិតសម្ភារៈល្អគ្រប់គ្រាន់នៅពេលដែលអាចរក្សាបាននូវភាពចុះសំរុងគ្នាតែមួយជាមួយបរិស្ថាន[១៤] ។

---

[14] *ខែន ហ្សទស៍ "ព្រះពុទ្ធសាសនា និងសកម្មភាពសង្គមៈ ការស្វែងរក" នៅក្នុងផ្លូវនៃសេចក្តីមេត្តា ឧទាហរណ៍* Pried Eppsteiner (Berkeley: Parallax, *១៩៨៥), ៧៨ ។*

ជាមួយការអានជាលើកដំបូង ប្រហែលជាលេចឡើងដូចជា មានភាពដូចគ្នាបន្តិចរវាងគោលដៅអភិវឌ្ឍន៍របស់គ្រីស្តបរិស័ទ និងអង្គការអ្នកកាន់ព្រះពុទ្ធសាសនា ។ ទោះបីយ៉ាងណាក៏ដោយ ការរៀបចំជាថ្មីនៃបញ្ជីទាំងពីរនេះ បង្ហាញឲ្យឃើញពីសារៈសំខាន់ដូចគ្នា ។

| គោលដៅរបស់គ្រីស្តបរិស័ទ | គោលដៅរបស់ពុទ្ធបរិស័ទ |
|---|---|
| ១- ការផ្លាស់ប្តូរចេញពីរបៀបនៃការរំលោភ និងការចង់ផ្តល់ប្រយោជន៍ផ្ទាល់ខ្លួនដល់គ្នាទៅវិញទៅមកនៅក្នុងសហគមន៍ ។ | ១- ផ្តល់ឲ្យម្នាក់ៗនូវសេរីភាពដែលមានលក្ខខ័ណ្ឌតែមួយគត់ គឺសេរីភាព និងកិត្តិយសរបស់អ្នកដទៃ ដើម្បីអភិវឌ្ឍការទុកចិត្តនៃការទទួលខុសត្រូវខ្លួនឯង ។ |
| ២- ផ្លាស់ប្តូរអ្នកនិយមជឿលើព្រេងវាសនាដែលធ្វើឲ្យទប់ស្កាត់ដល់សេចក្តីសង្ឃឹមដល់អ្នកដែលនិយមចូលចិត្តធ្វើការ ។ | ២- មានការគិតគូរជាដំបូង និងជាមុនគេបំផុតជាមួយសម្ភារៈ និងលក្ខខ័ណ្ឌសង្គមសំរាប់ការអភិវឌ្ឍន៍ផ្ទាល់ខ្លួន ។ |
| ៣- ផ្លាស់ប្តូររចនាសម្ព័ន្ធសង្គមដែលមានការគាបសង្កត់មកពីអ្នកដែលមានបុណ្យសក្តិ ដោយផ្តល់នូវឱកាសដល់មនុស្សទាំងអស់រួមបញ្ចូលទាំងអ្នកដែលគ្មានផលប្រយោជន៍ដល់សង្គម ផងដែរ ។ | ៣- ជួយប្រជាជនឲ្យឈ្នះអំនួតរបស់ខ្លួនដែលធ្លាប់ចង់ឲ្យមានអ្នកនៅក្រោមបង្គាប់របស់ខ្លួន ឬការជញ្ជក់យកផលប្រយោជន៍អ្នកដទៃ ការឲ្យតម្លៃខ្លួនឯងខ្ពស់ពេក និងបង្កើតឲ្យមានខ្ពស់ជាង/ទាបជាងរវាងគ្នានឹងគ្នា ។ |
| ៤- ផ្លាស់ប្តូរគំនិតដែលបំរើការអាក្រក់ និងគ្រោះថ្នាក់ធម្មជាតិដល់ប្រព័ន្ធធ្វើការដែលបានទុកជាភស្តុតាងរួចមកហើយ ទោះជាសម័យដើមឬសម័យទំនើប ។ | |
| ៥- បង្កើននូវគុណភាពជីវិតជាមួយការណែនាំអំពីបច្ចេកទេសត្រឹមត្រូវ ។ | ៥- ផ្តត់ផ្តង់បច្ចេកវិជ្ជាលំដាប់កណ្តាលដែលធ្វើឲ្យកើតសម្ភារៈល្អគ្រប់គ្រាន់នៅពេលដែលអាចរក្សាបាននូវភាពចុះសំរុងគ្នាតែមួយជាមួយបរិស្ថាន ។ |

គោលដៅទីមួយ ទាំងគ្រីស្ទបរិស័ទ និងពុទ្ធបរិស័ទបានថ្លែងថា នៅក្នុងការស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន យើងគួរតែស្ថិតនៅជាប់ក្នុងគំនិតនៃសេចក្តីត្រូវការរបស់អ្នកដទៃជានិច្ច ។ នៅក្នុងគោលដៅទីពីរ ទាំងគ្រីស្ទបរិស័ទ និងពុទ្ធបរិស័ទ សំដៅទៅលើសក្តានុពលសំរាប់ភាពរីកចំរើនរបស់មនុស្ស និងលក្ខខ័ណ្ឌនៃការផ្គត់ផ្គង់ដែលនាំមកឲ្យមនុស្សនូវសក្តានុពល ។ ទីបី ក្រុមទាំងពីរមានការស្អប់ខ្ពើមដល់ក្របខ័ណ្ឌ និងប្រព័ន្ធដែលបង្កើតការសង្កត់សង្កិន ការជញ្ជក់យកផលប្រយោជន៍អ្នកដទៃ ។ គោលដៅទីបួនរបស់លោក គ្រស គ្មានមតិអ្វីពីគំនិតពុទ្ធបរិស័ទមកប្រៀបនឹងគំនិតគ្រីស្ទបរិស័ទឡើយ ។ គោលដៅចុងក្រោយ គាំទ្រការអនុវត្តន៍ត្រឹមត្រូវនៃលំដាប់បច្ចេកវិជ្ជាថ្នាក់កណ្តាលដោយមិនគិតពីភាពក្រីក្រ ឬការនិយមប្រើប្រាស់របស់ថៅកៗឡើយ ។

ភាពខុសគ្នាដែលសំខាន់នៅក្នុងការអនុវត្តន៍ គឺហាក់បីដូចជាមានភាពច្បាស់លាស់ ។ គោលដៅរបស់គ្រីស្ទបរិស័ទបានស្នើថា ការផ្លាស់ប្តូរ គឺត្រូវបានចាប់ផ្តើមឡើងដោយភ្នាក់ងារមកពីប្រពៃណីខាងក្រៅ ។ ផ្ទុយទៅវិញ ការអនុវត្តន៍របស់ពុទ្ធបរិស័ទ គឺស្ថិតនៅលើមូលដ្ឋាននៃកម្លាំងផ្ទាល់ខ្លួនម្នាក់ៗ និងកិច្ចការខាងក្នុងរបស់គេ ។ នៅពេលដែលឯកត្តបុគ្គលមានការផ្លាស់ប្តូរ សហគមន៍ក៏មានការផ្លាស់ប្តូរដែរ ។

## គំនិតរបស់ពុទ្ធបរិស័ទចំពោះសង្គមគ្រីស្ទបរិស័ទ

ធ្វើការនៅក្នុងប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា យើងត្រូវតែយល់ថា តើពុទ្ធបរិស័ទទាំងនោះយល់អំពីគ្រីស្ទបរិស័ទយ៉ាងដូចម្តេចដែរ ។ ព្រះពុទ្ធសាសនា ជាសាសនាដែលគ្មានព្រះ[១៥] ផ្ទុយទៅវិញ ចំពោះសាសនាដែលមាន

[១៥] *"ព្រះជាម្ចាស់មិនពាក់ព័ន្ធទៅនឹងសាសនាឡើយ" ជាសង្ឃដីការបស់*

ព្រះគឺ សាសនាហិណ្ឌូ សាសនាអ៊ីស្លាម និងគ្រីស្ទសាសនា ។ ព្រះពុទ្ធយល់ថា ព្រះដែលគេបង្កើត និងព្រះដែលកើតឯងនោះ គឺខុស ។ ការដែលយើងដឹងពី "គោលការណ៍ដែលគ្មានព្រះ" នោះឯងជាលក្ខណៈគ្រឹះឲ្យយើងដឹងថា តើពុទ្ធបរិស័ទគិតពីគ្រីស្ទបរិស័ទ យ៉ាងដូចម្តេច ។

- អ្នកកាន់ព្រះពុទ្ធសាសនាជឿថា ប្រសិនបើគោលលទ្ធិណាដែលអាចប្រើបានដល់នរណាម្នាក់ នោះគឺវាសមទៅនឹងអ្នកនោះ ។ ប៉ុន្តែ ពិតប្រាកដណាស់ពុទ្ធបរិស័ទជឿថា ដើម្បីឲ្យគេអាចទទួលការត្រាស់ដឹងបាន គឺត្រូវបោះបង់ចោលគំនិតអ្នកជឿព្រះ ។ នៅក្នុងទស្សនៈនេះ វាជាការអនុញ្ញាតឲ្យគ្រីស្ទបរិស័ទជឿលើព្រះរបស់ខ្លួនផ្ទាល់ ប្រសិនបើគេរកឃើញថា មានប្រយោជន៍ ប៉ុន្តែប្រាកដណាស់ ការជឿនេះ នឹងត្រូវតែលះបង់ចោលក្នុងការចង់ទទួលការត្រាស់ដឹង ។
- ពុទ្ធបរិស័ទបានចាប់អារម្មណ៍នៅក្នុងគំនិតរបស់គ្រីស្ទបរិស័ទ ស្តីអំពីសេចក្តីស្រឡាញ់ដែលមិនគិតពីខ្លួនឯង ពីព្រោះការអាណិតអាសូរ គឺជាចំណុចកណ្តាលដល់គំនិតពួកគេអំពីក្រមសីលធម៌ ។ ទោះបីជាយ៉ាងណាក៏ដោយ គំនិតនៃពុទ្ធបរិស័ទអំពីសេចក្តីស្រឡាញ់ដែលមិនគិតពីខ្លួនឯង គ្មានមូលដ្ឋាននៅក្នុងភាពល្អប្រសើរ ឬក្នុងព្រះគ្រីស្ទ ឡើយ ។
- "សាសនាខុសឆ្គង" ឬ "អ្នកតំណាងសាសនា" នៅក្នុងគំនិតនៃអ្នកកាន់ព្រះពុទ្ធសាសនា គឺជាសាសនា ឬជាប្រព័ន្ធនៃការគិតដែលមិនដឹកនាំទៅរកការអភិវឌ្ឍន៍នៃជីវិតដែលមានសីលធម៌ល្អ ហើយទទួលនូវការទទួលខុសត្រូវផ្សេងៗពីសកម្មភាពរបស់ខ្លួន ។ នៅក្នុង

---

*ព្រះសង្ឃមួយអង្គទៅកាន់ រីចាដ ផែហ្វូ ហ្គូមប្រ៊ិច និងយោងទៅតាមព្រះពុទ្ធសាសនា* Tharavada: *ប្រវត្តិសាស្ត្រសង្គមពី* Ancient Benares to Modern Colombo (London: Routledge and Kegan Paul, *១៩៩៨*) ។

ទស្សនៈនៃអ្នកកាន់ព្រះពុទ្ធសាសនា ចំពោះគ្រីស្ទបរិស័ទដែលសង្កត់ទៅលើជីវិតដែលមានសីលធម៌ល្អ មិនធ្លាក់ចុះនៅក្នុងនិយមន័យនេះឡើយ ។

- "សាសនាដែលមិនពេញចិត្ត" គឺជាសាសនាមួយដែលជំរុញឲ្យមានការរីកចំរើននៃជីវិតសីលធម៌ល្អ ហើយទទួលការទទួលខុសត្រូវផ្សេងៗសំរាប់សកម្មភាពរបស់ខ្លួន ប៉ុន្តែមានជំនឿប្រឆាំងនឹងព្រះពុទ្ធសាសនា ដែលពួកគេមានជំនឿនៅក្នុងព្រះ ឬការបដិសេធការចាប់ជាតិជាថ្មី ។ គ្រីស្ទបរិស័ទភាគច្រើនធ្លាក់នៅក្នុងប្រភេទនេះ[១៦] ។

ព្រះពុទ្ធ បានពិពណ៌នាពីផ្លូវនៃការចងសម្ព័ន្ធជាមួយមនុស្សនៃសាសនាផ្សេងៗ ទុកដូចជាផ្នែកមួយនៃ "ការសាបព្រោះគំនិតដែលមិនគិតពីខ្លួនឯង ការអាណិតអាសូរ សេរីភាពពីការច្រណែន ភាពបរិសុទ្ធនៃគំនិត និងគោលបំណងនៃភាពធ្វើជាម្ចាស់លើខ្លួនឯង"[១៧] ។

## ការដាក់ស្នើនូវទេវសាស្ត្រនៅក្នុងប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាជីវចលនិយម

នៅក្នុងការព្យាយាមផ្តល់នូវគំរោងសំរាប់ការធ្វើទេវសាស្ត្រ ខ្ញុំសូមស្នើចំពោះការប្រុងប្រយ័ត្នពីរយ៉ាង ៖ ក្នុងការឆ្លើយតបដល់ព្រះពុទ្ធសាសនា យើងមិនត្រូវមានការប៉ុនប៉ងដល់ភាពប្រសើរបំផុតនោះទេ ។ យើងត្រូវតែមានទំនុកចិត្តបញ្ជាក់ពីបទពិសោធន៍របស់យើងជាមួយភាពប្រសើរបំផុតរបស់ព្រះជាម្ចាស់វិញ ។ យើងអះអាងថា ព្រះជាម្ចាស់ដែលយើងជឿ គឺជាព្រះអាទិករ ជាព្រះដែលពិតប្រាកដតែមួយគត់ ជាប្រភពនៃសេចក្តីពិត ហើយមាន

---

[១៦] *ប៉ូល ចេ គ្រីហ្វហ្វីតស៍, ជេ។, គ្រីស្តសាសនាក្នុងវង្វង់អ្នកកាន់សាសនាដទៃ (ម៉ារីកណុល, ញូយ៉ក: អ័របីស, ១៩៩២), ១៤៦*

[17] Ibid.

សេចក្តីស្រឡាញ់ដែលគ្មានលក្ខខ័ណ្ឌ និងគំរូពីភាពនៃការទុកចិត្តទាំងស្រុងបាន ។ សេចក្តីពិត និងភាពពិតប្រាកដរបស់យើង មិនមែនចេញមកពីវិទ្យាសាស្រ្ត ឬហេតុផលពីការគិតនោះទេ ប៉ុន្តែមកពីព្រះតែប៉ុណ្ណោះ ។

ទីពីរ យើងមិនត្រូវបញ្ចេញសកម្មភាពខ្លាំងក្លាហួសពេកចំពោះអំពើនៃក្រោយសម័យទំនើប ដោយក្លាយជាអ្នកផ្តាច់ការជាមួយអត្តចរិតថា យើងខ្ជាប់ជាប់ទៅក្នុងសេចក្តីពិតនោះឡើយ ។ នៅក្នុងការដែលបញ្ចេញសកម្មភាពទៅវិញទៅមកជាមួយអ្នកកាន់ព្រះពុទ្ធសាសនា យើងត្រូវតែរក្សាការបើកចំហទៅចំពោះការផ្លាស់ប្តូរនៃជីវិតរបស់យើង ។

ខ្ញុំចង់ស្នើថា ត្រូវតែមានការថ្លឹងថ្លែងរវាងជំនឿដែលមិនអាចរង្គើបាននៅក្នុងព្រះដែលគង់នៅឆ្ងាយ (Transcendent God) និងឋានៈជាអ្នកផ្តាច់ការនៃការប្រកាន់ភាពតឹងរឹងបំផុត ដែលមានចម្លើយទៅលើសំនួរនៃជីវិតគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។ ចំពោះអត្ថន័យនេះ មិនមែនគ្រប់ការទាំងអស់អាចចរចាគ្នាបាននោះទេ អ្វីដែលខ្ញុំមានជាមូលដ្ឋាន គឺទាក់ទងទៅចំពោះពិភពលោក ។ វាក៏មានអត្ថន័យដែរថា ខ្ញុំបើកចំហទៅចំពោះសេចក្តីពិតថ្មី និងការយល់ដឹងថ្មី ។ វាមានន័យថា ជីវិត គឺជាដំណើរការជាមួយបាវចនាមួយដូចតទៅនេះ "នៅពេលនេះខ្ញុំដឹងពីអ្វីដែលខ្ញុំជឿ ប៉ុន្តែអ្វីដែលខ្ញុំជឿនឹងមានការផ្លាស់ប្តូរនៅពេលដែលខ្ញុំបានទទួលពន្លឺ និងសេចក្តីពិតថ្មី" ។

**រូបអង្គនៃព្រះ**-តើទេវសាស្រ្តយ៉ាងដូចម្តេចទៅ ដែលមានប្រសិទ្ធភាព និងអាចពន្យល់បានដល់អ្នកកាន់ព្រះពុទ្ធសាសនាជីវចលនិយម? មានការជាច្រើនដែលអាចធ្វើបាន ខ្ញុំមានការចាប់អារម្មណ៍ដើម្បីប្រើទុកជាចំណុចចាប់ផ្តើមគំនិតដែលមនុស្សទាំងអស់ត្រូវបានបង្កើតឡើងក្នុងរូបកាយរបស់ព្រះអង្គ ។

ព្រះដែលជាអាទិករ បានបង្កើតមនុស្សឡើងក្នុងរូបអង្គរបស់ទ្រង់ ។ សេចក្តីពិតនេះដាក់ឲ្យមានសេចក្តីថ្លៃថ្នូរ និងសក្តានុពលដល់មនុស្សគ្រប់គ្នា។

ការដែលទទួលរូបអង្គនៃព្រះ បញ្ជាក់នូវភាពខាងវិញ្ញាណ និងសមត្ថភាព ដើម្បីគិតពិចារណា ។ ការចេះក៏មានបង្កប់ភាព បដិច្ចសមុប្បាទ និងការរួបរួម របស់មនុស្សទាំងអស់ ។ ជាមួយទស្សនៈនេះ យើងធ្វើទំនាក់ទំនងជាមួយ មនុស្សដោយមិនគិតពីដើមកំណើត ឬប្រពៃណីរបស់គេឡើយ ប៉ុន្តែយើង ធ្វើដោយមានការគោរព និងទៅតាមសេចក្តីសង្ឃឹមរបស់ពួកគេវិញ ។ យើង គោរព ដោយព្រោះពួកគេជារូបឆ្លុះរបស់ព្រះជាម្ចាស់ ហើយផ្តល់ការសង្ឃឹម ដោយព្រោះពួកគេគ្មានការអភិវឌ្ឍន៍នូវសក្តានុពល ដែលព្រះជាម្ចាស់ប្រទាន ឲ្យគេនៅពេលដែលព្រះអង្គបានបង្កើតពួកគេមក ។

តាមរយៈការមកចាប់កំណើត ព្រះយេស៊ូបានធ្វើការតុបតែងថ្មីនូវរូប អង្គនៃព្រះសំរាប់មនុស្សលោក ។ ព្រះយេស៊ូបានសំដែងពីព្រះជាម្ចាស់ទុក ដូចជាសេចក្តីពិត សេចក្តីអាណិតអាសូរ និងភាពទុកចិត្តជាទីបំផុត ។ ព្រះយេស៊ូបានអធិស្ឋានសូមឲ្យរាជ្យព្រះអង្គបានសំរេចនៅផែនដី ដូចនៅ ស្ថានសួគ៌ដែរ ។ នៅកន្លែងណាដែលមានលក្ខណសម្បត្តិរបស់ព្រះអង្គ (សេចក្តីពិត ការអាណិតអាសូរ ភាពទុកចិត្តជាទីបំផុត) គឺបានរកឃើញនៅក្នុង វង្វាស់យ៉ាងល្អដែលបានរកឃើញនគររបស់ព្រះ ។ នៅក្នុងសហគមន៍នេះ មនុស្សរស់នៅក្នុងភាពចុះសំរុងគ្នានៅក្នុងភាពទុកចិត្តគ្នា និងភាពបើកចំហ ចំពោះគ្នាទៅវិញទៅមក ។ នៅក្នុងសហគមន៍នេះ យុត្តិធម៌ និងការអាណិត អាសូរនឹងទទួលជ័យជំនះ ហើយអ្នកពិការ នឹងធ្វើឲ្យដើរបាន អ្នកខ្វាក់ នឹងផ្តល់ ពន្លឺឲ្យគេមើលឃើញ អ្នកជាប់ពន្ធនាគារ នឹងត្រូវដោះលែង ឯអ្នកដែលអស់ សង្ឃឹម នឹងត្រូវបានផ្តល់នូវសេចក្តីសង្ឃឹមឡើងវិញ។

នៅក្នុងប្រទេសកម្ពុជា មានភស្តុតាងជាក់ស្តែងដែលថា អង្ករអាច រក្សាទុកបានរហូតដល់ទៅ១២ខែ មិនមែនគ្រាន់តែរយៈពេល៧ខែតែប៉ុណ្ណោះ នៅពេលដែលអស់អ្នកដែលបានដាច់ជើងដោយសារគ្រាប់មីន គឺត្រូវបាន ជួយឲ្យដើរវិញបាន នៅពេលដែលមនុស្សរស់នៅក្រោមភាពអស់សង្ឃឹមនៃ

សេចក្ដីទ័លក្ររបស់គេ គឺឲ្យមានសេរីភាពចេញពីការរស់នៅដ៏លំបាកពីមួយថ្ងៃទៅមួយថ្ងៃនេះ ។ នៅពេលដែលអ្នកក្រអាចទទួលការខ្ចីប្រាក់ដោយគ្មានការចងការប្រាក់ នៅពេលដែលសេចក្ដីពិតមានជាទូទៅគ្រប់ទីកន្លែង ពេលដែលមនុស្សអាចរស់នៅជាមួយគ្នាក្នុងសន្តិភាព និងភាពចុះសំរុងគ្នាដែលស្ថិតនៅក្នុងការទុកចិត្តដ៏អព្យាក្រឹតមួយ និងមានការបញ្ឈប់ពីការអាណិតអាសូររវាងអ្នកជិតខាងនិងអ្នកជិតខាង ពេលដែលមនុស្សធ្វើការជាមួយគ្នាឲ្យចេញជាសកម្មភាពពិតនូវអ្វីដែលយើងមិនបានដឹងខ្លួនថា ព្រះបានផ្ដល់សក្ដានុពលដល់គ្រប់ទាំងមនុស្សទាំងអស់ ។ ដូច្នេះ មនុស្សដែលបានដើរក្នុងសេចក្ដីងងឹត នឹងឃើញពន្លឺ ។

ពន្លឺ គឺជាពន្លឺរបស់ព្រះជាម្ចាស់ ។ ព្រះយេស៊ូបាននាំពន្លឺនោះមកក្នុងពិភពលោកនេះ ។ យើងជាអ្នកនាំនូវពន្លឺនោះ គឺជាពន្លឺរបស់ព្រះយេស៊ូ ។ យើងស្វែងរកមធ្យោបាយដើម្បីនាំពន្លឺទៅកន្លែងងងឹត ។ នៅក្នុងការធ្វើដូច្នេះ យើងត្រូវដឹងថា របៀបដែលយើងធ្វើនោះ មានសារៈសំខាន់ជាងអ្វីដែលយើងធ្វើ ។ ក្នុងនាមជាអ្នកនាំពន្លឺ យើងឆ្លុះបញ្ចាំងអាកប្បកិរិយា និងអត្តចរិតរបសព្រះយេស៊ូ ។ នេះគឺជាការប្រសើរបំផុតក្នុងការសរុបឡើងវិញនៅក្នុងជំហរនៃអ្នកបំរើដែលត្រូវបានទទួលអំណាច ។

ព្រះយេស៊ូបានលើករឿងនេះឡើង នៅពេលដែល "ជម្លោះកើតមានឡើងក្នុងចំណោមពួកគេ ហាក់បីដូចជាម្នាក់ក្នុងពួកគេ បានតាំងខ្លួនឡើងធ្វើជាអ្នកធំជាងគេ ។ ប៉ុន្តែទ្រង់មានបន្ទូលទៅពួកគេថា "អស់ទាំងស្ដេចនៃសាសន៍ដទៃ គេតែងសោយរាជ្យលើបណ្ដារាស្ត្រ ហើយបណ្ដាជនហៅពួកអ្នកមានអំណាចលើគេ ថាជាអ្នកមានគុណដែរ ប៉ុន្តែមិនត្រូវឲ្យមានដូច្នោះក្នុងពួកអ្នករាល់គ្នាឡើយ ឯអ្នកណាដែលធំជាងគេក្នុងពួកអ្នករាល់គ្នា នោះត្រូវ

ប្រព្រឹត្តដូចជាតូចជាងគេវិញ ហើយអ្នកណាដែលនាំមុខគេ នោះដូចជាអ្នកបំរើដែរ... ប៉ុន្តែខ្ញុំនៅចំពោះអ្នករាល់គ្នា ទុកដូចជាអ្នកបំរើវិញ"[១៨] ។

ព្រះយេស៊ូយាងមកធ្វើជាអ្នកបំរើ ។ យើងបំរើដើម្បីនាំមនុស្សទៅនគររបស់ព្រះដែលស្ថិតនៅក្រោមអំណាចរបស់ព្រះគ្រីស្ត ។ យើងធ្វើយ៉ាងដូច្នេះបានដោយជំនឿ ហើយព្រះវិញ្ញាណរបស់ព្រះគ្រីស្ត គឺជាតំណាងពីព្រះតាមរយៈយើងនៅក្នុងសកម្មភាព និងពាក្យសំដីរបស់យើង ។ យើងកំពុងបំរើក្នុងនាមជាតំណាងរបស់ព្រះគ្រីស្ត ជាមួយប្រាជ្ញាដែលព្រះវិញ្ញាណរបស់ព្រះអង្គកំពុងធ្វើការ ដើម្បីស្ថាបនាច្បាប់របស់ព្រះជាម្ចាស់។ អំណាចដែលកំពុងតែធ្វើការ គឺជាអំណាចរបស់ព្រះវិញ្ញាណ មិនមែនជាអំណាចរបស់ខ្លួនយើងឡើយ ។ តួនាទីរបស់យើង គឺព្រោះគ្រាប់ពូជ ។ កន្លែងខ្លះនឹងបង្កើតផល ។ យើងមិនមែនជាអ្នកដែលទទួលខុសត្រូវចំពោះការលូតលាស់របស់គ្រាប់ពូជនោះទេ ប៉ុន្តែព្រះជាម្ចាស់ទេតើ ដែលជាអ្នកទទួលខុសត្រូវចំពោះការនេះ ។ យើងគ្រាន់តែជាអ្នកព្រោះពូជតែប៉ុណ្ណោះ ។

អត្តចរិតរបស់យើងនៅក្នុងព័ន្ធកិច្ច គឺជាការដឹងគុណមួយដល់ព្រះគុណដែលរកថ្លែងពុំបានរបស់ព្រះអង្គ ។ ហេតុដែលជំរុញចិត្តយើងឲ្យបំរើ គឺមិនមែនជាការបន្ធូរបន្ថយដល់កំហុសរបស់យើង ឬចំណេញដល់គុណសម្បត្តិរបស់យើងនោះទេ ប៉ុន្តែវាជាការអរព្រះគុណដល់ព្រះជាម្ចាស់ចំពោះអំណោយដែលរកថ្លែងពុំបាន ព្រោះវាជាលទ្ធផលដ៏ធម្មតាដែលគួរអរព្រះគុណ ។ បើធ្វើដូច្នេះបាន នោះយើងនឹងរកអំណរឃើញនៅក្នុងការបំរើ ។

ជនជាតិឥណ្ឌាម្នាក់ដែលបានទទួលរង្វាន់ណូបែលឈ្មោះ រ៉ាប៊ីនដ្រាណាត ថាគ័រ (Rabindranath Tagore) បានសរសេរថា ៖

---

[18] *លូកា ២២: ២៥-២៧* NRSV

"ខ្ញុំបានដេកលក់ ហើយយល់សប្តិថា ជីវិតគឺមានភាពត្រេកអរ
ខ្ញុំបានងើបឡើង ហើយរកឃើញថា ជីវិតគឺជាការបំរើ
ខ្ញុំបានបំរើ ហើយយល់ឃើញថា ការបំរើគឺសេចក្តីអំណរ ។"

## តើអង្គការ អឹមសុីសុី ខុសពី អង្គការលោកីយ៍ក្រៅរដ្ឋាភិបាលត្រង់ណា?

សំនួរពីភាពខុសគ្នារវាង "អង្គការគ្រីស្តបរិស័ទ" និង "អង្គការលោកីយ៍" កើតមានឡើងម្តងទៀតក្នុងការពិភាក្សានៅក្នុងរង្វង់អង្គការគ្រីស្តបរិស័ទ ។ មានអង្គការជាច្រើន ដែលបុគ្គលិកម្នាក់ៗមានចេតនាល្អចំពោះការងារ មានការគិតគូរយ៉ាងខ្លាំងដល់អ្នកដែលពួកគេបំរើ និងមានចំណង់ពិតប្រាកដដើម្បីធ្វើឲ្យកិច្ចការកាន់តែប្រសើរឡើងដល់អ្នកក្រីក្រ និងផ្តល់ឲ្យមានកិត្តិយសឈានមុខ ។ អ្នកស្ម័គ្រចិត្តរបស់អង្គការ អឹមសុីសុី ជួបឧបស័គ្គជាមួយនឹងសំនួរនេះ ហើយក្នុងការដែលយើងជឿដូច្នេះ គឺមិនគ្រប់គ្រាន់ដើម្បីឲ្យយើងក្លាយជាអ្នកបច្ចេកទេសដ៏ចំណានបានឡើយ ។ ដូច្នេះហើយ បានជាយើងស្វែងរកគ្រប់ទាំងមធ្យោបាយដើម្បីធ្វើសហប្រតិបត្តិការជីវិតខាងវិញ្ញាណរបស់យើងឲ្យចូលទៅក្នុងជីវិតប្រចាំថ្ងៃ ពេលដែលយើងរស់នៅ និងធ្វើការជាមួយមនុស្សដែលមានប្រពៃណី ឬគតិលោកខុសគ្នា ។

ដូចដែលយើងធ្វើការនៅក្នុងប្រពៃណីអ្នកកាន់ពុទ្ធសាសនាជីវចលនិយម គឺយើងត្រូវការបង្គោលដឹកនាំដើម្បីជួយចង្អុលប្រាប់យើងអំពីមធ្យោបាយនៃការងារដែលអាចសហប្រតិបត្តិការទៅភាពខាងវិញ្ញាណនៅក្នុងកិច្ចការងាររបស់យើង ប៉ុន្តែមានការគោរពដល់ប្រពៃណីរបស់អ្នកនៅក្នុងស្រុក ។ សេចក្តីថ្លែងដូចតទៅនេះគឺជាគំរូខ្លះៗដល់យើង ៖

- សន្មតថាអ្នកកាន់ពុទ្ធសាសនាជីវចលនិយម មានសកម្មភាពជីវិតខាងវិញ្ញាណ ដែលមានផលប្រយោជន៍ចាំបាច់ដល់ការបង្កើតឲ្យមានគតិលោករបស់គេ

- ក្លាយទៅជាសិស្សខាងវិញ្ញាណនៃមនុស្ស និងប្រពៃណី
- សន្មតថា ទំនាក់ទំនងដែលមានលក្ខណៈពេញលេញ នឹងមិនត្រូវកើតឡើងបានទេ លុះត្រាតែមានការពិចារណានូវទំហំខាងវិញ្ញាណជាមុនសិន
- សន្មតថា ទំហំខាងវិញ្ញាណត្រូវតែជាផ្នែកមួយនៃដំណើរការអភិវឌ្ឍន៍
- សម្លឹងរក "ពិធីបុណ្យ"[១៩]
- ប្រើពិធីបុណ្យ ដើម្បីសហប្រតិបត្តិការទំហំខាងវិញ្ញាណនៅក្នុងមធ្យោបាយដែលធ្វើឲ្យមានការយល់ដឹងទាំងពីរ ទាំងខាងអ្នកកាន់ពុទ្ធសាសនាជីវចលនិយម និងគ្រីស្ទបរិស័ទ
- ស្វែងរកមធ្យោបាយដើម្បីឲ្យមនុស្សគេបានដឹងពីគំរូនៃការយោងរបស់យើង គឺមកពីសេចក្តីបង្រៀនរបស់ព្រះយេស៊ូ
- ជៀសវាងជម្លោះ ត្រូវសំរាកដើម្បីអនុញ្ញាតឲ្យព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ធ្វើការ
- សង្ឃឹមថានឹងមានការផ្លាស់ប្តូរនៅក្នុងដំណើរការនេះ
- នៅក្នុងការផ្លាស់ប្តូរគ្នានេះ ត្រូវចូលទៅដោយមានទំនាក់ទំនងយ៉ាងល្អ ជាជាងការប្រឈមមុខជាមួយគ្នា ។

នៅពេលដែលគតិលោក ឬការដាក់ជំនឿយ៉ាងជ្រៅទៅលើអ្វីមួយបញ្ចេញឲ្យឃើញ នោះពេលសមាធិ គឺពិតជាមាននៅរៀងរាល់ថ្ងៃនៃជីវិត ។ នេះគឺជាពេលដែលមូលដ្ឋាននៃការសន្មតត្រូវបានសាកល្បង ។ ក្នុងនាមជា

---

[១៩] ចន ស្ទូវើ, *កាពគ្រប់ជ្រុងជ្រោយនៃអត្ថបទព្រះគម្ពីរ: ទំនាក់ទំនងរវាងព្រះជាម្ចាស់ មនុស្ស និងការប្រព្រឹត្តិរបស់មនុស្ស, សិក្ខាសាលាមួយដែលមានការទាក់ទាញ* (Brwood, Victoria: *អង្គការទស្សនៈពិភពលោក អូស្ត្រាលី*, ១៩៩៨), ១២៥ ។

អ្នកអភិវឌ្ឍដែលចាកចេញពីប្រពៃណីរបស់ខ្លួន យើងនាំមកដល់ប្រពៃណីថ្មីនៃភាពខាងវិញ្ញាណមួយ និងគតិលោកនៅក្នុងការដែលយើងបង្កើតទំនាក់ទំនង ធ្វើការសំរេចចិត្ត និងការកំណត់អាទិភាពផ្សេងៗ ។ ហេតុការណ៍នេះកើតឡើង ឬមិនកើតឡើង អាស្រ័យលើយើងជាអ្នកយល់ច្បាស់អំពីការនេះដែរ ។ យើងត្រូវតែសន្មតថា អ្នកកាន់ព្រះពុទ្ធសាសនាជីវចលនិយមមានគំរូនៃការបំរើដល់ខ្លួនរបស់គាត់ក្នុងមធ្យោបាយដូចគ្នា ។ នៅពេលដែលយើងចាប់ផ្តើមទទួលស្គាល់ពីសារៈសំខាន់នៃគតិលោករបស់យើង យើងនឹងយល់ដឹងពីសេចក្តីត្រូវការ ដើម្បីទទួលស្គាល់ភាពខាងវិញ្ញាណក្នុងចំណោមមនុស្សដែលយើងរស់នៅជាមួយ ។

នៅក្នុងកិច្ចការងាររាល់ថ្ងៃរបស់យើង ក្នុងនាមជាអ្នកអភិវឌ្ឍគ្រីស្តបរិស័ទ យើងត្រូវតែមានការដឹងខ្លួនថែមទៀតនូវកន្លែងណាដែលព្រះជាម្ចាស់ទ្រង់ធ្វើការ ។ នៅពេលដែលយើងធ្វើដូច្នេះ យើងនឹងក្លាយទៅជាអ្នកដែលរវាសដឹងដល់កន្លែងផ្សេងៗទាំងប៉ុន្មាន ដែលភាពខាងវិញ្ញាណនៃអ្នកកាន់ពុទ្ធសាសនាជីវចលនិយមមានគ្រោងសំនួរ និងដំណោះស្រាយចំពោះបញ្ហាអភិវឌ្ឍន៍ ។ មានពេលសមាធិដែលផ្តល់ពេលវេលាឲ្យយើងមានទំនាក់ទំនងភាពខាងវិញ្ញាណរបស់ខ្លួនយើង ។ យើងទំនាក់ទំនងជំរៅនៃជំនឿរបស់យើង ហើយយើងស្វែងឲ្យយល់ដឹងនូវជំរៅជំនឿស្រដៀងគ្នារបស់អ្នកកាន់ពុទ្ធសាសនាជីវចលនិយមផងដែរ ។ យើងធ្វើយ៉ាងដូច្នេះដោយសេចក្តីគោរព និងសុភាព ជាជាងធ្វើដោយភាពវាយប្រហារ "សេចក្តីពិត" នៃដំណឹងល្អចំពោះអ្នកដទៃ[២០] ។

---

[20] *បណ្ឌិត ណាទថាឆាយ និងបណ្ឌិត អ៊ូបុនកំន ជាប្តីប្រពន្ធនឹងគ្នា ពួកគាត់ជា គ្រីស្តបរិស័ទថៃ ហើយអតីតជាព្រះសង្ឃ និងដូនជីនៃព្រះពុទ្ធសាសនា បានសរសេរ* doctoral theses *ស្តីពីការទទួលយកដែលជាគុណតម្លៃក្នុងការប្រាស្រ័យទាក់ទងនៃជំនឿ ។ ដំណោះស្រាយបែបនេះអាស្រ័យលើ គតិលោក*

ក្នុងរឿងដែលភ្ជាប់មកជាមួយនេះ ខ្ញុំសូមធ្វើការសរុបពិពណ៌នាពីគំនិតនេះ ។ មានក្រុមជីកអណ្តូងមួយក្រុម បានសំរេចចិត្តដើម្បីជីកអណ្តូងនៅកន្លែងមួយ ។ ពួកគេក៏បានយកដីមកធ្វើជាគំរូដើម្បីត្រួតពិនិត្យជាមួយតារាងរបស់គេ ដោយប្រើបច្ចេកវិទ្យាទំនើបដើម្បីធ្វើការសំរេចចិត្ត ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកភូមិនៅទីនោះដឹងថា វាមានតែគ្រូទេដែលយល់អំពីការទាំងនោះ ហើយធ្វើការសំរេចចិត្តបាន ។ សំរាប់ពួកគេ នេះគឺជាពេលសមាធិគឺជាពេលដែលជំនឿរបស់គេធ្វើឡើងដោយមានការសំរេចចិត្តដ៏ល្អិតល្អន់ ។ អ្នកបច្ចេកទេសពិនិត្យដី និងតារាងវិភាគ គឺក្លាយទៅជាមធ្យោបាយចម្លែកនៃការប្រើសិល្ប៍ ដើម្បីធ្វើការសំរេចចិត្តទៅវិញ ។ លោក ស្ទួវត (Steward) និយាយថា ៖

> អ្នកភូមិនោះយល់ខុសក្នុងការមើលឃើញការជ្រើសរើសវិធីនេះទុកដូចជាការប្រើសិល្ប៍ ប៉ុន្តែពួកគេមានភាពត្រឹមត្រូវក្នុងការមើលវាទុកដូចជាពេលសមាធិទៅវិញ ។ វាប្រហែលជាជំនឿឆ្វេង ក៏ប៉ុន្តែយើងមិនគួរបំភ្លេចទេថា ភាពអស្ចារ្យទាំងឡាយនៅជុំវិញខ្លួនយើង ហើយនៅក្នុងសកម្មភាពទាំងប៉ុន្មានដែលយើងធ្វើគ្រប់ពេលទាំងអស់ផង ។[២១]
> (ឯកសារ ភ្ជាប់ទី១)

---

*និងវប្បធម៌ក្នុងការទំនាក់ទំនងរបស់ជនជាតិថៃ ។ ពួកគាត់កំពុងតែខិតខំប្រឹងប្រែងដើម្បីពង្រីងចំណេះដឹងដល់អ្នកតំណាងគ្រីស្ទបរិស័ទក្នុងប្រទេសថៃ ។ ក្នុងគំនិតរបស់ពួកគាត់ ដំណោះស្រាយចំពោះមុខក្នុងការទំនាក់ទំនងដ៏ណើងល្អ គឺអាចនាំមនុស្សឲ្យកាន់តែឃ្លាតឆ្ងាយឡើង ។ ដូច្នេះវិធីសាស្ត្រដែលស្មៀមស្ងាត់ ការទទួលយក និងវិធីសាស្ត្រដែលមានហេតុផល ដែលផ្តើមចេញពីសេចក្តីប្រាថ្នាចង់បានការរស់នៅដែលប្រកបទៅដោយភាពត្រឹមត្រូវ និងសុចរិតនឹងនាំមនុស្សឆ្ពោះទៅរកអាណាចក្រដ៏អស់កល្បរបស់ព្រះជាម្ចាស់ ។*

[21] *អ្នកបំរើ, ភាពគ្រប់ជ្រុងជ្រោយនៃព្រះគម្ពីរ ។*

ដោយចាប់យកពេលសមាធិ យើងជៀសវាងហេតុផលដែលជាលោកីយ៍ ហើយផ្តល់នូវការទទួលស្គាល់ដល់ភាពអស្ចារ្យលើសពីធម្មជាតិ ។ សេចក្តីត្រូវការនេះ មិនអាចសំរេចបាននៅក្នុងរបៀបធ្វើឲ្យមានភាពអាក់អន់ចិត្តនោះឡើយ ។ ការចាប់ផ្តើមដ៏សាមញ្ញមួយជាមួយបញ្ហា (ការរកកន្លែងប្រសើរដើម្បីជីកអណ្តូង) ហើយផ្តល់នូវការទទួលស្គាល់ដល់ព្រះអាទិករដែលបានបង្កើតពិភពលោកដែលមានសណ្តាប់ធ្នាប់ ហើយអនុញ្ញាតឲ្យយើងយល់ដឹងខ្លះៗនូវភាពអាថ៌កំបាំងរបស់ធម្មជាតិ ។

## សរុបសេចក្តី

មានបញ្ហាជាច្រើនពាក់ព័ន្ធទៅនឹងពួកលោកខាងលិច ដែលចូលមក "អភិវឌ្ឍ" ប្រទេសដែលមិនទាន់អភិវឌ្ឍ ។ ចេតនាល្អតែមួយគត់ នឹងមិនអាចឲ្យជៀសផុតពីគ្រោះថ្នាក់បានឡើយ ។ ភាពឆាប់ដឹងខ្លួន ការបន្ទាបខ្លួន និងភាពស្និទ្ធស្នាលជាមួយប្រជាជនដែលរស់ក្នុងប្រពៃណីថ្មី គឺជាការចាំបាច់ ។ នៅក្នុងការប្រាស្រ័យទាក់ទងនេះ អ្នកដែលមកថ្មីត្រូវការមកស្វែងយល់ពីគតិលោក និងភាពខាងវិញ្ញាណរបស់មនុស្ស ។ ភាពខាងវិញ្ញាណ គឺជាផ្នែកសំខាន់មួយនៃការយល់ដឹង ។ ការបដិសេធភាពខាងវិញ្ញាណរបស់ខ្លួនឯង និងមនុស្សដែលយើងត្រូវបំរើ គឺជាការធ្វើឲ្យយើងមានរូបភាពមិនពេញលេញ ហើយកម្មវិធីអភិវឌ្ឍន៍ទាំងអស់នឹងលំអៀងទៅរកភាពសើៗ ដែលមិនអាចស្ថិតស្ថេរបានឡើយ ។ ភ្នាក់ងារអភិវឌ្ឍ "លោកីយ៍" ភាគច្រើនទទួលស្គាល់សារៈសំខាន់នៃការរួមបញ្ចូលសង្គមមជ្ឈដ្ឋានគតិលោកនៅក្នុងភាពទំនាក់ទំនងរបស់ពួកគេ ។

ទោះបីជាយ៉ាងណាក៏ដោយ អ្នកធ្វើការអភិវឌ្ឍន៍គ្រីស្តបរិស័ទភាគច្រើនមានការយកចិត្តទុកដាក់ជាទីបំផុតចំពោះសេចក្តីបង្រៀនរបស់ព្រះយេស៊ូនៅក្នុងភាពជាព្រះ និងក្នុងទំនាក់ទំនងមនុស្សទុកដូចជាមូលដ្ឋានសំរាប់ខាង

វិញ្ញាណរបស់ពួកគេ ។ អ្នកធ្វើការអភិវឌ្ឍន៍ទាំងអស់នេះទទួលស្គាល់ទំហំខាងវិញ្ញាណនៃការចែកចាយទៅវិញទៅមករវាងអ្នកអភិវឌ្ឍ និងអ្នកដែលទទួលការអភិវឌ្ឍន៍ ។ យើងចាប់ផ្ដើមកន្លែងណាដែលគេរស់នៅ និងគតិលោករបស់គេ ។ ការនេះនឹងរួមបញ្ចូលសេចក្ដីពន្យល់របស់គេអំពីវិញ្ញាណអាក្រក់ និងហេតុអ្វីបានជាការអាក្រក់កើតឡើង ។ យើងសន្ទនា និងចូលឲ្យជ្រៅទៅដល់ការព្យាយាមឲ្យយល់ពីគតិលោករបស់ពួកគេ ។

យើងធ្វើយ៉ាងដូច្នេះ ទុកដូចជាសិស្ស និងគ្រូ ដោយមានការបន្ទាបខ្លួន គោរព និងដោយទំនុកចិត្តថា យើងមានរាជសារដែលពេញដោយសក្ដានុភាព ដើម្បីបង្កើតឲ្យមានជីវិតប្រសើរឡើងដល់អ្នកដែលទទួលការអភិវឌ្ឍន៍ ។ ការធ្វើ និងជំហរនៃអ្នកធ្វើការអភិវឌ្ឍន៍គ្រីស្ទបរិស័ទ គឺមានអត្តចរិតប្រសើរ ដោយមានភាពជាអ្នកដឹកនាំបែបបំរើ ។ អ្នកដែលទទួលការអភិវឌ្ឍន៍នឹងមើលមកយើងដោយសេចក្ដីសង្ឃឹម ទុកដូចជាអ្នកដែលមានជំនាញទៅលើកន្លែងធ្វើការរបស់គេ ។ សេចក្ដីសង្ឃឹមនេះ នឹងបង្កើតនូវឱកាសដើម្បីភ្ជាប់ទំនាក់ទំនងទៅនឹងភាពខាងវិញ្ញាណរបស់ខ្លួនយើង ។

អ្នកធ្វើការអភិវឌ្ឍន៍គ្រីស្ទបរិស័ទស្វែងរកការផ្លាស់ប្ដូរជំនឿ និងអត្តចរិតទាំងឡាយណាដែលធ្វើឲ្យផ្ដាច់នូវកម្លាំង ព្រមទាំងធ្វើឲ្យអ្នកដែលត្រូវអភិវឌ្ឍក្លាយជាទាសករ ។ ឧទាហរណ៍ សេចក្ដីបង្រៀនពីការរលាកក្រពះបណ្ដាលមកពីមេរោគបាក់តេរី គឺជាការបើកទ្វារមួយដល់សេចក្ដីបង្រៀនអំពីតម្លៃអនាម័យដែលយើងគួរទប់ស្កាត់ ។ កត្តាដែលធ្វើឲ្យទន់ខ្សោយនូវគតិលោករបស់ពួកគេ នឹងត្រូវតែមានការផ្លាស់ប្ដូរ ។ ការអភិវឌ្ឍន៍ដែលជះឥទ្ធិពលយូរអង្វែង គឺអាចទទួលលទ្ធផលបាននៅពេលដែលមានការផ្លាស់ប្ដូរជំនឿ និងតម្លៃ ។ មនុស្សដែលបានទទួលការផ្លាស់ប្ដូរនឹងមានតម្លៃផ្ដល់ផ្ដង់ដល់សុខភាពរស់នៅក្នុងសហគមន៍ ។ យើងបានឃើញម្ដងហើយម្ដង

ទៀតថា កម្មវិធីអភិវឌ្ឍន៍ដែលគ្មានការផ្លាស់ប្តូរនេះនឹងស្លាប់មួយរំពេច នៅពេលដែលភ្នាក់ងារអង្គការនេះចាកចេញបាត់ទៅ ។

បន្ទាប់មកអ្នកស្តាប់ ត្រូវទទួលយកឲ្យបានច្បាស់នូវអ្វីដែលអ្នកនិយាយបានបញ្ជូនចេញទៅ ។ ប៉ុន្តែ ប្រសិនបើមួយរំពេចនោះ មានសម្លេងមករំខាន ឬអារម្មណ៍របស់អ្នកស្តាប់រវើរវាយ គាត់អាចបាត់បង់នូវអ្វីដែលគេបាននិយាយ ។ អ្នកនិយាយ ប្រហែលនិយាយថា "ប្រាំពីរ" ប៉ុន្តែអ្នកស្តាប់អាចឮថា "មួយពីរ" ឬ "មកពី" ឬ "អំពី" ក៏ថាបាន ។ ទោះបីជាបានឮពាក្យត្រឹមត្រូវក៏ដោយ ក៏អ្នកស្តាប់អាចកំណត់ជាន័យផ្សេងបានដែរ ។ ប្រសិនបើខ្ញុំនិយាយថា "ពណ៌ខៀវ" តើលោកអ្នកមើលឃើញអ្វី? ខៀវស្លេកដូចជាផ្ទៃមេឃនៅតាមបណ្តោយជើងមេឃ? ខៀវជាំ? ខៀវចាស់? ខៀវខ្ចី? តើពាក្យថា "ស្រឡាញ់" ឬ "សប្បុរស" ជាអរូបនាម មានន័យដូចគ្នាដល់គ្រប់មនុស្សទាំងអស់ ដែរឬទេ?

យើងអាចធ្វើតារាងសន្ទនានៅក្នុងពាក្យមួយតាមមធ្យោបាយ ដូចខាងក្រោមនេះ៖

ប្រភព                                                  គោលដៅ

១ ⇨ ២ ⇨ ៣ ⇨ ៤ ⇨ ៥ ⇨ ៦

⇧ ⇧ ⇧ ⇧ ⇧

| សម្លេង |
|---|

| | |
|---|---|
| ១- អ្នកជ្រើសរើស | ៤- អ្នកទទួល |
| ២- អ្នកថ្លែងចេញ | ៥- អ្នកបកស្រាយ |
| ៣- អ្នកបញ្ជូន | ៦- អ្នកអភិវឌ្ឍន៍ |

ការបកប្រែលំបាកជាងនេះទៅទៀត ពីព្រោះវាតម្រូវយ៉ាងហោចណាស់ឲ្យមានពីរចំណុចនៅក្នុងដំណើរការទាំងអស់នេះ ។ អ្នកបកប្រែព្យអ្វីដែលបាននិយាយនៅក្នុងភាសាទីមួយ ហើយធ្វើជាអ្នកកំណត់ទិសដៅ ។ បន្ទាប់មក គាត់គឺជាប្រភពដើមដល់ភាសាទីពីរ ។ តាមពិតទៅមានហេតុការណ៍ជាច្រើន ដែលរំខានដល់ "សម្លេង" ធ្វើអោយមិនច្បាស់ និងមានការយល់ច្រឡំទៅក្នុងដំណើរការនេះ ។

ដូច្នេះមនុស្សខ្លះមានការភ័យខ្លាច ថាគ្មានអ្នកណាអាចបកប្រែត្រឹមត្រូវនោះទេ ។ ចំណែកឯអ្នកបកប្រែព្រះគម្ពីរខ្លះវិញ តម្រូវឲ្យបកប្រែអត្ថបទព្រះគម្ពីរឲ្យបានត្រឹមត្រូវ ពីព្រោះភាសារបស់អ្នកអានប្រហែលជាមានច្បាប់វេយ្យាករណ៍របស់គេដែលព្រះគម្ពីរគ្មាន ។ គ្មានការបកប្រែណាមួយដែលអាចរក្សាអត្ថន័យបានឥតខ្ចោះដូចអត្ថបទដើមឡើយ ។ គូម៉ារ៉ាជីវ៉ា (Kumarajiva) នៅក្នុងសតវត្សទី៥ ជាអ្នកបកប្រែគម្ពីរព្រះពុទ្ធសាសនាទៅជាភាសាចិន បាននិយាយថា ៖

> ...ការបកប្រែប្រៀបដូចជាការទំពារអាហារដែលត្រូវយកទៅបញ្ចុកអ្នកដទៃ ។ អ្នកណាដែលគ្មានសមត្ថភាពទំពារអាហារដោយខ្លួនឯង ត្រូវតែកាត់ចិត្តទទួលទានអាហារដែលគេទំពារឲ្យស្រាប់នោះទៅ ។ ទោះជាអាហារដែលគេទំពារឲ្យនោះហាក់ដូចជាមានរសជាតិអន់ជាងអាហារមិនទាន់ទំពារក្តី ក៏អ្នកនោះត្រូវតែទ្រាំលេបចូលពោះដែរ ព្រោះវាគ្រាន់បើជាងអត់ ។

ប៉ុន្តែ ទោះបីជាពិបាកក្នុងការធ្វើឲ្យបានល្អយ៉ាងណាក៏ដោយ ក៏គ្រីស្ទបរិស័ទត្រូវតែបកប្រែ ។ ប្រសិនបើក្រុមជំនុំត្រូវបង្កើតសិស្សនៅគ្រប់ជាតិសាសន៍ដូចដែលព្រះយេស៊ូបានបញ្ជា ហើយប្រសិនបើតំណាងគ្រប់ភាសា

ទាំងអស់មានភាពរីករាយនៅក្នុងនគរព្រះ ព្រះបន្ទូលដែលទ្រង់បានផ្ដល់ឲ្យតាមរយៈភាសាហេព្រើរ អារាមិក និងក្រិក ត្រូវតែបកប្រែទៅជាភាសាខ្មែរ អង់ហ្គ្លេរ និង អង់គ្លេស ។

## មូលដ្ឋាននៃការបកប្រែ

ប៉ុន្តែ តើយើងអាចធ្វើឲ្យការនោះកើតឡើងយ៉ាងណាបាន? តើមធ្យោបាយណាមួយ ដែលធ្វើឲ្យការបកប្រែអាចឆ្លុះបញ្ចាំងនូវភាពដើមរបស់វាបាន? តើច្បាប់អ្វីដែលគ្រប់គ្រងដំណើរការនេះ?

ការបកប្រែទាំងអស់ ត្រូវតែនាំទៅរកភាសារបស់អ្នកទទួលតាមន័យត្រង់ស្របតាមអត្ថរូបដើមរបស់វា ។ ការបកប្រែភាសាអង់គ្លេស ត្រូវតែបង្កើតឡើងនៅក្នុងគំនិតខ្ញុំឲ្យដូចជារូបភាពដដែលនៅក្នុងគំនិតរបស់លោកអ្នកនៅពេលដែលលោកអ្នកអានភាសាដើមរបស់ខ្មែរ ។ ដូច្នេះនៅពេលដែលយើងនិយាយថា ការបកប្រែមួយជាការបកប្រែបែបរក្សាអត្ថរូប គឺយើងមិនសំដៅទៅលើអត្ថន័យនោះទេ ព្រោះគ្រប់ការបកប្រែទាំងអស់ត្រូវនាំទៅរកអត្ថន័យនៃពាក្យនិមួយៗនៅក្នុងឯកសារដើមរបស់វា ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការបកប្រែទាំងអស់មិនអាចបញ្ជូននូវទំរង់នៃឯកសារទីមួយដល់ឯកសារទីពីរបានដូចដើមសុទ្ធសាធនោះទេ ។ មានន័យថា លំដាប់នៃពាក្យនិងវេយ្យាករណ៍ប្រហែលជាខុសគ្នា ។ តាមពិតទៅ វាតែងតែមានភាពខុសគ្នាជានិច្ច ។

មានរបៀបមូលដ្ឋានពីរក្នុងការបកប្រែ ។ របៀបទីមួយ គឺការបកប្រែបែបរក្សាអត្ថរូប (ឈ្មោះមិនសូវល្អដូចបានប្រាប់ខាងលើរួចមកហើយថាគ្រប់ការបកប្រែដែលល្អ គួរតែស្វែងរកអត្ថន័យរបស់អត្ថរូប) គឺស្វែងរកដើម្បីរក្សាទំរង់ដើមនៃប្រភពភាសារបស់គេ ។ របៀបទីពីរ ឬការបកប្រែបែបសំនួនវោហារ គឺជាការប៉ុនប៉ងស្វែងរកអត្ថន័យរបស់ភាសាដើមមកបកស្រាយក្នុង

ទំរង់ភាសាដែលអ្នកស្តាប់អាចយល់បានដោយមិនគិតថា ទំរង់នោះស្រប ឬមិនស្របទៅនឹងទំរង់នៃឯកសារដើមឡើយ ។ ម្យ៉ាងវិញទៀត នៅក្នុងការបកប្រែតាមសំនួនវោហារ ប្រហែលជាមានការផ្លាស់ប្តូរជំរើសនៃពាក្យ ឬលំដាប់លំដោយនៃពាក្យខ្លះ ដើម្បីធ្វើឲ្យអត្ថបទនោះដូចភាសាកំណើតរបស់អ្នកអាន ។ ដើម្បីបង្កើតឲ្យមានឥទ្ធិពលខ្លាំង ការបកប្រែមិនគួរមានលក្ខណៈដូចជាការបកប្រែឡើយ ប៉ុន្តែគួរមានលក្ខណៈធម្មតាដូចភាសាកំណើតរបស់អ្នកអានផ្ទាល់ច្រើនជាង ។

បញ្ហាមួយក្នុងការបកប្រែបែបរក្សាអត្ថរូបគឺថា ទោះជាវាមានភាពត្រឹមត្រូវដោយចម្លងពាក្យ និងលំដាប់ពាក្យចំៗពីភាសាដើមក៏ដោយ ក៏ការបកប្រែអាចនាំទៅរកភាពច្រលំ ឬគ្មានន័យចំពោះអ្នកអានផងដែរ ។ គ្រប់ការបកប្រែណាដែលអ្នកបកប្រែចង់ឲ្យអ្នកអានយល់ ត្រូវធ្វើតាមច្បាប់នៃការបកប្រែ គឺមិនមែនគ្រាន់តែប្រែពាក្យមួយម៉ាត់ម្តងៗនោះទេ ប៉ុន្តែត្រូវប្រែអត្ថន័យមួយគំនិតម្តងៗវិញ ។

ជាច្រើនសតវត្សកន្លងទៅហើយ បុរសម្នាក់ឈ្មោះ អគីឡា (Aquila) បានបកប្រែព្រះគម្ពីរសញ្ញាចាស់ពីភាសាហេព្រើរទៅជាភាសាក្រិក ។ ដូចដែលគាត់បានធ្វើយ៉ាងដូច្នេះ គាត់ព្យាយាមចម្លងគ្រប់ទាំងពាក្យលំអិតពីភាសាដើមមកក្នុងភាសាបកប្រែរបស់គាត់ ។ លទ្ធផលដែលទទួលបានគឺ ការបកប្រែរបស់គាត់ជាការបកប្រែពាក្យទល់នឹងពាក្យមកពីអត្ថបទហេព្រើរ ប៉ុន្តែអ្នកអានជនជាតិក្រិកពិបាកយល់ជាខ្លាំង ។ ដោយការបកប្រែមិនត្រូវធ្វើឡើងតាមពាក្យមួយម៉ាត់ម្តងៗ តែត្រូវគិតតាមអត្ថន័យវិញនោះ នាំឲ្យការបកប្រែរបស់លោក អគីឡា ហាក់ដូចជាមិនបានផលអ្វីសោះ ។ ការបកប្រែបែបរក្សាទំរង់ដើមខ្លាំងពេក ដូចជាការបកប្រែរបស់លោក អគីឡា ធ្វើឲ្យអ្នកអានមិនយល់ ហើយធ្វើឲ្យការងារនោះមានភាពចំឡែក និងមិនប្រាស្រ័យទាក់ទងបានជាមួយអ្នកអាន ។

ដូច្នេះការបកប្រែបែបរក្សាអត្ថរូបខ្លាំងពេកនោះ មិនអាចឲ្យគេទទួលបានឡើយ ពីព្រោះវានាំមកនូវអត្ថន័យដ៏តិចតួចបំផុត ឬពីព្រោះវាមានលក្ខណៈមិនរលូនដូចភាសារបស់អ្នកអាន ។ ម្យ៉ាងវិញទៀត វាក៏ជាការបរាជ័យមួយផងដែរដល់ការបកប្រែណាដែលប្រើសេរីភាពហួសពេក ដោយព្រោះមានការផ្លាស់ប្តូរទិន្នន័យពីឯកសារដើម ។ ពេលខ្លះមានគេរិះគន់ដល់ការបកប្រែគម្ពីរអង់គ្លេសមួយ គឺព្រះគម្ពីរជីវរស់ (The Living Bible) ដោយព្រោះហេតុផលនេះឯង ។ ព្រះគម្ពីរជីវរស់ (The Living Bible) ជួយអ្នកអានភាសាអង់គ្លេសឲ្យយល់ព្រះបន្ទូលប្រសើរជាងព្រះគម្ពីរភាសាក្រិកដែលលោកអគីឡា បកប្រែ ប៉ុន្តែវាមានការផ្លាស់ប្តូរដល់អត្ថន័យដើមខ្លាំងពេក ។

## ការបកប្រែបែបរក្សាអត្ថន័យ

មេរៀនដែលអាចឲ្យជៀសផុតពីគ្រោះថ្នាក់ចំពោះការបកប្រែ គឺយើងមិនត្រូវពឹងផ្អែកទៅលើភាពជ្រុលនិយមទាំងពីរខាងលើនេះទេ ។ យើងគួរតែព្យាយាមយកចំណុចខ្លាំងមកប្រើ ហើយបោះចំណុចខ្សោយរបស់វានីមួយៗចោល ។ ទិន្នន័យនៃឯកសារដើមត្រូវតែរក្សាទុក ប៉ុន្តែអត្ថរូបនៃភាសាដែលទិន្នន័យនាំយកទៅអាចផ្លាស់ប្តូរទៅតាមភាសារបស់អ្នកទទួល ។ នៅពេលដែលយើងព្យាយាមរក្សាដោយភាពស្មោះត្រង់ដល់បរិបទ និងគោលបំណងរបស់វា ក្នុងទំរង់បែបនេះ ការរក្សាអត្ថរូបត្រូវបានបោះបង់ចោល នេះហើយហៅថាការបកប្រែបែបរក្សាអត្ថន័យ ឬសមមូលដ៏មានថាមពល ។

ការតម្រង់ទៅរករបៀបបកប្រែបែបនេះ ឆ្លើយតបដល់អ្នកអានប្រសើរជាងការផលិតទំរង់ធម្មតាថ្មីមួយទៀតរបស់ឯកសារដើម ។ បែបនេះត្រូវបានហៅថា "ការតម្រង់ថ្មី" មួយក្នុងការបកប្រែ ។ ប៉ុន្តែ វាមិនមែនថ្មីសុទ្ធសាធនោះទេ ព្រោះសូម្បីតែលោក យេរ៉ូម (Jerome គ.ស ៣៤៧-៤១៩) លោក លូធ័រ (Luther ១៤៨៣-១៥៤៦) និង លោក ដូឡេត (Dolet ១៥០៩-

១៥៨៦) ក៏បានប្តូរអត្ថរូបដើម្បីឈានទៅរកអត្ថន័យត្រឹមត្រូវ ។ ពេលដែលលោក យេរ៉ូម ត្រូវគេចោទប្រកាន់ថា គាត់បានបកប្រែខុសនូវសំបុត្រមួយ គាត់បានបង្ហាញពីគោលការណ៍របស់គាត់ថា "ក្នុងការបកប្រែពីភាសាក្រិក... ខ្ញុំបកប្រែអត្ថន័យមួយគំនិតម្តងៗ មិនមែនបកប្រែពាក្យមួយម៉ាត់ម្តងៗនោះទេ" ។

ការបកប្រែបែបរក្សាអត្ថន័យ ឬសមមូលដ៏មានថាមពល លើកស្ទួយសង្គភាពដែលក្នុងការជ្រើសរើសពាក្យខ្ពស់ជាងសង្គភាពដែលថ្លែងចេញស៊ីទៅនឹងស្ថានការណ៍ ។ ការរើសពាក្យមានន័យស្មើ មិននៅងាប់ក្រឡាដែលស៊ីទៅនឹងស្ថានការណ៍ មានន័យថា ធ្វើឲ្យការបកប្រែរបស់ពាក្យមួយសមទៅនឹងឃ្លាដែលបានប្រើរួចមកហើយ ទោះបីជាពាក្យនោះអាចជំនួសដោយពាក្យផ្សេង ឬឃ្លាផ្សេងក៏ដោយ គឺយោងទៅតាមស្ថានការណ៍នៃការបកប្រែពាក្យណាមួយចេញពីពាក្យដើម ។ នេះគឺវាប្រសើរជាងប្រើពាក្យងាប់ក្រឡា ឬប្រើពាក្យដូចគ្នាដើម្បីបកប្រែពាក្យនីមួយៗពីភាសាដើម ពីព្រោះពាក្យដែលប្រើនៅក្នុងភាសាទីមួយ មិនអាចដូចក្នុងភាសាទីពីររហូតនោះទេ។ ឧទាហរណ៍ ពាក្យអង់គ្លេសថា "know" មិនអាចបកប្រែជាភាសាខ្មែរតែមួយពាក្យបាននោះទេ ។ To know ធ្វើអ្វីមួយ អាចបកប្រែថា "ចេះ" បន្ថែមជាមួយកិរិយាស័ព្ទ To know អ្នកណាម្នាក់ គឺត្រូវបកប្រែថា "ស្គាល់" វិញ ។ ដូច្នេះដើម្បីបកប្រែឃ្លាអង់គ្លេសឲ្យបានត្រឹមត្រូវ "I know Tom, and Tom knows how to fix your problem" គឺតម្រូវឲ្យប្រែថាស្គាល់ផង និងចេះផងសំរាប់ពាក្យ "know" តែមួយ ។ យើងត្រូវតែបន្តបកប្រែទៅតាមស្ថានការណ៍ ប្រសើរជាងការប្រើពាក្យងាប់ក្រឡាដែលមិនប្រែប្រួល ប្រសិនបើយើងចង់ឲ្យការបកប្រែនោះបានទទួលជោគជ័យ ។

នេះហាក់បីដូចជាជាក់ស្តែងពេក ។ ប៉ុន្តែ ការបកប្រែបែបរក្សាអត្ថន័យត្រូវតែអនុវត្តតាមរបៀបនេះដើម្បីវាយតម្លៃទៅលើឥទ្ធិពលរបស់វា

ចំពោះអ្នកអាន ។ កាលពីអតីតកាលកន្លងមក ការបកប្រែត្រូវបានគេវាយតម្លៃដោយប្រៀបធៀបឯកសារដើមជាមួយនឹងអត្ថបទបកប្រែ ។ ប្រសិនបើអត្ថរូប ឬទំរង់ទាំងពីរនេះល្អដូចគ្នា ការបកប្រែនេះត្រូវបានគេពិចារណាថាត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយ ការជ្រើសរើសយកពាក្យដែលមានន័យស្មើមិននៅងាប់ក្រឡាទាមទារឲ្យការឆ្លើយតប ពីសំណាក់អ្នកអានចំពោះឯកសារបកប្រែ មានភាពស្រដៀងគ្នាទៅនឹងការឆ្លើយតបរបស់អ្នកអានឯកសារដើម ។ ការឆ្លើយតបនេះរួមបញ្ចូលទាំងផ្នែកចំណេះដឹង ក៏ដូចជាអត្ថន័យសមស្រប របស់អត្ថបទ និងការលើកទឹកចិត្តឲ្យមានភាពសកម្មឡើង ។ ដូច្នេះការបកប្រែល្អ តំណាងឲ្យតួនាទីក្នុងការផ្តល់ពត៌មាន (ទំនាក់ទំនងនៃទិន្និន័យ) តួនាទីបង្ហាញពីចំណាប់អារម្មណ៍ (ទំនាក់ទំនងនៃអារម្មណ៍) និងតំណាងឲ្យតួនាទីចាំបាច់មួយទៀតគឺ (ទំនាក់ទំនងដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការ) ។ ភាពស្មោះត្រង់ក្នុងការបកប្រែ គឺអាស្រ័យលើសមត្ថភាពក្នុងការជំរុញឲ្យមានការឆ្លើយតបដូចគ្នាមួយ ចំពោះអត្ថបទបកប្រែក៏ដូចជាអត្ថបទដើម ។

## សេចក្តីត្រូវការឲ្យអ្នកអានយល់

មុននឹងបន្តវាយតម្លៃទៅលើការបកប្រែបែបរក្សាអត្ថន័យ សូមឲ្យយើងរំឭកថា ព្រះមានបំណងព្រះហឫទ័យឲ្យអ្នកអានយល់ដឹងអត្ថន័យនៃព្រះបន្ទូល ។ អ្វីដែលគួរឲ្យឆ្ងល់នោះគឺ មិនមែនអ្នកទាំងអស់គ្នាសុទ្ធតែទទួលបាននូវសេចក្តីពិតនោះឡើយ ថ្វីបើព្រះគម្ពីរអះអាងភាពត្រឹមត្រូវរបស់ខ្លួនក៏ដោយ ។ កណ្ឌចុងក្រោយដែលគេហៅថា កណ្ឌវិវរណៈ ពាក្យនេះមានន័យថា "ការបើកសម្តែង" ឬ "ការលាតត្រដាងឲ្យដឹង" ។ តាមរយៈចំណងជើងនេះ បង្ហាញឲ្យដឹងថា កណ្ឌនេះគឺជាការបើកសំដែង ឬ ការលាតត្រដាងឲ្យដឹងតាមភាពរាបស្មើដែលមិនមែនធ្វើឲ្យពិបាកយល់ ឬធ្វើអោយភាន់ច្រឡំនោះទេ ។ ទុតិយកថា ៣០:១១-១៤ ចែងថា ៖

"ដ្បិតបញ្ញត្តិដែលអញបង្គាប់មកឯងថ្ងៃនេះ មិនមែនហួសកម្លាំងឯងទេ ក៏មិនមែននៅឆ្ងាយដែរ គឺមិនមែននៅលើស្ថានសួគ៌ ឲ្យឯងបានថា តើអ្នកណានឹងឡើងទៅស្ថានសួគ៌ នាំយកព្រះបន្ទូលមកប្រាប់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំបានប្រព្រឹត្តតាម នោះក៏មិនមែននៅត្រើយសមុទ្រខាងនាយឲ្យឯងបានថា តើអ្នកណានឹងឆ្លងសមុទ្រទៅនាំយកព្រះបន្ទូលមកប្រាប់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំបានប្រព្រឹត្តតាមនោះដែរ គឺព្រះបន្ទូលនេះនៅជិតឯងណាស់ ក៏នៅក្នុងមាត់ឯង និងក្នុងចិត្តឯងផង ដើម្បីឲ្យឯងអាចប្រព្រឹត្តតាមបាន ។"

ព្រះគ្រីស្ទបានបន្ទោសដល់អស់អ្នកដែលមិនយល់ព្រះបន្ទូលរបស់ទ្រង់ ដោយបញ្ជាក់ថា ពួកគេគួរក្តាប់ឲ្យជាប់[១] ។ ទោះបីជាព្រះបន្ទូលមានចេតនាបញ្ចៀសសេចក្តីពិតចេញពីអ្នកដែលមិនជឿក៏ដោយ ក៏ការពិតនោះមិនមែនដោយសារតែភាសាធ្វើឲ្យមានការភាន់ច្រឡំ ពិបាកយល់នោះទេ ប៉ុន្តែសារៈសំខាន់ខាងវិញ្ញាណទៅវិញទេ ដែលត្រូវគេបញ្ចៀសចេញពីពាក្យដ៏សាមញ្ញនោះ[២] ។ លោក អែសរ៉ា អានក្រិត្យវិន័យឲ្យបណ្តាជនគេយល់ពីលទ្ធផលនៃការផ្លាស់ប្រែចិត្ត ស្តាប់បង្គាប់ និង អំណរ[៣] ។

ការដែលថាព្រះគម្ពីរជាបន្ទូលរបស់ព្រះ បង្កប់ន័យថា ព្រះដែលជាអ្នកនិពន្ធ មានបំណងចង់បានការប្រាស្រ័យទាក់ទង និងការយល់ដឹងពីអ្នកអាន មិនមែនគ្រាន់តែដើម្បីរក្សាទំរង់នៃវេយ្យាករណ៍របស់វានោះទេ ។ ការ

---

[១] *លូកា ២៤:២៥; ម៉ាកុស ១២:២៤*

[២] *ម៉ាថាយ ១៣:១០-១៥; ១ កូរិនថូស ១:១៨-២៥; ២:៦-១០*

[៣] *នេហេមា ៨*

សម្លឹងទៅលើព្រះបន្ទូលបែបនេះ មិនមែនមានន័យថា យើងមិនជឿទៅលើការដែលព្រះបណ្ដាលឲ្យតែងព្រះគម្ពីរនោះទេ ។ ប៉ុន្តែវាមានការយល់ច្បាស់ដល់ទាំងពីរផ្នែក ទាំងលក្ខណៈនៃអត្ថបទ និងប្រវត្តិសាស្ត្រនៃការបញ្ជូនព្រះបន្ទូលមក ។ យើងត្រូវដឹងថា ព្រះជាម្ចាស់មានព្រះហឫទ័យទុកដាក់ដល់ការនាំខ្លឹមសារនៃព្រះបន្ទូលរបស់ទ្រង់ពីមនុស្សមួយជំនាន់ទៅមួយជំនាន់ទៀតខ្លាំងជាងការរក្សាអត្ថរូប ឬទំរង់ឲ្យបានដូចអត្ថបទដើមបេះបិទដែលគ្មានអ្នកណាម្នាក់អាចយល់បាន ។ យើងមិនមានឯកសារដើមនៃគ្រប់ទាំងកណ្ឌព្រះគម្ពីរនោះទេ ប្រសិនបើយើងមាននៅសល់ខ្លះ នោះមនុស្សនឹងមិនសង្ស័យឡើយ ព្រមទាំងធ្វើការថ្វាយបង្គំវាដូចជាពួកអ៊ីស្រាអែលបានថ្វាយបង្គំពស់លង្ហិនអឺចឹងដែរ ។ ការខ្វែងគំនិតគ្នា និងភាពមិនច្បាស់លាស់ពិបាកយល់ត្រូវបានរកឃើញក្នុងអត្ថបទហេព្រើរ និងអត្ថបទក្រិក ។ ការពិភាក្សាវែកញែកនៅតែបន្តរវាងអ្នកកាន់សាសនាមួយចំនួន និងអ្នករិះគន់អត្ថបទ ។ មានដំណឹងដែលថា ព្រះយេស៊ូបានបង្រៀនក្នុងក៏រិតខ្ពស់ជាភាសា អារាមិក ប៉ុន្តែយើងគ្មានឯកសារអារាមិកដើមណាប្រាប់យើងឲ្យដឹង "ពិតប្រាកដ" ពីអ្វីដែលព្រះអង្គទ្រង់មានបន្ទូលនោះទេ ។ ដំណឹងល្អទាំងបួន ប្រែប្រួលទៅតាមការពិពណ៌នានៅក្នុងហេតុការណ៍តែមួយ ។ មធ្យោបាយដែលអ្នកនិពន្ធព្រះគម្ពីរសញ្ញាថ្មីដកស្រង់អត្ថបទពីព្រះគម្ពីរសញ្ញាចាស់មានការផ្លាស់ប្តូរ ម្តងដូច្នេះម្តងដូច្នោះ ពេលខ្លះពួកគេប្រើអត្ថបទហេព្រើរ តែពេលខ្លះគេប្រើអត្ថបទគម្ពីរសិបតង់ (ព្រះគម្ពីរសញ្ញាចាស់បកប្រែពីភាសាហេព្រើរ ទៅជាភាសាក្រិក) ឬពេលខ្លះភាសាក្រិក ពេលខ្លះទៀតទាំងពីរភាសា ។ អ្វីដែលសំខាន់នោះគឺពួកគេនាំយកអត្ថន័យដើមរបស់វាជាងប្រើពាក្យត្រង់ៗចេញពីភាសាដើមតែមិនយល់ន័យ ។ សរុបសេចក្តីមកយើងបានដឹងច្បាស់អំពីរបៀបបកប្រែដើម្បីឲ្យអ្នកអានយល់បាន ។ ទោះបីជាយើងមិនបានរំលោភទៅលើគោលលទ្ធិនៃការផ្លុំបណ្ដាលផ្ទាល់មាត់ ឬ ខិលច្រអូសក្នុងការសិក្សាលំអិតទៅលើ

អត្ថបទនោះក៏ដោយ យើងត្រូវតែបន្តក្នុងការយល់ដឹងពីជំនឿ និងស្តាប់បង្គាប់ដល់ព្រះបន្ទូល ដែលទ្រង់មានបំណងព្រះហឫទ័យផ្តល់ព្រះបន្ទូលមកដល់យើង ។ ព្រះយេស៊ូបានដាស់តឿនដល់អស់អ្នកដែលបានអនុវត្តការសិក្សាយ៉ាងរវាសរវៃទៅលើសេចក្តីលំអិតទាំងឡាយ តែបែរជាមិនយល់ខ្លឹមសាររួមរបស់វាទៅវិញ[៤] ។

## ការបកប្រែបែបរក្សាអត្ថន័យ និងការយល់ដឹង

ប្រសិនបើការប្រាស្រ័យទាក់ទងអត្ថន័យ ជាគោលដៅរបស់ព្រះបន្ទូល ឯពាក្យ និងអត្ថរូបគ្រាន់តែជាមធ្យោបាយសំរាប់បង្កើតអត្ថន័យទាំងនោះ វាជាកត្តាសំខាន់ក្នុងការកំណត់វិធីសាស្រ្តនៃការបកប្រែដើម្បីឲ្យអត្ថន័យមានទំនាក់ទំនងល្អងាយយល់ ។

ការសិក្សាស្រាវជ្រាវជាច្រើននៅសហរដ្ឋអាមេរិក បានឲ្យយោបល់ថា មនុស្សមានការដឹងដោយសារការបកប្រែបែបរក្សាអត្ថន័យខ្លាំងជាងការបកប្រែបែបរក្សាអត្ថរូប ។ នេះគឺជាការពិតសំរាប់មនុស្សគ្រប់ជាន់ថ្នាក់ និងគ្រប់កំរិត ។ ទោះបីជាសិស្សប្រើការបកប្រែបែបរក្សាអត្ថរូបអស់មួយជីវិតគេក៏ដោយ ក៏ពួកគេនៅតែយល់ថា ការបកប្រែបែបរក្សាអត្ថន័យនៅតែមានលក្ខណៈប្រសើរជាងនៅពេលដែលឱកាសហុចឲ្យពួកគេ ។

មានអ្នកខ្លះជំទាស់ចំពោះការនេះ ហើយប្រកែកថា ការធ្វើឲ្យមានភាពធូរស្រាលក្នុងការយល់ដឹងអត្ថន័យ មិនគួរមានសារៈសំខាន់លើសការរក្សាអត្ថរូប ដែលសឹងតែមានន័យត្រង់ៗពិតប្រាកដតាមអត្ថបទដើមនោះទេ ។ មានបុរសម្នាក់ពោលថា "ភាពត្រឹមត្រូវ មិនមែនជាការធ្វើឲ្យធូរស្រាលក្នុងការយល់ដឹងនោះទេ ប៉ុន្តែវាជាគោលដៅជាមូលដ្ឋាន

---

[៤] យ៉ូហាន ៥:៣៩-៤៧

នៃការបកប្រែ"[៥] ។ ប៉ុន្តែគាត់បានពន្យល់ពាក្យសំដីរបស់គាត់ដោយបំភ្លឺតាមរយៈទ្រឹស្តីរបស់លោក អេនស្តេន (Einstein's Theory) ស្តីអំពីផលគុណដែលថា "២ គុណនឹង ២ ស្មើ ៤" ។ នេះគឺមិនត្រឹមត្រូវទេ ហើយថែមទាំងបាត់បង់ចំណុចទាំងស្រុងផង ។ "២ គុណនឹង ២ ស្មើ ៤" ពិតប្រាកដហើយ គឺវាងាយយល់ ប៉ុន្តែនេះមិនមែនជាតំណាងផលគុណរបស់ទ្រឹស្តី អេនស្តេន ឡើយ ។ ម្យ៉ាងវិញទៀតការបកប្រែបែបរក្សាអត្ថន័យដែលល្អតែងជួបប្រទះភាពលំបាកក្នុងការរក្សាអត្ថន័យរបស់អត្ថបទដើម នៅពេលដែលព្យាយាមធ្វើការបកប្រែឲ្យគេយល់បាន ។ បុរសម្នាក់ទៀតប្រកែកថា គ្រីស្តបរិស័ទមិនត្រូវគិតថា ព្រះគម្ពីរជាការងាយយល់នោះទេ កំរិតនៃវិញ្ញាណការសិក្សា និងការសញ្ជឹងគិត គ្រូបង្រៀន និងសៀវភៅបកស្រាយព្រះគម្ពីរគឺជាជំនួយដែលគេត្រូវការជាចាំបាច់ ។ សំរាប់គាត់ ទស្សនៈវិជ្ជានៃការបកប្រែដែលមិនជាប់ទាក់ទងទៅនឹងការរក្សាអត្ថរូប "តម្រូវឲ្យមានការបកប្រែដែលច្បាស់ជាងអត្ថបទដើម ហើយឆ្លើយតបទៅនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ក្នុងការដែលព្រះអង្គប្រើគ្រប់មធ្យោបាយដើម្បីប្រទានការយល់ដឹងមកដល់យើង"[៦] ។ ពេលខ្លះ យើងឮរឿងស្រដៀងគ្នានេះនៅក្នុងប្រទេសខ្មែរ "ការបកប្រែ "ខ" គឺសំរាប់កូនខ្ចីខាងវិញ្ញាណ ពីព្រោះវាមានលក្ខណៈងាយយល់ ឯអ្នកដែលសិក្សារឹងមាំ គឺការបកប្រែ "ក" ដែលមានភាពលំបាកជាង ។"

---

[៥] *ថូម៉ាស អេហ្គា "បន្ទូលរបស់ព្រះ ឬ... ជាការរក្សាអត្ថន័យដើម?"* *Reflections*, Fall 1983, 3.

[៦] *ភ៉ន់ ផារុណាក "កំណត់សំគាល់លើការបកប្រែ" ១៩៧៤* (mimeographed), ៧

ទោះជាយ៉ាងណាក៏ដោយ ការបកប្រែបែបរក្សាអត្ថរូបមានភាពមិនសូវត្រឹមត្រូវដូចការបកប្រែមួយទៀត ដែលមានការសម្រួលរចនាសម្ព័ន្ធនៃភាសាដើម្បីធ្វើឲ្យគេអាចយល់នោះឡើយ ។ នេះគឺពីព្រោះតែវាក្យស័ព្ទ ឬវេយ្យាករណ៍នៃភាសាដើម ឬទីកន្លែងដែលគេនិពន្ធអត្ថបទដើម មានបង្កប់ទៅដោយវប្បធម៌ទំនៀមទំលាប់ដែលអ្នកអានមិនអាចយល់បានប្រសិនបើគ្មានការពន្យល់បកស្រាយ[៧] ។ ទោះជាយ៉ាងណាក៏ដោយ ក៏លោក ប៉ារុណាក (Parunak) ប្រកែកថា ពាក្យដែលអាចមានន័យលើសពីមួយនៅក្នុងអត្ថបទដើម ត្រូវតែរក្សាទុកនៅក្នុងការបកប្រែ មិនត្រូវឲ្យគេលើកយកមកបញ្ជាក់ន័យតែមួយតាមរយៈការបកស្រាយឡើយ ។

ទោះជាយ៉ាងណាក៏ដោយ យើងត្រូវសង្កេតមើលភាពខុសគ្នារវាងពាក្យដែលមានន័យលើសពីមួយដែលអ្នកនិពន្ធចង់និយាយ និងពាក្យមិនច្បាស់លាស់ ឬការពិបាកយល់ដែលចេញពីលទ្ធផលនៃការមិនយល់ដឹងច្បាស់លាស់ពីរឿងប្រពៃណី ឬភាសានៃអត្ថបទដើម ។ ការរក្សាទុកនូវពាក្យមិនច្បាស់លាស់ ឬការពិបាកយល់នេះមិនត្រឹមត្រូវឡើយ ទោះជាអត្ថបទដើមមិនធ្វើឲ្យមានការភាន់ច្រឡំដល់អ្នកអានដើមនោះក៏ដោយ ។ ឧទាហរណ៍ ទោះជាយើងមិនអាចដឹងច្បាស់ពីអ្វីដែលលោក ប៉ូល ចង់និយាយនៅក្នុង ១ កូរិនថូស ៧:៣៦-៣៨ តែវាមានភាពច្បាស់លាស់ដល់អ្នកអាននៅជំនាន់គាត់ ព្រោះគាត់បានឆ្លើយនូវសំនួរដែលពួកគេបានសួរ ។ ដូច្នេះអ្នកបកប្រែត្រូវតែស្វែងយល់ពីអត្ថន័យនៃប្រភពដើម ជាជាងការរក្សានូវ "អត្ថរូប" ដែលគេមិនអាចយល់បាន ។ អ្នកបកប្រែត្រូវមានការយល់ដឹងអំពីគោលបំណងរបស់អ្នកនិពន្ធជាងអ្នកអានភាគច្រើន ។ ការបកប្រែដែលនាំឲ្យគេយល់ច្រឡំ

---

*[៧] សូមអានសំបុត្ររបស់ រិក ស្តើស ដែលបានបកប្រែក្នុងគម្ពីរ ក៏យឃ្វើហ្វ ក្នុងសេចក្តីបន្ថែម ៗ*

អត្ថន័យសព្វថ្ងៃនេះ គឺជាការបំពានទៅលើអត្ថន័យនៃឯកសារដើម ។ លើកលែងតែក្នុងករណីដែលអ្នកនិពន្ធមានបំណងចង់សរសេរពីអ្វីមួយដែលមានន័យលើសពីមួយ (ដូចជាក្នុង យ៉ូហាន ៣:៣, ៧ ពាក្យ "again" អាចមានន័យថា "ម្តងទៀត" ឬ "មកពីលើ") តើការដែលរក្សាពាក្យដែលមានន័យច្រឡូកច្រឡំដូច្នេះ គួររក្សានៅក្នុងការបកប្រែ ឬទេ?

## ការកំណត់ព្រំដែនដល់ការបកប្រែបែបរក្សាអត្ថន័យ

ដោយសរុបសេចក្តីថា ការបកប្រែបែបរក្សាអត្ថន័យឲ្យស្មើនឹងអត្ថន័យដើម ដែលផ្តោតទៅលើអ្នកអាន ក៏ដូចជាផ្តោតទៅលើអត្ថបទ ហុចលទ្ធផលឲ្យមានការងាយយល់ជាង ហើយការបកប្រែបែបនេះមានភាពត្រឹមត្រូវជាង នោះយើងត្រូវដឹងថា តើយើងកំណត់ព្រំដែនយ៉ាងណាចំពោះដំណើរការនៃការបកប្រែនេះ ។ តើយើងគួរទៅឆ្ងាយប៉ុនណា ដើម្បីកុំឲ្យយើងផ្លាស់ប្តូរអត្ថន័យរបស់ឯកសារដើម?

ទីមួយ អ្នកបកប្រែត្រូវបង្កើតជាថ្មីនូវការយោងដ៏ត្រឹមត្រូវទៅរកហេតុការណ៍ពិតនៃប្រវត្តិសាស្ត្រ ។ ការបកប្រែអង់គ្លេសមួយ ហៅថាការបកប្រែបំណះផាឌិបលើសំបុត្ររបស់លោកប៉ូល (Cotton Patch Version of Paul's Epistles) រំលោភគោលការណ៍នេះ ហើយផ្លាស់ប្តូរសំបុត្រទៅអ្នកក្រុង កូរិនថូស ទៅជា "សំបុត្រទៅគ្រីស្តបរិស័ទនៅក្រុង អាត្លង់តា" ។ នៅក្នុងសំបុត្រនេះ របស់ដែលថ្វាយដល់រូបព្រះនៅក្នុង ៨:១ ក្លាយទៅជាធ្វើការនៅថ្ងៃអាទិត្យ ។ ហើយ ពួកយូដា និងសាសន៍ដទៃក្នុង ១០:៣២ ទៅជាពួកស្បែកស និងពួកអាហ្វ្រិក អាមេរិកាំងទៅវិញ ។ ប៉ុន្តែយើងត្រូវរក្សាប្រវត្តិសាស្ត្រដើមឲ្យនៅតែពិតដដែល ។ ប្រសិនបើយើងផ្លាស់ប្តូរការពិពណ៌នានៃព្រះគម្ពីរសញ្ញាថ្មីនៃ "ការទំរេតខ្លួននៅលើតុ" (ប្រហែលវាជាប្រពៃណីបរទេសសំរាប់យើង) យើងអាចប្តូរទៅជា "អង្គុយញ៉ាំ" (នេះគឺ

អ្វីដែលយើងគួរធ្វើ យោងទៅតាមប្រពៃណីរបស់យើង) នោះយើងនឹងមានបញ្ហាក្នុងការយល់ថា តើលោក យ៉ូហាន ដាក់ក្បាលលើឱរាព្រះយេស៊ូនៅបន្ទប់ខាងលើយ៉ាងដូចម្ដេច ។

ទីពីរ យើងត្រូវរក្សាការបង្រៀនព្រះគម្ពីរសញ្ញាថ្មីអោយត្រឹមត្រូវទៅតាមភាពដើមរបស់វា ទោះបីជាយើងមិនចូលចិត្តក៏ដោយ ។ ឧទាហរណ៍ភាសា អង់គ្លេសនៅក្នុង The Living Bible បកប្រែភាសាក្រិក (ἐπίστευσαν ὅσοι ἦσαν τεταγμένοι εἰς ζωὴν αἰώνιον) នៅក្នុង កិច្ចការ ១៣:៤៨ ថា "As many as wanted eternal life, belived." "អស់អ្នកណាដែលចង់បានជីវិតអស់កល្បជានិច្ច ក៏ជឿ" ទោះបីនេះជាការអាចយល់បានក៏ដោយ ក៏ប៉ុន្តែ វាឆ្លុះបញ្ចាំងទេវវិទ្យារបស់អ្នកបកប្រែ ជាងឆ្លុះបញ្ចាំងទៅលើអត្ថបទដែលសរសេរជាភាសាក្រិក ។

ទីបី យើងត្រូវតែចៀសចេញពីការបកប្រែណាដែលមានលក្ខណៈមិនពេញលេញ បំផ្លើស និងផ្ដល់ពត៌មានមិនត្រឹមត្រូវ ។ ព្រះគម្ពីរដ៏រស់ "The Living Bible" ពិតជាបានរំលោភច្បាស់ណាស់ក្នុងគោលការណ៍នេះ គឺក្នុង អេម៉ុស ១:១-"Amos was a herdsman living in the village of Tekoa. All day long he sat on the hillsides watching the sheep, keeping them from straying." "អេម៉ុសគឺជាអ្នកគង្វាល រស់នៅក្នុងភូមិមួយឈ្មោះ ត្កូអា ។ គាត់បានអង្គុយពេញមួយថ្ងៃនៅតាមជ្រលងភ្នំដើម្បីមើលចៀមមិនឲ្យវាវង្វេង" ។ ពេលដែលប្រៀបធៀបទៅនឹងអត្ថបទហេព្រើរ ការបកប្រែនេះមានការបន្ថែមយ៉ាងពិតប្រាកដ ហើយព្រមទាំងមានការលុបបំបាត់ទៀតផង។

## ការចែងគោលដៅសាជាថ្មី

មនុស្សដែលគាំទ្រការបកប្រែតាមរបៀបរក្សាអត្ថន័យ បានស្នើដែនកំណត់បីនេះ ។ ប៉ុន្តែ យើងគួរពង្រីកទ្រឹស្ដីបន្ថែមទៀត ដោយមានការរៀបចំ

ប្រកាសវត្ថុបំណងរបស់វា ដោយបង្កើតនូវការឆ្លើយតបបែបសមមូលក្នុងភាគីអ្នកអាន ។ តើការឆ្លើយតបនេះ ជាការដែលអាចសំរេចបាន គួរឲ្យចង់បានឬទេ? ភាពដែលអាចនឹងកើតមានឡើងដល់ការឆ្លើយតបដែលធ្វើឲ្យមានសមមូល គឺគួរឲ្យសង្ស័យ ពីព្រោះតែប្រវត្តិសាស្ត្រ និងប្រពៃណីមានចម្ងាយរវាងអ្នកអានជំនាន់ដើម និងអ្នកអានជំនាន់អ្នកបកប្រែ ។ ការដែលគួរឲ្យចង់បានគឺ បានហៅចូលទៅក្នុងការសង្ស័យដោយគម្លាតនៃហេតុការណ៍រវាងភាពទាំងពីរនេះ ។

ឧទាហរណ៍ គោលបំណងនៃការសរសេររបស់លោក ប៉ូល ក្នុង ១ កូរិនថូស ៥ គឺពួកជំនុំបានដកចេញសមាជិកម្នាក់ពីក្រុមរបស់ខ្លួន ។ តើគួរបកប្រែអោយពួកជំនុំសព្វថ្ងៃដកពួកជំនុំណាម្នាក់ចេញយ៉ាងឆាប់រហ័សពីក្រុមរបស់ខ្លួន នៅពេលដែលម្នាក់នោះរស់នៅដោយប្រាសចាកសីលធម៌ឬទេ? ហេតុកាណ៍ការផ្សេងៗផ្តល់នូវគោលដៅនៃការដែលមិនគួរឲ្យចង់បាននូវការឆ្លើយតបសមមូល ។ បំណងនៃការឆ្លើយតបមួយរបស់លោកប៉ូលទៅជំពូកដំបូងរបស់រ៉ូមគឺថា ពួកយូដាមិនមានអារម្មរណ៍ប្រសើរជាងពួកសាសន៍ដទៃឡើយ ។ ដំបូងភាពខុសគ្នារវាង គ.ស ៦០ នៅក្នុងអាណាចក្ររ៉ូម និងដើមសតវត្សទី២១ ផ្តល់នូវវត្ថុបំណងជាទូទៅដែលមិនសូវចាំបាច់ ។ ការខុសគ្នាទាំងនេះ ប្រហែលជាតម្រូវឲ្យមានការត្រឡប់សកម្មភាពទៅវិញ ដែលថាពួកគ្រីស្តបរិស័ទ សាសន៍ដទៃមិនមានអារម្មណ៍ថា ខ្លួនប្រសើរជាងពួកយូដាឡើយ ។ ការឆ្លើយតបតាមសំបុត្រដល់ពួកជំនុំភីឡាដិលភា (វិវរណៈ ៣:៧-១៣) ត្រូវតែមានការលើកទឹកចិត្តរបៀបណាមួយ ហើយមានការរក្សាក្នុងផ្លូវដូចគ្នា (ខ.១ "ចូរកាន់ខ្ជាប់តាម សេចក្តីដែលឯងមាន") ។ ប្រសិនបើពួកជំនុំឡៅឌីសេ បានឆ្លើយតបក្នុងផ្លូវតែមួយ វាគួរតែមានការអាក្រក់ជាទីបំផុត ។ ដើម្បីផ្តោតខ្លាំងទៅលើការដែលធ្វើឲ្យមានភាពឆ្លើយតបសមមូលដែលអត្ថបទបានធ្វើឲ្យមានការលៃសំរួលទៅលើការឆ្លើយតបនោះ គឺជាការ

បរាជ័យក្នុងគោលបំណងខ្ពស់នៃការបកប្រែ ការបង្កើតឲ្យមានអត្ថន័យដូចគ្នាសុទ្ធសាធនៃប្រភពឯកសារ ។

មនុស្សមួយចំនួនព្យាយាមប្រាប់យើងថា ការធ្វើឲ្យអត្ថបទបកប្រែមានលក្ខណៈងាយយល់ គឺសំខាន់ជាងការបកប្រែដែលរក្សាអត្ថន័យទាំងស្រុងរបស់អត្ថបទដើមទៅទៀត ។ ប៉ុន្តែ តើគំនិតនេះប្រកបដោយគតិបណ្ឌិតឬទេ? តើត្រឹមតែភាពងាយយល់ អាចធ្វើឲ្យការបកប្រែមានលក្ខណៈល្អប្រសើរដែរ ឬយ៉ាងណា? តើវាមិនត្រូវការឲ្យមានអត្ថន័យដូចគ្នាទៅនឹងអត្ថបទដើមទេឬ?

ប្រសិនបើការ "ឆ្លើយតបដែលរក្សាអត្ថន័យស្មើ" មិនមែនជាចំណង់ចំបង តើជាអ្វីទៅ? ការប្រសើរជាងនោះ ប្រហែលជាបទពិសោធន៍របស់អ្នកអាន "ការរក្សាន័យស្មើនោះ គឺប្រកាន់ខ្ជាប់ និងការក្រសោបន័យស្របតាមសារលិខិតនោះ"។ "ការក្រសោប" រួមបញ្ចូលក្នុងការខំប្រឹងឲ្យយល់ទាំងពីរ ទាំងខាងទិន្នន័យ ទាំងខាងសំលេងនៃការងារ ។ "ការក្រសោប" មានន័យថា អ្នកអានមានការចង់ទទួលនូវភាពដូចគ្នា និងភាពបន្ទាន់ដើម្បីស្តាប់បង្គាប់ដល់ហេតុដែលថា កាលៈទេសៈរបស់គេស្របទៅនឹងភាពដើមទាំងនេះ ។ ដោយបង្កើតឲ្យមាន "ការប្រកាន់ខ្ជាប់ និងការក្រសោបឲ្យស្របតាម" គោលដៅនៃការបកប្រែ ប្រសើរជាងការឆ្លើយតបសមមូល យើងត្រូវតែរក្សាគម្លាតច្បាស់លាស់រវាងភាពដើម និងអ្នកអានបច្ចុប្បន្ននៅពេលដែលកំពុងលើកទឹកចិត្តថា អត្ថបទបុរាណ និយាយត្រូវទៅនឹងស្ថានភាពយើងសព្វថ្ងៃនេះ ដែរឬទេ ។

## សរុបសេចក្តី

សរុបទៅ ការបកប្រែគឺជាកិច្ចការដ៏លំបាកមួយ មិនមែនគ្រាន់តែតំរូវឲ្យមានការផ្លាស់ប្តូរវាក្យស័ព្ទ រចនាសម្ព័ន្ធវេយ្យាករណ៍ទៅក្នុងភាសាថ្មីតែ

ប៉ុណ្ណោះនោះទេ ប៉ុន្តែវាជាអត្ថន័យ និងថាមពល ។ ការយល់ដឹង គឺជាទិសដៅសំខាន់នៃការបកប្រែបែបរក្សាអត្ថន័យ គឺមានប្រសិទ្ធិភាពបំផុតក្នុងការធ្វើឲ្យមានភាពយល់ដឹង ។

ទោះជាយ៉ាងណាក៏ដោយ មិនគួរផ្តោតយ៉ាងខ្លាំងទៅលើអ្នកអានដែលឯកសារដើមបានបំពេញដល់ខ្លួនគាត់តែប៉ុណ្ណោះទេ ។ ប្រសិនបើយើងមិនប្រុងប្រយ័ត្ន ទិសដៅនៃការបង្កើតការឆ្លើយតបមានអត្ថន័យស្មើ អាចលើកទឹកចិត្តបាន ។ ដូច្នេះ អ្នកបកប្រែត្រូវមានគោលដៅបង្កើតកិច្ចការងារដើម្បីឲ្យបទពិសោធន៍សមមូលរបស់អ្នកអានឈោងចាប់កិច្ចការនោះបាន ។ ក្នុងមធ្យោបាយថ្លឹងថ្លែងឲ្យស្មើរវាងការកំណត់អត្ថបទ និងអ្នកអាន គឺត្រូវបានរក្សាវាទុក ។

លោក អឺជិន នីដា (Eugene Nida) ពណ៌នាពីព្រះគម្ពីរពីរប្រភេទនៅប្រទេសថៃ ។ ប្រភេទទីមួយ គឺការបកប្រែជាភាសាអង់គ្លេសតាមរបៀបចាស់គំរិល ហើយសឹងតែគ្មានអ្នកណាម្នាក់យល់បាន ។ ទោះបីយ៉ាងណាក៏ដោយ ព្រះគម្ពីរនេះប្រើការបានសំរាប់ម្ចាស់សណ្ឋាគារ ពីព្រោះតែរក្សាវានៅតាមបន្ទប់នីមួយៗ ម្ចាស់សណ្ឋាគារបានរកឃើញថា គាត់មានការបន្ថយការបាត់ភួយ និងកន្សែងពោះគោបន្តិចម្តងៗ ។ ផ្ទុយទៅវិញ ការបកប្រែមួយផ្សេងទៀតនិយាយភាសាមនុស្សដែលគេនិយាយ ។ បន្ទាប់ពីបានអានការបកប្រែដែលយល់ដឹងជាងមុនរួចមក ពុទ្ធសាសនិកម្នាក់បានយល់ព្រមអនុញ្ញាតឲ្យសង្ឃរបស់គាត់គ្រប់អង្គទទួល "សៀវភៅដ៏អស្ចារ្យនេះ" ។ ទោះជាយ៉ាងណាក៏ដោយ ក៏គាត់បានដាស់តឿនសង្ឃគ្រប់ៗអង្គមិនឲ្យទទួលសូម្បីតែមួយក្បាលប្រសិនបើមិនបានរៀបចំអត់ងងុយមួយយប់[៨] ។

---

[៨] Ibid., 130.

ចូរយើងលើកស្ទួយការបកប្រែព្រះគម្ពីរ ដែលបណ្ដាលឲ្យមនុស្ស បាត់បង់ការងោកងុយ ប្រសើរជាងលើកស្ទួយការបកប្រែដែលបានត្រឹមតែ បំបាក់ទឹកចិត្តចោរលួចក្រណាត់ផាឌិប ។ ប៉ុន្តែសូមយើងលើកទឹកចិត្តការ បកប្រែណាដែលមិនបានកែព្រះរាជសារសម្រួលទៅតាមបុព្វហេតុនៃអ្វីដែល គេហៅថា ភាពច្បាស់លាស់ ។

## សេចក្ដីបន្ថែម

តទៅនេះគឺជាចំណែកនៃសំបុត្រមួយ សរសេរឡើងនៅថ្ងៃទី ៣០ ខែមិនា ឆ្នាំ ១៩៨៩ ដោយលោក រិក ស្ពីស (Rick Speece) ។ នៅពេលនោះ រិក កំពុងធ្វើការបកប្រែព្រះគម្ពីរ វ៉ាយគ្លីហ្វ (Wycliffe) គម្ពីរសម្ព័ន្ធថ្មីមួយ សំរាប់ជនជាតិ អង់ហ្គាវ (Angave) នៃប្រទេស ប៉ាពួនូវ គីនី (Papua New Guinea) ។

រំលងបាន២ខែក្រោយមក អ្នកបកប្រែ៨នាក់ផ្សេងទៀតនៅក្នុង ប្រទេសប៉ាពួ នេះបានចូលរួមជាមួយពួក អង់ហ្គាវ ២នាក់ និង ខ្ញុំ ដើម្បីពិនិត្យ រាល់ថ្ងៃនៅក្នុងសំបុត្ររបស់ ប៉ូល និង កណ្ឌលូកា ។ ការត្រួតពិនិត្យនេះ ចំណាយពេលអស់ជាច្រើនខែ ពិនិត្យទៅលើឯកសារដូចគ្នាជាមួយមនុស្ស ជាច្រើននៅឯភូមិមួយឈ្មោះ អង់ហ្គាយ (Angai) ។ នៅពេលនេះប្រហែលជា អស់លោកខ្លះកំពុងឆ្ងល់ "ហេតុអ្វីបានមានការត្រួតពិនិត្យច្រើនម្ល៉េះ?" សូមឲ្យ ខ្ញុំធ្វើការពន្យល់ថា ហេតុអ្វីបានជាខ្ញុំដាក់អ្នកក្នុងកន្លែងដែលមានម្នាក់ទៀត អានអំពីហេតុការណ៍អ្វីមួយដែលបានកើតឡើងនៅក្នុងប្រពៃណីដែលអ្នក មិនស្គាល់ ។ សូមពិនិត្យមើលរឿងមួយ ដែលបានបកប្រែទៅជាភាសាអង់ គ្លេស ហើយពីភាសាអង់គ្លេស ទៅជាភាសាខ្មែរ ពីអីនីបាឡយ (Inibaloi) គឺជាភាសាហ្វីលីពីនមួយ ដោយលោក លីបាឡាត (Lee Ballard) ។

¨អស់អ្នកដែលបានរកឃើញ (លុយខ្លះដែលត្រូវកប់ទុក) គឺ យ៉ូអាន់ បេចា (Juan Bajar)... ពួកគេបានមកដល់ផ្ទះទាំងយប់ ជាមួយលុយដែលគេបានរកឃើញ ហើយគាត់បានធ្វើ ¨កាពិ¨ (kapi) សំរាប់វា ។ ពេលយប់នោះនៅផ្ទះរបស់គាត់នៅឯសាលាកូបាន់ (Salakoban) ។ ពិតប្រាកដហើយ វាបានធ្វើនៅផ្ទះរបស់គាត់ គឺជាកន្លែងដែលបានធ្វើ ¨កាពិ¨ សំរាប់វា ។

¨ព្រឹកស្អែកឡើង នៅពេលដែលពួកគេកំពុងតែញាំក្បាល ឆ្អឹងថ្គាមថ្មីបានធ្លាក់ចុះ ។ ហើយវាមិនធ្វើឲ្យទ្រេត ឬ ផ្អៀងទេ នៅពេលដែលវាធ្លាក់ ប៉ុន្តែវាបែរជាត្រង់ឡើងលើ ហើយវាបានចង្អុលទៅទិសខាងកើត ។ នៅពេលដែលស្ត្រីម្នាក់បានឃើញវា ពួកគេនិយាយថា ¨ធ្វើវាម្តងទៀត¨ ។ ប្រហែលជាពួកគេបានរាប់ថា វាមិនគ្រប់គ្រាន់នៅឡើយ ។ ហើយយ៉ូអាន់បានធ្វើ ¨កាពិ¨ ជាលើកទីពីរ។

សូមសាកល្បងខ្លួនយើង ដើម្បីឲ្យដឹងថាការបកប្រែភាសាខ្មែរមកពីភាសាអង់គ្លេស មានអត្ថន័យពេញលេញ ដែរឬទេ ។ សូមឆ្លើយនូវសំនួរទាំងនេះ៖

តើ ¨កាពិ¨ មានន័យយ៉ាងដូចម្តេច?
ហេតុអ្វីបានជាពួកគេធ្វើ ¨កាពិ¨?
តើអ្នកណាបានញាំក្បាលនោះ?
តើក្បាលប្រភេទអ្វី ឬជាក្បាលអ្នកណា?
តើអ្វីទៅដែលធ្លាក់ចុះ?
តើឆ្អឹងថ្គាមអ្វី ដែលបានធ្លាក់ចុះ?
តើឆ្អឹងថ្គាម បានធ្លាក់ចុះមកពីណា?

តើអ្វីទៅដែលជាសារៈសំខាន់នៃកន្លែងឆ្អឹងថ្គាម?
តើស្ត្រីចាស់ម្នាក់មានសកម្មភាពយ៉ាងណា នៅពេលដែល
ពួកគេបានឃើញ?
តើអ្នកណាបានរាប់អ្វី ថាមិនគ្រប់គ្រាន់?

ខ្ញុំអាចទាយទុកជាមុនថា អស់លោកមិនអាចឆ្លើយរាល់សំនួរទាំងនេះបានដោយស្កប់ចិត្តនោះទេ ។ មូលហេតុអ្វី? ជាធម្មតាគឺដោយព្រោះអ្នកនិពន្ធបានប្រាប់រឿងនេះទៅបងប្អូន អ៊ីនីបាឡយរបស់គាត់ ដែលចែកចាយជាមួយគាត់នូវការយល់ដឹងពីប្រពៃណីពិតរួចទៅហើយ ។ ហេតុដូច្នេះហើយ បានជាគាត់មិនត្រូវការបញ្ជាក់ឲ្យច្បាស់ថែមទៀតនោះ ។ ឥឡូវសូមយើងធ្វើការពិចារណាការបកប្រែទីពីរក្នុងរឿងតែមួយ ។

"ម្នាក់ដែលបានរកឃើញ (លុយខ្លះដែលបានកប់ទុក) គឺយ៉ូអាន់ បេចា ។ ពួកគេបាននាំវាទៅផ្ទះរបស់គាត់ទាំងយប់ ហើយគាត់បានសម្លាប់ជ្រូកធ្វើពិធីជប់លៀង "កាពិ" មួយ ដើម្បីជាការតបស្នងដល់វិញ្ញាណជីដូនជីតារបស់គាត់ ។ ពិតប្រាកដហើយ គឺនៅផ្ទះរបស់គាត់ឯសាលាកូបាន់ ដែលគាត់បានធ្វើពិធីជប់លៀង "កាពិ"" ។

"ព្រឹកស្អែកឡើង តាមប្រពៃណីរបស់គេ គេតែងតែមានសហគមន៍អាហារពេលព្រឹកបន្ទាប់ពីជប់លៀង ។ នៅពេលដែលពួកគេកំពុងបរិភោគអាហារពេលព្រឹកនោះ ឆ្អឹងថ្គាមរបស់ជ្រូកដែលបានថ្វាយកាលពីយប់មុននោះ បានធ្លាក់ចុះមកពីដំបូលដែលលយចេញពីផ្ទះ នៅកន្លែងដែលគេព្យួរក្បាលជ្រូកនោះទៅតាមប្រពៃណីរបស់គេ ។ ហើយក្បាលជ្រូកនោះមិនផ្អៀង ឬ ទ្រេតឡើយនៅពេលដែលវាធ្លាក់ចុះ ប៉ុន្តែវាបែរជាត្រង់ទៅលើ ហើយចង្អុលទៅទិសខាងកើតជាកន្លែងដែលវិញ្ញាណអយ្យកោរបស់ពួកគេរស់នៅ ។ នៅ

ពេលដែលស្ត្រីចាស់ម្នាក់បានឃើញ ពួកគេបានរាប់វាថា ទាំងអស់នេះ គឺជាប្រផ្នូលអាក្រក់មួយ ហើយនិយាយទៀតថា "ធ្វើពិធី "កាពិ" ម្តងទៀត ជាលើកទីពីរ ។ ប្រហែលជាវិញ្ញាណអយ្យកោរបស់ពួកគេបានរាប់ថា ជ្រូកដែលពួកគេបានថ្វាយនោះ តបស្នងមិនគ្រប់គ្រាន់ឡើយ" ។ ហើយយ៉ូអាន់បានធ្វើពិធី "កាពិ" ជាលើកទីពីរមែន" ។

តើអ្នកយល់ថា ការបកប្រែលើកទីពីរនៃរឿងនេះមានអត្ថន័យជាងការបកប្រែលើកទីមួយ ឬទេ? មូលហេតុអ្វី? ពីព្រោះការដឹងអំពីប្រពៃណីគឺសំខាន់សំរាប់អ្នកដែលមិននិយាយភាសា អីនីបាឡយ ដើម្បីឲ្យយល់ពីរឿងនេះ បានសរសេរជាអក្សរច្បាស់ៗ (bold) ។ ឥឡូវនេះការបកប្រែទីពីរ គឺមានភាពខុសប្លែកពីទីមួយ ប៉ុន្តែវាមានរឿងដូចគ្នាដែលបានប្រាប់ជារបៀបសាមញ្ញវិញក្នុងមធ្យោបាយដែលធ្វើឲ្យអ្នកខាងក្រៅមានការយល់ដឹងពេញលេញជាង ។

ឥឡូវនេះខ្ញុំសង្ឃឹមថា អ្នកមានគំនិតប្រសើរឡើងអំពីអ្វីដែលយើងរកឃើញសារៈសំខាន់របស់វា ដើម្បីត្រួតពិនិត្យហើយត្រួតពិនិត្យទៀតលើការបកប្រែរបស់យើងឲ្យបានហ្មត់ចត់ ។

ចូរយើងពិចារណាសំនួរពីរ ដែលថ្មីៗនេះត្រូវបានសួរដោយអ្នកប្រឹក្សានៃការត្រួតពិនិត្យការបកប្រែ អង់ហ្គោរ នៃក័ណ្ឌកិច្ចការ ។ លោកអ្នកអាចរំឭកឡើងវិញនូវជំពូកទី៩ អំពី លោក ប៉ូល ដែលបានគេចខ្លួនពីក្រុង ដាម៉ាស តាមកញ្ជើសំរូតចុះតាមកំពែងក្រុង ។ អ្នកប្រឹក្សាលើការបកប្រែ បានសួរថា "តើលោក ប៉ូល ចូលទៅក្នុងកញ្ជើនោះបានដោយរបៀបណា?" ពេលដែលខ្ញុំបានបកប្រែសំនួរនេះទៅជាភាសា អង់ហ្គោរ មាននារីម្នាក់ក្នុងចំណោមនារីពីរនាក់ ដែលពួកយើងត្រួតពិនិត្យបានឆ្លើយថា "ខ្ញុំមិនជឿថា លោក ប៉ូល អាចចូលក្នុងកញ្ជើបានដោយរបៀបណាឡើយ" ។ នារីម្នាក់ទៀតបានឆ្លើយ

ដែរថា "ប្រហែលជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បង្រួមលោកប៉ូលឲ្យតូចទាល់តែអាចចូលក្នុងកញ្ជើនោះបាន" ។ ចម្លើយរបស់នារីទាំងពីរនោះគឺត្រឹមត្រូវទៅតាមប្រពៃណីរបស់ពួកគេ ឬក៏ពួកគេមិនដែលឃើញកញ្ជើណាដែលធំជាងធុងដាក់ចំណុះជាង១០០លីត្រនោះទេ ។ ពួកគេមិនដឹងថា នៅមជ្ឈឹមបូព៌ា គេនិយមធ្វើកញ្ជើធំៗ ដែលមនុស្សជំទង់អាចចូលទៅក្នុងនោះបានដោយឥតមានបញ្ហា ។ ហេតុដូច្នេះហើយ បានជាយើងសំរេចចិត្តធ្វើឲ្យពាក្យ "កញ្ជើ" នេះមានគុណភាពឡើងឆាប់យល់នៅក្នុងការបកប្រែទៅជាភាសាអង់ហ្គ្លេ គឺ "កញ្ជើដែលធំអស្ចារ្យ" ។ ដោយធ្វើការសំរួលយ៉ាងដូច្នេះ យើងបានប្រគល់ការបកប្រែប្រាស្រ័យទាក់ទងឲ្យមានអត្ថន័យ ដូចដែលលោកលូកា មានបំណងចង់ឲ្យអ្នកអានរបស់គាត់អាចយល់បាន ។

បន្ទាប់មក នៅក្នុងជំពូកដដែល គឺជារឿងរបស់ តេប៊ីថា (ដែលស្រាយថានាងក្តាន់) ដែលបានស្លាប់ ហើយលោកប៉ូលបានប្រោសឲ្យនាងមានជីវិតរស់ឡើងវិញ ។ នៅក្នុង ខ ៣៧ "នាងមានជំងឺ ហើយក៏ស្លាប់ទៅកាលគេបានផ្ងូតទឹករូបនាងហើយ នោះក៏យកទៅដាក់ក្នុងបន្ទប់ខាងលើ" ។ អ្នកប្រឹក្សាបានសួរថា "ហេតុអ្វីបានជាគេផ្ងូតទឹករូបនាង?" នារីអង់ហ្គ្លេបាននិយាយគ្នាទៅវិញទៅមក ហើយឆ្លើយថា "យើងមិនដឹងថាហេតុអ្វី បានជាគេផ្ងូតទឹករូបនាងទេ ។ យើងមិនដែលធ្វើយ៉ាងដូច្នេះ ចំពោះអ្នកណាម្នាក់ដែលស្លាប់នោះទេ ។ ជាងនេះទៅទៀត យើងមិនដែលដាក់សពផ្តេកនោះឡើយ គឺយើងលើកសពបញ្ឈរឡើងឲ្យអង្គុយ ។ ទោះជាយ៉ាងណាក៏ដោយ យើងគិតថា ពួកគេគ្រាន់តែធ្វើតាមទំនៀមទំលាប់របស់ពួកគេនៅពេលដែលមនុស្សណាម្នាក់ស្លាប់" ។ នៅក្នុងពន្លឺរបស់ចម្លើយនេះ យើងមានអារម្មណ៍ថា អត្ថបទប្រាស្រ័យទាក់ទងអត្ថន័យពេញលេញដូចដែលបានបកប្រែ ហើយដោយគ្មានការសម្រួលអ្វីទាំងអស់ ទោះបីជាប្រពៃណីនោះមានភាពចម្លែកដល់ជនជាតិ អង់ហ្គ្លេ ក៏ដោយ ។

សំណុំឯកឃ្ញុំ ៣/៣ (តុលា ២០០២)៖ ១០៣-១១០



# ដើមត្នោតមានអំនួត



*លោក អ៊ួន សិលា*

មានប្រទេសមួយ លាតសន្ធឹងនៅក្នុងជ្រោយនៃទ្វីបអាស៊ីភាគអគ្នេយ៍ ដែលកាលពីដើមគេហៅថា "កម្ពុជា" ប្រែថា "ទឹកដីមាសឬសុវណ្ណភូមិ" ។ នៅក្នុងពេលនៅក្រោមអាណានិគមរបស់ប្រទេសបារាំង គេហៅប្រទេសនេះថា "កាំបូដ" ហើយឈ្មោះនោះក្រោយមកគេបានហៅជាភាសា អង់គ្លេសថា "ខេមបូឌា" ។ មានដើមត្នោតជាច្រើននៅក្នុងវាលស្រែភាគច្រើននៅក្នុងប្រទេសខ្មែរ ។ ថ្ងៃមួយក្រុមហ្វីកហ្វីនធីម៉ូថេរបស់យើងបានធ្វើដំណើរត្រឡប់មកពីបង្រៀនសិក្ខាសាលាស្ដីអំពីការរួបរួមនៅក្នុងខេត្ត កំពង់ធំ ។ នៅតាមផ្លូវត្រឡប់មកភ្នំពេញវិញនោះ ក្រុមរបស់ខ្ញុំគេបានសួរខ្ញុំថា "តោះឈប់មួយភ្លែតសិន រកកន្លែងបាញ់ទន្សាយ គឺមានន័យថា រកកន្លែងបត់ជើងតូច" ។ ដូច្នេះខ្ញុំក៏បានឈប់ឡាន ហើយយើងនាំគ្នាដើររកកន្លែងគួរសម ពេលនោះខ្ញុំបានឃើញដើមត្នោតមួយដើម ដែលមានដើមឈើមួយប្រភេទទៀតដុះជាប់នៅជាមួយ ។ មើលទៅគួរឲ្យចាប់អារម្មណ៍ មែនទែន! ដើមឈើនោះ

គេបានហៅថា ដើមជ្រៃ តាមទម្លាប់ដែលគេធ្លាប់ហៅភាគច្រើននៅក្នុងប្រទេសកម្ពុជា ។

ដូចខ្ញុំបានជំរាបជូនកាលពីលើកមុននៅក្នុងអត្ថបទមួយរបស់ខ្ញុំ[១] កសិករខ្មែរមួយចំនួនបាននិយាយថា ដើមឫស្សី និង ដើមត្នោត ជាប្ដីប្រពន្ធនឹងគ្នា ។ ដើមត្នោត គឺជារុក្ខជាតិដ៏មានប្រយោជន៍បំផុត ។ ដើមវាគេអាចប្រើយកទៅធ្វើផ្ទះ ធ្វើក្រោលគោក្របី ធ្វើទូក និងធ្វើឧបករណ៍កសិកម្មដទៃទៀត។ ស្លឹកត្នោតគេអាចប្រើវាប្រកជាដំបូលផ្ទះ ឬខ្ទម ធ្វើមួក កន្ទេល ស្បោងដាក់ស្រូវជាដើម ។ ទឹកត្នោតគេយកទៅធ្វើស្ករ ផ្លែត្នោតគេយកទៅធ្វើបន្លែស្ល និងនៅពេលវាទុំគេយកទៅធ្វើជានំអាកោ និងនំផ្សេងៗទៀត ។

ដូច្នេះដើមត្នោតមានប្រយោជន៍តាំងពីឫសរហូតដល់ស្លឹក គឺមានប្រយោជន៍ដូចជាដើមឫស្សីដែរ ។ ដើមត្នោតរឹង និងខ្លឹមណាស់ ។ វាមានឫសចាក់ស្រេះចូលគ្នារឹងមាំជាទីបំផុត ។ កម្រមានខ្យល់ព្យុះណាអាចធ្វើឲ្យដើមត្នោតរលំណាស់ ។ ស្លឹកត្នោតមានពណ៌បៃតងចាស់រហូតពេញមួយឆ្នាំ គឺពណ៌វាស្រដៀងនឹងពណ៌ដើមស្រល់ ឬដើមណូអែលដែរ ។ ពណ៌វាមិនប្រែប្រួលឡើយ ទោះជារដូវណាក៏ដោយ ។ ហេតុដូច្នេះហើយ ទើបម្ចាស់សណ្ឋាគារលំដាប់ផ្កាយប្រាំខ្លះ និងម្ចាស់អាគារទំនើបៗមួយចំនួនដទៃទៀតនៅក្នុងទីក្រុងភ្នំពេញ គេបានយកដើមត្នោតមកដាំដើម្បីលំអនៅក្នុងទីធ្លាខាងមុខអាគារទាំងឡាយនោះ ។ ដើមត្នោតទាំងឡាយនោះមិនគ្រាន់តែបន្ថែមសម្រស់ដល់សណ្ឋាគារប៉ុណ្ណោះទេ ប៉ុន្តែជួយរំលឹកដល់មនុស្សដែលកំពុងរស់នៅក្នុងសង្គមខំប្រជែងជើងគ្នាដើម្បីរស់នៅក្នុងទីក្រុង ឲ្យគេនឹកឃើញដល់ជីវិតរស់ដែលប្រកបដោយសេចក្ដីសុខរបស់កសិករខ្មែរយើងនៅតាម

---

[១] *ដើមឫស្សី នៅក្នុងសំណាំទឹកឃ្មុំ លេខ២/២ ឆ្នាំ ២០០២ ។ នៅត្រង់ទំព័រ១០-១៥ ។*

ជនបទ ។ កាលពីសម័យបោះឆ្នោតឆ្នាំ១៩៩៨ មានគណៈបក្សនយោបាយមួយបានជ្រើសយកដើមត្នោតមកធ្វើជានិមិត្តសញ្ញារបស់គណៈបក្ស ។ ប្រហែលជាគេយល់ឃើញថា គេអាចធ្វើឲ្យប្រជាជនខ្មែរចាប់អារម្មណ៍លើភាពរឹងមាំរបស់ដើមត្នោត ហើយនិងភាពមិនប្រែប្រួលនៃពណ៌របស់ស្លឹកត្នោត និងអាចយល់ចិត្តរបស់ប្រជារាស្ត្រខ្មែរ ដើម្បីឲ្យគេបោះឆ្នោតឲ្យ ។

ខ្ញុំផ្ទាល់ក៏យល់ស្របតាមគំនិតបែបនោះដែរ! ព្រោះវិចិត្រករខ្មែរភាគច្រើនតែងតែមានអារម្មណ៍ស្រដៀងគ្នានេះដែរ គឺនៅក្នុងគំនូររបស់គេដែលបង្ហាញពីទេសភាពនៅតាមជនបទស្រុកស្រែនោះ គេតែងតែគូររូបដើមត្នោតនៅក្នុងរូបនោះដែរ ។ ដើមត្នោតជារុក្ខជាតិមួយដែលរឹងមាំ និងមានប្រយោជន៍បំផុតនៅក្នុងប្រទេសខ្មែរ ។ ដើមត្នោតអាចឈររឹងមាំបានមិនថាឡើយនៅពេលទឹកជន់ឬមានខ្យល់ព្យុះនោះទេ ឬនៅក្នុងរដូវប្រាំងរាំងស្ងួតយ៉ាងណាក្តី ហើយមិនតែប៉ុណ្ណោះដើមត្នោតជានិមិត្តសញ្ញានៃដើមឈើតំណាងឲ្យប្រទេសជាតិទៀតផង ។

ប៉ុន្តែដើមត្នោតនឹងងាប់ បើសិនជាមានដីកខ្វក់នៅជាប់នឹងដើមនោះទោះបីជាដើមត្នោតរឹងមាំយ៉ាងណាក្តី និងមានមោទនភាពនឹងសម្រស់របស់ខ្លួនយ៉ាងណាក្តី ។ បើសិនកសិករមិនមកកាត់គាវត្នោតចាស់ៗចេញទេ គាវត្នោតទាំងនោះនឹងមានជាប់ដី ហើយដីនោះនឹងកកនៅតាមគាវត្នោត ។ មានសត្វស្លាបជាច្រើន ដែលតែងតែពាំយកផ្លែឈើយកទៅស៊ីនៅលើគាវត្នោតឬក៏ជុះអាចម៍នៅលើនោះ ។ នៅពេលមានភ្លៀងធ្លាក់មក អាចម៍សត្វដែលមានគ្រាប់រុក្ខជាតិនោះក៏ដុះឡើង ។ ពេលមុនដំបូង ពេលដែលដើមរុក្ខជាតិនោះដុះភ្លាមឃើញតូចមែនទែន ដែលដើមត្នោតគិតថា វាមិនមានការគំរាមកំហែងអ្វីដល់ខ្លួនវាឡើយ ។ ប្រហែលជាដើមត្នោតមានមោទនភាពខ្លួនឯងថា ខ្លួនមានសម្រស់កាន់តែស្រស់មួយកំរិតទៀត នៅពេលដែលខ្លួនមានដើមរុក្ខជាតិមួយប្រភេទទៀតមកដុះនៅជាមួយនោះ ។

ប៉ុន្តែមិនយូរប៉ុន្មាន ដើមរុក្ខជាតិនោះកាន់តែដុះធំឡើងៗជាលំដាប់ ។ ដើមត្នោតមិនអាចទទួលយកជីវជាតិដែលឫសរបស់ខ្លួនខំក្រេបជញ្ជក់ពីដីមកចិញ្ចឹមខ្លួនបានទេ ព្រោះជីជាតិទាំងឡាយនោះត្រូវបានរុក្ខជាតិមួយបែបទៀតជញ្ជក់យកអស់ ។ ដើមត្នោតក៏ចាប់ផ្ដើមកើតជម្ងឺកង្វះជីវជាតិ ហើយក្រោយមកមិនយូរប៉ុន្មានក៏ស្លាប់តែហោងតែម្ដងទៅ ។ នៅពេលដែលយើងទៅចូលរួមការប្រជុំបំប៉នស្មារតីបុគ្គលិកអង្គការ ទស្សនៈ ពិភពលោក (World Vision Staff retreat) នៅក្នុង ខេត្តសៀមរាប កាលពីពីរឆ្នាំមុន យើងបានទៅទស្សនាប្រាសាទអង្គរវត្ត ។ ខ្ញុំបានសង្កេតមើលទៅតាមកំផែងនៃប្រាង្គប្រាសាទទាំងឡាយនោះ ត្រូវទទួលរងនូវការបំផ្លិចបំផ្លាញដោយសារឫសឈើ ដូចដែលខ្ញុំធ្លាប់ឃើញដុះនៅតាមដើមត្នោតនោះដែរ ។ ឫសរុក្ខជាតិនោះវាបានញែកបំបែកផ្ទាំងសិលា ដែលដូនតារបស់យើងបានដាក់នៅជាប់ជិតគ្នានោះឲ្យឃ្លាតពីគ្នា ។ កំផែងប្រាង្គប្រាសាទទាំងនោះមើលទៅមានសោភ័ណភាពល្អប្រណិត ដរាបណាវានៅជាប់ស្អិតជាមួយគ្នា ហើយក្បាច់ចម្លាក់ដ៏រស់រវើកទាំងនោះ ឆ្លុះបញ្ចាំងពីស្នាដៃដ៏ប្រពៃរបស់បុព្វបុរសខ្មែរយើង ដែលមានអារិយធម៌ដ៏រុងរឿងនៃអធិរាជខ្មែរ ។ ដើម្បីជួយសង្គ្រោះប្រាង្គប្រាសាទទាំងនោះមិនឲ្យខូចខាត នោះក្រសួងទេសចរណ៍ត្រូវចាត់ឲ្យមានកម្មករទៅកាត់ឫសរុក្ខជាតិនោះចេញ ។ ប្រាង្គប្រាសាទបុរាណទាំងនោះភាគច្រើនទទួលរងនូវការខូចខាតដោយសារតែឫសឈើ ដែលដុះជ្រៀតនៅត្រង់ចន្លោះកណ្ដាលផ្ទាំងសិលានីមួយៗ ។ ដើមឈើទាំងនោះដុះត្រគោលត្រគុំក្នុងពេលដែលស្រុកខ្មែរកើតសង្គ្រាមក្នុងស្រុកអស់រយៈពេលយ៉ាងយូរដែលពេលនោះគ្មានអ្នកទេសចរណ៍ណាម្នាក់ហ៊ានទៅទស្សនាប្រាង្គប្រាសាទនោះឡើយ ។ ប្រទេសកម្ពុជា ត្រូវបានកាត់ផ្ដាច់ចេញពីពិភពលោកជិតពីរទសវត្សរ៍ ។ មិនថាឡើយអ្នកទេសចរណ៍មកពីក្រៅប្រទេស សូម្បីតែអ្នកទេសចរណ៍នៅក្នុងស្រុកក៏មិនអាចទៅទស្សនាប្រាង្គប្រាសាទទាំងនោះ

បានឡើយ ដោយសារសម័យកាលវាលពិឃាត ។ កាលពីសម័យនោះ មិនថាឡើយជីវិតមនុស្សទទួលរងនូវការកាប់សម្លាប់ សូម្បីតែផ្ទាំងសិលា ក៏ត្រូវទទួលរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរដែរ ។

រឿងទាំងឡាយខាងលើនេះ ធ្វើឲ្យខ្ញុំនឹកឃើញពីទំនាក់ទំនងដែល ព្រះជាម្ចាស់ហើយនិងប្រជារាស្ត្ររបស់ព្រះអង្គធ្លាប់មានភាពជិតស្និតពី មុនមកនោះ ។ កាលដើមដំបូងឡើយ មនុស្សនិងព្រះជាម្ចាស់ជាគូកនយ៉ាង ជិតស្និតជាមួយគ្នា ប៉ុន្តែបន្ទាប់ពីអាដាំ និងអេវ៉ា ធ្លាក់ក្នុងអំពើបាប ពេលនោះ ហើយដែលអំពើបាបបានចូលទៅក្នុងពិភពលោកយើងនេះ ហើយថែមទាំង បានញែកមនុស្ស និងព្រះអាទិកររបស់ខ្លួនឲ្យឃ្លាតពីគ្នា ។ ដ្បិតឈ្នួលនៃអំពើ បាបនោះគឺសេចក្តីស្លាប់ ។ ដើម្បីជួសជុលនូវទំនាក់ទំនងដែលបានបាក់បែក នោះ ដំបូងយើងត្រូវដោះស្រាយជាមួយអំពើបាបជាមុនសិន ។ មិនខុសគ្នានឹង ការជួសជុលកំផែងប្រាង្គប្រាសាទអង្គរវត្តនោះឡើយ ។ ដើម្បីជួសជុល ក្រសួងទេសចរណ៍ត្រូវបញ្ជូនមនុស្សឲ្យទៅកាត់ផ្តាច់ឫសឈើជាមុនសិន ។ កាលពីដំបូងឫសឈើទាំងនោះដុះឡើងតូចៗបំផុត ប៉ុន្តែនៅពេលយូរៗទៅ វាក៏កាន់តែធំឡើងៗជាលំដាប់ ។ កាលណាទុកវានៅកាន់តែយូរ ការខូចខាត ដល់រូបចម្លាក់នោះ កាន់តែធ្ងន់ធ្ងរ ។

អំពើបាប នៅពេលដែលវាចាប់ផ្តើមកើតឡើងដំបូង គឺវាតូចបំផុត ប៉ុន្តែនៅពេលដែលយើងទុកពេលឲ្យវាកន្លងហួសទៅកាន់តែយូរ គឺវាកាន់ តែធ្ងន់ធ្ងរឡើងៗ ។ អំពើបាបដែលយើងមិនបានលន់តួ នោះនឹងធ្វើឲ្យខូច ដល់ទំនាក់ទំនងផ្សេងៗ ។ នៅក្នុងនាមយើងជាគ្រីស្តបរិស័ទ សូមឲ្យយើង នឹកចាំពីមេរៀនដែលយើងរៀនបានពីដើមត្នោត ។ សូមកុំឲ្យយើងមានអំនួត ថាយើងរឹងប៉ឹង ដែលថាយើងជាដើមត្នោត ជានិមិត្តសញ្ញានៃប្រទេសជាតិ ឬក៏គិតថា ជារាស្ត្រដែលព្រះជាម្ចាស់ជ្រើសរើស ឬពូជសាសន៍ពិសេស និង គិតថាយើងមានមុខមាត់ ព្រោះមានគេត្រូវការយើងច្រើនយកទៅលំអ

សណ្ឋាគារថ្នាក់ផ្កាយ៥នោះឡើយ ។ កុំឲ្យយើងរំភើបនឹងលំអ និងកិត្តិយស ដែលយើងបានទទួលនោះឡើយ ។ បើសិនជាភ្លេចខ្លួន មិនអនុញ្ញាតឲ្យអ្នកថែសួនមកកាត់គាវចាស់ៗចេញពីយើងទៅទេនោះ យើងនឹងមានភាពកខ្វក់ជិតជាប់នៅជាមួយយើង ពេលនោះនឹងមានសត្វស្លាបជុះអាចម៍ដាក់លើយើង ។ ដូចជាសុភាសិតអង់គ្លេសមួយឃ្លា ដែលគេចែងរំលឹកយើងថា៖ "យើងមិនអាចបញ្ឈប់សត្វស្លាបពីការហើររំលងក្បាលយើងបានទេ ប៉ុន្តែយើងអាចបញ្ឈប់វាមិនឲ្យធ្វើសំបុកនៅពីលើក្បាលយើងបាន" ។

យើងត្រូវតែលន់តួអំពើបាបរបស់យើងទៅព្រះជាម្ចាស់ ។ តែនៅពេលដែលយើងព្រមលន់តួបាបរបស់យើងដល់ព្រះអង្គវិញ នោះព្រះអង្គសន្យាថានឹងប្រព្រឹត្តចំពោះយើងយ៉ាងសុចរិត គឺព្រះអង្គនឹងអត់ទោសរាល់អំពើបាបរបស់យើង និងសំអាតយើងពីការទុច្ចរិតទាំងឡាយផង ។[២] បើសិនជាយើងអនុញ្ញាតឲ្យអំពើបាបដុះដាលកាន់តែធំឡើងៗ នោះយើងមិនអាចចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់បានឡើយ យើងនឹងត្រូវវិនាសដូចជាដើមត្នោតដែរ ។

ដូចគ្នានេះដែរ រាល់ទំនាក់ទំនងផ្សេងៗរវាងមិត្តសម្លាញ់ និងរវាងក្រុមជំនុំ បើសិនជាយើងទុកឲ្យអំពើបាបដុះខណ្ឌយើងនោះ គឺវាអាចកើតឡើងនូវភាពរីករវដូចពោលខាងលើនោះបាន ។ ទំនាក់ទំនងរបស់យើងនឹងត្រូវរលំដួល ដូចជាផ្ទាំងថ្មនៅតាមកំផែងនៃប្រាង្គប្រាសាទអង្គរវត្តដែរ ។ ចូរប្រយត្ន័ឫសដែលដុះនៅចន្លោះផ្ទាំងសិលានានា ដែលស្ថាបត្យកររបស់យើងគេបានដាក់ឲ្យនៅជាប់ស្អិតជាមួយគ្នា ។ នៅពេលដែលវានៅជិតគ្នាទើបវាអាចក្លាយទៅជាបាយ័នមុខបួន ឬជារូបអប្សរាបាន និងអាចមើលទៅស្រស់ស្អាតទៅបានដែរ ។ ប៉ុន្តែបើមានឫសឈើទៅដុះនៅចន្លោះរូបភាពដើម

---

[២] ១យ៉ូហាន ១:៩

ដែលយើងកោតសរសើរថាស្រស់ស្អាត នោះនឹងលែងស្រស់ស្អាតទៀតហើយ ។ មិនគ្រាន់តែមើលទៅមិនស្រស់ស្អាតប៉ុណ្ណោះទេ គឺតួប្រាសាទទាំងមូលអាចនឹងត្រូវខូចបង់ទៅទៀតផង ។ ដូច្នេះ ចូរចាំឲ្យបានច្បាស់ថា ត្រូវកាត់ឫសឈើចោលចេញ ។

បងប្អូនអើយ ព្រះយេស៊ូសព្វព្រះហឫទ័យជួយជួសជុលទំនាក់ទំនងដែលបាក់បែករវាងមនុស្សជាតិទាំងឡាយនោះឡើងវិញ ។ ព្រះជាម្ចាស់ និងមនុស្សធ្លាប់មានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និតបំផុត ។ ប៉ុន្តែដោយសារតែអំពើបាបបានញែកមនុស្សយើងឲ្យដាច់ចេញពីព្រះអង្គ និងធ្វើឲ្យមានការបាក់បែកប្រេះឆាផ្នែកទំនាក់ទំនងនេះ ។ ពីព្រោះតែទំនាក់ទំនងដ៏សុក្រឹតរវាងព្រះជាម្ចាស់ និងមនុស្សត្រូវបាក់បែក ដូច្នេះហើយទើបរាល់ទំនាក់ទំនងទាំងឡាយក៏ត្រូវប្រែជាមិនល្អទាំងអស់ផងដែរ ។ ទំនាក់ទំនងនោះរួមមានទំនាក់ទំនងរវាងប្ដីនិងប្រពន្ធ កូននិងឪពុកម្ដាយ ចៅហ្វាយនិងកូនចៅ បងនិងប្អូន ប្រជាជាតិនិងប្រជាជាតិ ពូជសាសន៍និងពូជសាសន៍ ។ល។ បានក្លាយទៅជាជូរផ្អូម និងមានភាពរញ៉េរញ៉ៃអស់ទៅ ។ ហេតុអ្វី? គឺវាបណ្ដាលមកពីអំពើបាប ។ ប្រជាជន ជាតិសាសន៍ និងសង្គមទាំងអស់អាចរស់នៅដោយសុខដុមរមនាជាមួយគ្នា បើសិនជាគេព្រមអនុញ្ញាតឲ្យព្រះយេស៊ូកាត់ឫសគល់នៃអំពើបាបនោះចេញ ។ មានតែព្រះនាមព្រះអង្គតែមួយគត់ដែលអាចជួយសង្គ្រោះដល់មនុស្សលោកទាំងអស់បាន [៣]។ ព្រះអង្គជាកសិករ ដែលជួយសំអាតដើមត្នោតពីការរុករានទន្ទ្រានពីសំណាក់រុក្ខជាតិផ្សេងៗ ដែលបំផ្លាញដល់ការរីកដុះដាលរបស់ដើមត្នោត ។ ព្រះអង្គក៏ជាភ្នាក់ងារពីក្រសួងទេសចរណ៍ ដែលជួយកាត់ឫសឈើចេញពីចន្លោះផ្ទាំងសិលារបស់ប្រាង្គប្រាសាទដែរ ។

---

[៣] *កិច្ចការ៤:១២*

សរុបសេចក្តីៈ

- ដើមត្នោតអាចរស់នៅយូរអង្វែងនិងរឹងមាំបាន បើគ្មានដើមជ្រៃ ឬរុក្ខជាតិផ្សេងទៀតដណ្តើមដុះពីលើវាទេនោះ ។
- គ្រីស្តបរិស័ទអាចឈររឹងមាំក្នុងជំនឿរបស់ខ្លួនបាន បើសិនមិនព្រមឲ្យអំពើបាបរីកដុះដាលនៅក្នុងជីវិតរបស់គេ ។
- ផ្ទាំងសិលានៅក្នុងប្រាង្គប្រាសាទអាចមើលទៅស្រស់ស្អាត បើសិនជាផ្ទាំងសិលាទាំងនោះស្ថិតនៅកៀកកិតនឹងគ្នាតាមទំរង់ដើមដែលគេបានដាក់វាឲ្យនៅនោះ ។
- រាល់ទំនាក់ទំនងទាំងឡាយអាចមានភាពសុខដុមរមនាទៅបាន បើសិនជាយើងព្រមដោះស្រាយអំពើបាបជាមុនសិននោះ ។

HONEYCOMB 3/3 (October 2002): 111–114



# The Proud Palm Tree



*UON Seila*

On a peninsula in Southeast Asia lies a country once called "Kampuchea," meaning "The Land of Gold." During the colonial period the French called it "Cambodge," a name that later evolved into "Cambodia." There are a lot of palm trees in most farming fields in Cambodia. One day our Training of Timothys team was returning from a seminar on unity in Kompong Thom. On the way back to Phnom Penh my team asked me, "Let's stop for a while to shoot a rabbit (i.e., find a rest room)." So I stopped the car and we went to "shoot a rabbit" or "see a man about a dog," and I noticed a palm tree with another kind of tree growing on it. That was interesting! The tree was called *Chrey* in Cambodian.

As I mentioned in a previous article,[1] some Cambodian farmers consider the bamboo and palm tree to be husband and wife. The palm tree is very useful. It can be used for building houses, barns, boats, and farming tools. Its leaves can be used to thatch roofs, make hats, mats, containers for rice crops, etc. Its juice can produce sugar, its fruit can be cooked as food, and when it ripens the palm can be used to make *Akor* and other kinds of cake.

---

[1]Uon Seila, "Bamboo," *Honeycomb* 2/2 (April 2001): 10–15.

So the palm tree is very useful from root to leaves, just as is the bamboo. Its trunk is strong and hard. It has sturdy roots. Storms only rarely can cause a palm tree to fall. Its leaves look dark green all year round, similar to a pine tree or Christmas tree. It does not change color as the seasons pass. That is why owners of some five-star hotels and other buildings in Phnom Penh plant palm trees in their yards as decorations. They not only add beauty to the hotel, but also invite people caught up in a rat-race society to think about the peaceful countryside lives of Cambodian farmers. In the 1998 election one political party chose the palm tree as its emblem. Perhaps they thought they could focus the attention of the Khmer people on the strength of the tree and the unchanging evergreen color of its leaves, and so win people's hearts and votes.

I also agreed with that idea! Most Cambodian artists express similar feelings by including palm trees in their paintings of countryside scenery. The palm tree is a strong and useful plant in Cambodia. It can stand firm whether in flood or in storm or in dry season, and it also stands symbolically as a national tree.

But the palm tree will die if there is some dirt on it, even though it is so proud with its beauty and its strength. If the farmer does not come to cut the leaves and they stay attached, some dirt may accumulate where they attach to the trunk. Birds will drop into this dirt on the palm tree their stools carrying seeds of fruits they have eaten. When the rainy season comes, these small seeds will germinate and grow. At first they look too small to bother the tall palm tree. Maybe the palm even looks proud of having two kinds of tree growing together.

But as the years fly by the other tree grows bigger and bigger. Eventually the palm can't get enough of the nutrients that its roots absorb from the ground because the other tree sucks them all away. The palm tree then becomes malnourished, and before long dies.

When we had World Vision staff retreat in Siem Reap two years ago we visited a ruined temple. I noticed that some of the temple walls had been destroyed by the same kind of tree I saw growing on the palm tree. Its root had split the stones from sticking close together. As long as the stones stayed close together the wall looked good, and the beauty of each relief it bore vividly reflected the civilization of the Khmer

Empire. In order to save the temple from falling apart the Ministry of Tourism had workers cut the root of the tree away. Most of the ruin was destroyed by a root that grew between the stones of the temple. These trees had flourished during the long years of the civil war when no visitors came to see the temple. Cambodia was cut off from the world for nearly two decades. Neither local nor overseas visitors came to the temples during the time of the killing fields. So not only were people killed during that time, even the stones were badly damaged.

It reminded me of the relationship that God and his people once enjoyed. In the beginning man and God were close companions, but after the fall of Adam and Eve, sin entered this world and separated man from his creator. For the wages of sin is death. In order to fix the broken relationship sin must be dealt with first. It is like the stone wall at Angkor Wat. To save it from destruction they need to send some agent from the Ministry of Tourism to cut the root. When it first started growing the root looked very small, but as time went by it grew bigger and bigger. The longer it stayed the worse the damage it caused to the relief.

Sin at first starts very small, but as time passes its results grow worse and worse. Unrepented sin will ruin a relationship. As Christians please remember the lesson from the palm tree. Don't be proud that we are strong, that we the palm tree are the symbol of the country—the chosen race or kin, and that they use us to decorate five-star hotels. Don't be thrilled with the beauty and honor that we are given. If we forget to allow garden keeper to take away our old leaves we will become dirty, or birds will drop something on us. As an English saying reminds us, "We cannot stop birds from flying over our heads, but we can stop them from building their nests on our heads."

We have to confess our sins to God. But if we confess our sins to God, he will keep his promise and do what is right: he will forgive us our sins and purify us from all our wrongdoing.[2] If we allow sin to grow bigger and bigger we can never come into the presence of the Lord and we will perish like a palm tree.

---

[2] 1 John 1:9.

The same can happen in the relationships between friends and churches if we allow sins to grow between us. Like the stone wall at Angkor Wat, our relationship will fall apart. Beware of roots that start to grow between the stones that the builder originally placed close together. When the stones remain close together, they become the image of the four faces at Bayon or Apsara, and they look beautiful. But when tree roots grow in between, the original shape with its beauty and meaning is lost. Not only does it look ugly, but the whole temple may fall as well. Make sure you cut away the roots.

My friends, Jesus wants to fix the broken relationship with all humankind. God and man used to have a very close relationship. But sin separated us from God, and caused that relationship to break down. Because the sacred relationship between God and man broke, all other types of relationships have turned sour as well. Relationships between husband and wife, children and parents, brothers and sisters, nation and nation, race and race, etc., became spoiled and turned into a mess. Why? It is caused by SIN. But people, races, and societies can live in harmony if they allow Jesus to cut off the root of sin. He is the only name that can save mankind.[3] He is the farmer who can clean the palm tree to keep it from being destroying by an invading plant. He is the agent from the Ministry of Tourism who can dig out the roots growing between stones of the ruin.

Conclusion:

- Palm trees can live long and stay strong if they have no other tree growing in their stem.
- Christians can stand strong in their faith if they don't allow sin to grow bigger and bigger in their lives.
- Stones in old ruins can still look beautiful if they stay close to the original place where they were put.
- All kinds of relationships can be in harmony if sin is dealt with first.

---

[3]Acts 4:12.

HONEYCOMB 3/3 (October 2002): 115–119



# Watch and Pray

*Neal YOUNGQUIST*



Throughout the gospels, Jesus firmly commanded his disciples to watch and pray. As the Good Shepherd, concerned for the imminent dangers confronting his sheep, Jesus repeatedly emphasized the need to guard our souls through watchfulness and prayer.

The need to pray is obvious. But what does it mean to watch? In the original Greek text of Matthew 25:13; Mark 13:33,37; and Luke 21:36 the phrase "to watch" conveys the need to give strict attention to; be cautious and alert; be vigilant; be sleepless; be on guard for fear that through laziness and looseness some destructive calamity will suddenly overtake one's life.[1]

With this in mind, on what areas should we as Christians diligently focus? Three main areas deserve our attention: to watch against

---

[1][Ed. note: These verses use different words: γρηγορέω in Matt 25:13 and Mk 13:37; ἀγρυπνέω in Lk 21:36; βλέπω and ἀγρυπνέω in Mk 13:33.]

temptation, to be on guard against false teaching, and to prepare ourselves for Christ's return.

### Watching Against Temptation

> ***Above all else, guard your heart, for it is the wellspring of life.***
> ***Prov 4:23***

Jesus said, "Watch and pray so that you will not fall into temptation. The spirit is willing but the body is weak."[2] Often we think that temptation is solely external to ourselves. But to misdirect our full attention toward outward attractions leaves us vulnerable to the temptations lurking within our hearts. James wrote, "Each one is tempted when, by his own evil desire, he is dragged away and enticed."[3] We must accept the fact that impure desires lie in wait within our hearts looking for opportunities of expression in various forms. The importance of this cannot be underestimated since Satan, our accuser and tester, is well acquainted with these latent shortcomings, and cunningly seeks to exploit them for his advantage and our destruction.

Since the heart is deceitful beyond measure[4] many of these enticements often take on a subtle form: the persuasive urge to add to our temporal possessions; the consummate desire to position ourselves in the best light; a cunningness to dominate or manipulate people to our advantage; a hidden craving to feed our over-inflated egos; veiled hatred fueled by unforgiveness buried deep within our souls. Sadly, we underestimate our ability to deceive ourselves. Falling under sin's seductive influence we become its slaves at the expense of the vitality and fruitfulness of our spiritual lives. For this very reason Solomon, gifted with great wisdom although well experienced in falling prey to his own vices, urges us to "guard our heart, for it is the wellspring of life."[5]

---

[2]Matt 26:41.

[3]Jas 1:14.

[4]Jer 17:9.

[5]Prov 4:23.

Guarding our heart requires real courage to sincerely confront our inborn weaknesses. Such courage requires a consistent commitment to regular, humble self-examination through reading God's word and prayer. David's psalms exclaim the illuminating effect of God's inspired word—"the commands of Yahweh are radiant, giving light to the eyes"[6] and "the unfolding of your words give light; it gives understanding to the simple."[7] As the word of God shines on receptive hearts it opens one's understanding to the areas of life that are in need of transformation. Revelation of the heart's condition is further magnified through fervent prayer. David cried out to his Creator to search and know his heart, to test and know his thoughts, to reveal any offensive way, and finally to guide him on the everlasting way.[8]

Our travel on the road of righteousness, however, depends on the grace of God as well. The Apostle Paul, who encountered his own frustrations, recognized that personal resources were altogether insufficient to win the battle over the flesh. Victory is realized by reliance on Christ's redeeming work on the cross and the power of the Spirit of God in our lives.[9] It is God's abundant grace that "teaches us to say 'No' to ungodliness and worldly passions and to live self-controlled, upright, and godly lives in this present age."[10]

***My sheep hear my voice, and I know them and they follow me***
***Jn 10:27***

**Watching Against False Teaching**

The early church was constantly encountering false teaching. Various heresies, doctrines, myths, and "different gospels" were secretly entering the church and silently eroding the fundamental values and faith of the Body of Christ. Recognizing the dangers of following such pleasant-sounding but wayward teachings,

[6]Ps 19:8.
[7]Ps 119:130.
[8]Ps 139:23, 24.
[9]See Rom 6–8.
[10]Tit 2:12.

Paul, Peter, Jude, John, and other church leaders of the day issued strong warnings to guard against deceivers within their midst. Discerning the dangers as well, Jesus admonished his disciples to "Watch out that no one deceives you"[11] and "Be on guard against the yeast [teaching] of the Pharisees, which is hypocrisy."[12]

Today, very little is different from the times of the early church. Unsound doctrine, appealing to our carnal appetites, is ever present. With so much deception circling about us how can we keep true to the narrow road before us?

A commitment to studying and meditating upon the truth of the word of God and hiding it within our heart is the first defense against heresy. Second, John exhorts us to not believe every spirit "but test the spirits to see whether they are from God ... every spirit that acknowledges Jesus Christ has come in the flesh is from God."[13] And finally, cultivating an intimate relationship with the Lord through prayer and holy living will keep our hearts away from the crooked paths that lead to destruction. The more we know Him the better we can discern between truth and deception.

## Watching for His Return

The timing and events surrounding Christ's return has been passionately debated since the ascension. No doubt, every age had reason to believe that Christ's return was imminent. Yet, our focus must not be diverted on determining the day or hour of the return. Rather, we are to keep alert, preparing ourselves when Christ does come again.

The consequences of ill-preparedness are devastating. As with a guard asleep at his post, dangers abound for those who are consumed by the affairs of this world, unaware of the need to be spiritually ready. As demonstrated by the parables of the foolish virgins without oil in their lamps and the fearful servant who misused his single talent (ref. Matthew 25) the risks of negligence and faithlessness are too great to ignore.

---

[11]Mk 13:5.

[12]Lk 12:1.

[13]1 Jn 4:1–3.

> ***"No Regrets, No Remorse, No Retreat"***

As children of the light we are to be ever ready, not like those who are "asleep" carelessly partaking in deeds of darkness. Like pilgrims passing through this world our activities must center on courageously investing our lives, talents, and resources for the Kingdom of God. We are to be engaged in transforming the temporal nature of earthly things into an enduring quality for God's eternal kingdom. And, in doing so, to ready ourselves for the time when "the perishable must clothe itself with the imperishable, and mortal with immortality."[14]

Christ is coming for ready servants awaiting and hastening his return; servants longing for a lasting home; servants enduring hardship rather than the fleeting pleasures of sin; servants perceiving and welcoming the eternal promises from afar; servants making every effort to be found spotless.

All the more reason, therefore, for a commitment to watch over our hearts, guard our minds from errant teaching, and to be ready for Christ's second coming. Such a dedication, surrounded with the grace of God, will gain us a joyous entrance into God's eternal kingdom. With this in view, momentary struggles are worth it; short-term sufferings are bearable; difficulties give opportunity for praise. During our earthly sojourn may the pledge of a faithful servant in China ring true in our hearts: no regrets, no remorse, no retreat. Let that be our anthem as we live ever-watchful lives for God's glory!

---

[14] 1 Cor 15:53.

សំណុំទិកឃ្មុំ ៣/៣ (តុលា ២០០២)៖ ១២០-១២៧



# ចាំយាម និង អធិស្ឋាន

*ទៀល យ៉ាំងគ្រីស្ត*



តាមរយៈ គម្ពីរដំណឹងល្អទាំងអស់ ព្រះយេស៊ូមានព្រះរាជបញ្ជាយ៉ាងម៉ឺងម៉ាត់ ដល់សិស្សរបស់ព្រះអង្គឲ្យចាំយាម ហើយអធិស្ឋាន ។ ក្នុងនាមជាអ្នកគង្វាលដ៏ល្អ ត្រូវគិតអំពីគ្រោះថ្នាក់ដែលបំរុងនឹងកើតមានឡើងដល់ចៀមរបស់ខ្លួន ។ ព្រះយេស៊ូបានបញ្ជាក់ម្តងទៀតថា យើងអាចការពារព្រលឹងរបស់យើងបានតាមរយៈការចាំយាម និងការអធិស្ឋាន ។

អធិស្ឋាន គឺជាសេចក្តីត្រូវការជាក់ស្តែងបំផុត ។ ប៉ុន្តែ តើការចាំយាមមានន័យយ៉ាងដូចម្តេច? នៅក្នុងអត្ថបទដើមរបស់ក្រិកនៃ កណ្ឌ ម៉ាថាយ ២៥៖១៣, ម៉ាកុស ១៣៖៣៣, ៣៧; និង លូកា ២១៖៣៦ ពាក្យថា "ការចាំយាម"

មានន័យថា ការយកចិត្តទុកដាក់បំផុត ការប្រយ័ត្នប្រយែងយ៉ាងមធ្យ័ត មិនធ្វេសប្រហែស មិនងោកងុយឡើយ ត្រូវប្រយ័ត្នចំពោះការភ័យខ្លាចដែលកើតមានតាមរយៈភាពខ្ជិលច្រអូស និងការមិនប្រុងប្រយ័ត្ន ព្រោះវាអាចនាំឲ្យគ្រោះថ្នាក់កើតឡើងដល់ជីវិតយើងដោយមិនដឹងខ្លួន[1] ។

ប្រសិនបើយើងគិតអំពីការនេះនៅក្នុងគំនិតរបស់យើង តើផ្នែកណាមួយដែលក្នុងនាមយើងជាគ្រីស្ទបរិស័ទ គួរយកចិត្តទុកដាក់ជាទីបំផុត? មានការបីយ៉ាង ដែលទាមទារឲ្យយើងផ្ដោតការយកចិត្តទុកដាក់ទៅលើ គឺការចាំយាមប្រឆាំងនឹងសេចក្ដីល្បួង ការចាំយាមប្រឆាំងនឹងការបង្រៀនដែលខុសឆ្គង និងការចាំយាមដើម្បីរង់ចាំការយាងមកវិញរបស់ព្រះគ្រីស្ទ ។

## ការចាំយាមប្រឆាំងនឹងសេចក្ដីល្បួង

ព្រះយេស៊ូមានព្រះបន្ទូលថា "ចូរចាំយាម ហើយអធិស្ឋានចុះ ដើម្បីមិនឲ្យកើតសេចក្ដីល្បួងនាំចិត្តឡើយ ឯវិញ្ញាណក៏ប្រុងជាស្រេចមែនតែសាច់ឈាមខ្សោយទេ"[2] ។ យើងតែងតែគិតថា សេចក្ដីល្បួង គឺជារឿងខាងក្រៅខ្លួនរបស់យើងតែប៉ុណ្ណោះ ។ ប៉ុន្តែដោយសារការធ្វេសប្រហែសមិនយកចិត្តទុកដាក់ទៅលើសេចក្ដីល្បួងខាងក្រៅនោះហើយ ទើបធ្វើឲ្យយើងមានការរួមចំណែកជាមួយសេចក្ដីល្បួង ដែលចាំផ្នែក

> *ចូររក្សាចិត្ត ដោយអស់ពីព្យាយាម ដ្បិតអស់ទាំងផលនៃជីវិតសុទ្ធតែចេញពីក្នុងចិត្តមក ។*
> *សុភាសិត ៤:២៣*

[1] [Ed. note: *ខគម្ពីរទាំងនេះប្រើពាក្យខុសៗគ្នា:* γρηγορέω *ក្នុង ម៉ាថាយ ២៥:១៣ និងម៉ាកុស ១៣:៣៧*; ἀγρυπνέω *ក្នុង លូកា ២១:៣៦*; βλέπω *និង* ἀγρυπνέω *ក្នុង ម៉ាកុស ១៣:៣៣*.]

[2] *ម៉ាថាយ ២៦:៤១*

នៅក្នុងចិត្តរបស់យើង ។ លោក យ៉ាកុប បានសរសេរថា "តែដែលគ្រប់គ្នាមានសេចក្តីល្បួង នោះគឺដោយសារតែសេចក្តីប៉ងប្រាថ្នារបស់ខ្លួននាំប្រទាញ ហើយល្បួងលោមទេ"[3] ។ យើងត្រូវតែទទួលស្គាល់ថា វាជាការពិតដែលសេចក្តីប៉ងប្រាថ្នាមិនបរិសុទ្ធដេករង់ចាំនៅក្នុងចិត្តរបស់យើង ហើយប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីស្វែងរកឱកាស ។ សារៈសំខាន់នៃការនេះមិនអាចប្រមាណបានឡើយ ព្រោះសាតាំងដែលជាអ្នកប្តឹងពីយើង និងជាអ្នកល្បួងយើង ដឹងច្បាស់នូវអ្វីដែលនឹងកើតមាននៅពេលខាងមុខ ហើយវារិះរកគ្រប់ល្បិចកលដើម្បីជញ្ជក់យកការទាំងនោះទុកជាប្រយោជន៍របស់វា និងជាសេចក្តីវិនាសអន្តរាយរបស់យើង ។

ដោយព្រោះចិត្តជាគ្រឿងបញ្ឆោតលើសជាងអ្វីទាំងអស់[4] នោះសេចក្តីល្បួងទាំងប៉ុន្មានតែងកើតឡើងតាមរយៈកលល្បិចគ្រប់រូបភាព ដូចជាការបញ្ចុះបញ្ចូលជំរុញឲ្យមានសេចក្តីលោភលន់ចង់បានទ្រព្យសម្បត្តិលោកិយ ការលោភលន់ចង់បានមុខតំណែងខ្ពស់ ការប្រើល្បិចកលដើម្បីគ្រប់គ្រង ឬបញ្ចុះបញ្ចូលមនុស្សដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ការបិទបាំងមហិច្ឆតាដើម្បីបំប៉ោងអាត្មាខ្លួន ហើយស្បៀបាំងសេចក្តីសំអប់ត្រូវបានដុត ដោយការមិនចេះអត់ទោសដែលកប់យ៉ាងជ្រៅនៅក្នុងព្រលឹងរបស់យើង ។ គួរឲ្យសោកស្តាយណាស់ ដែលយើងប្រមាណសមត្ថភាពរបស់ខ្លួនដើម្បីបោកប្រាស់ខ្លួនឯង ។ ការលង់នៅក្នុងសេចក្តីល្បួងរបស់អំពើបាប វាធ្វើឲ្យយើងក្លាយទៅជាទាសកររបស់វា ដែលជាការខាតបង់នូវភាពក្លាហាន និងជីវិតខាងវិញ្ញាណរបស់យើង ។ ដោយព្រោះតែហេតុផលនេះហើយ បានជាព្រះបាទសាឡូម៉ូន ធ្លាប់មានបញ្ហាដោយសារតែអំពើឧបាយមុខរបស់ខ្លួន ទោះបី

---

[3] *យ៉ាកុប ១:១៤*

[4] *យេរេមា ១៧:៩*

ជាទ្រង់មានអំណោយទានផ្នែកប្រាជ្ញាយ៉ាងណាក៏ដោយ ទើបទ្រង់លើកទឹកចិត្តយើងឲ្យ "រក្សាចិត្ត ដោយអស់ពីព្យាយាម ដ្បិតអស់ទាំងផលនៃជីវិតសុទ្ធតែចេញពីក្នុងចិត្តមក"[៥]។

ការរក្សាចិត្ត តំរូវឲ្យមានសេចក្តីក្លាហានដ៏អង់អាចដើម្បីប្រឈមនឹងសេចក្តីកំសោយពីកំណើតរបស់យើង ។ សេចក្តីក្លាហានទាំងនោះទាមទារឲ្យយើងបន្តការប្តេជ្ញាដែលទៀងទាត់ ហើយពិនិត្យពិច័យមើលចិត្តគំនិតខ្លួនឯងឲ្យបានល្អតាមរយៈការអានព្រះបន្ទូល និង ការអធិស្ឋាន ។ ទំនុកតំកើងរបស់ស្តេចដាវីឌបានបញ្ជាក់ពីឥទ្ធិពលនៃការជួយបំភ្លឺរបស់ព្រះទ្ទូលទ្រង់ដែលបានបណ្តាល "ក្រិត្យក្រមនៃព្រះយេហូវ៉ាជាសុទ្ធសាធ ក៏បំភ្លឺភ្នែក"[៦] ហើយ "ការបើកសំដែងព្រះបន្ទូលទ្រង់ នោះផ្សាយពន្លឺចេញ ក៏ធ្វើឲ្យមនុស្សឆោតល្ងង់មានយោបល់"[៧] ។ នៅពេលដែលព្រះបន្ទូលព្រះអង្គចាំងមកលើចិត្តអ្នកដែលព្រមទទួល នោះវាបើកបង្ហាញឲ្យអ្នកនោះស្គាល់គ្រប់ផ្នែកនៃជីវិតដែលត្រូវការនូវការបំផ្លាស់បំប្រែ ។ ការអធិស្ឋានដោយស្មោះអស់ពីចិត្ត បានធ្វើឲ្យស្ថានភាពតឹងតែងនៅក្នុងចិត្តកាន់តែបើកចំហឡើង ។ ស្តេចដាវីឌបានអំពាវនាវដល់ព្រះអាទិកររបស់ទ្រង់ឲ្យពិនិត្យមើល ហើយស្គាល់ចិត្តរបស់ទ្រង់ ល្បងលដើម្បីជ្រាបពីគំនិតរបស់ទ្រង់ បង្ហាញឲ្យឃើញរាល់អំពើអាក្រក់ ហើយនៅទីបំផុតឲ្យនាំទ្រង់ដើរតាមផ្លូវដ៏នៅអស់កល្បជានិច្ច[៨] ។

ទោះបីយ៉ាងណាក៏ដោយ ការធ្វើដំណើររបស់យើងនៅលើផ្លូវដ៏សុចរិត គឺត្រូវពឹងផ្អែកទៅលើព្រះគុណនៃព្រះជាម្ចាស់ដូចគ្នា ។ លោកសាវ័កប៉ូល ជាអ្នកដែលបានជួបនូវរាល់ឧបស័គ្គទាំងប៉ុន្មាន បានទទួលស្គាល់ថា

---

[5] *សុភាសិត ៤:២៣*

[6] *ទំនុក. ១៩:៨*

[7] *ទំនុក. ១១៩:១៣០*

[8] *ទំនុក. ១៣៩:២៣, ២៤*

ធនធានផ្ទាល់ខ្លួនទាំងអស់នោះ គឺមិនគ្រប់គ្រាន់ដើម្បីឲ្យឈ្នះសង្គ្រាមខាងឯសាច់ឈាមបានឡើយ ។ ជ័យជំនះត្រូវពឹងផ្អែកទៅលើកិច្ចការប្រោសលោះនៃអង្គព្រះយេស៊ូគ្រីស្ទដែលទ្រង់បានសំរេចនៅលើឈើឆ្កាង និងអំណាចនៃព្រះវិញ្ញាណរបស់ព្រះអង្គនៅក្នុងជីវិតយើង[9] ។ គឺជាព្រះគុណដ៏បរិបូររបស់ព្រះជាម្ចាស់ដែល "បង្ហាត់បង្រៀនយើងឲ្យលះចោលសេចក្ដីទមិលល្មើស និងសេចក្ដីប៉ងប្រាថ្នាក្នុងលោកនេះ ហើយរស់នៅក្នុងសម័យនេះដោយសេចក្ដីធុន់ធ្ងរ សេចក្ដីសុចរិត ហើយដោយគោរពប្រតិបត្តិដល់ព្រះវិញ[10] ។

## ការចាំយាមប្រឆាំងនឹងសេចក្ដីបង្រៀនខុសឆ្គង

> *"ចៀមខ្ញុំតែងស្ដាប់ ឮសំឡេងខ្ញុំ ខ្ញុំស្គាល់វា ហើយវាមកតាមខ្ញុំ"* ។
> *យ៉ូហាន ១០:២៧*

ពួកជំនុំដំបូងតែងតែជួបប្រទះការបង្រៀនខុសឆ្គងជានិច្ច ។ ជម្លោះគោលលទ្ធិរឿងទាក់ទងនឹងប្រពៃណីជាច្រើន ព្រមទាំង "ដំណឹងល្អផ្សេងៗ" បានជ្រៀតចូលមកក្នុងពួកជំនុំដោយសំងាត់ ព្រមទាំងធ្វើឲ្យតម្លៃជាមូលដ្ឋាន និងជំនឿលើរូបកាយរបស់ព្រះគ្រីស្ទមានការធ្លាក់ចុះដោយមិនដឹងខ្លួន ។ ការទទួលស្គាល់គ្រោះថ្នាក់ដោយការធ្វើតាមសេចក្ដីបង្រៀនដែលស្ដាប់ទៅពិរោះ ប៉ុន្តែតាមពិតជាសេចក្ដីបង្រៀនដែលនាំឲ្យវង្វេងនោះ លោក ប៉ូល លោក ពេត្រុស លោក យ៉ូហាន និងអ្នកដឹកនាំពួកជំនុំដទៃទៀតនៅជំនាន់នោះ បានចេញប្រកាសជាស់តឿនយ៉ាងតឹងរ៉ឹងប្រឆាំងនឹងអ្នកបោកប្រាស់ទាំងនោះ ។ ដូចគ្នាដែរត្រូវមានការសង្កេតដល់គ្រោះថ្នាក់ទាំងនោះ ព្រះយេស៊ូបានដាស់តឿនសិស្ស

---

[9] *សូមមើលក្នុង រ៉ូម ៦-៨*
[10] *ទីតុស ២:១២*

របស់ព្រះអង្គ "ឲ្យប្រយ័ត្នក្រែងអ្នកណានាំពួកអ្នករាល់គ្នាឲ្យវង្វេង"[11] ហើយ "ចូរអ្នករាល់គ្នាប្រយ័ត្ននឹងដំបែ (សេចក្តីបង្រៀន) ពួកផារិស៊ី ដែលជាសេចក្តីកំពុត"[12] ។

សព្វថ្ងៃនេះមានការខុសគ្នាតិចណាស់ពីពួកជំនុំដំបូង ។ គោលលទ្ធិដែលមិនត្រឹមត្រូវ តែងកើតមានដល់ចំណាង់ចំណូលចិត្តខាងសាច់ឈាមរបស់យើងជានិច្ច ។ តើយើងអាចរក្សាផ្លូវពិតដ៏តូចនៅចំពោះមុខយើងបានយ៉ាងដូចម្តេច? បើការបោកបញ្ឆោតមានស្ទើរជុំវិញខ្លួនយើងយ៉ាងនេះ ។

ការប្តេជ្ញាសិក្សា និងសញ្ជឹងគិតទៅលើសេចក្តីពិតរបស់ព្រះបន្ទូល ហើយរក្សាទុកនៅក្នុងចិត្តរបស់យើង នោះគឺជាវិធីការពារចំបងសំរាប់ប្រឆាំងនឹងគ្រូក្លែងក្លាយ ។ ទីពីរ លោក យ៉ូហាន ដាស់តឿនយើងថា មិនត្រូវឲ្យជឿលើវិញ្ញាណទាំងអស់ឡើយ "ចូរល្បងវិញ្ញាណទាំងអស់វិញ ដើម្បីឲ្យដឹងជាមកពីព្រះឬមិនមែន... គឺអស់វិញ្ញាណណាដែលថ្លែងប្រាប់ថា ព្រះយេស៊ូគ្រីស្ទបានមកក្នុងសាច់ឈាម គឺវិញ្ញាណនោះហើយដែលមកពីព្រះ"[13] ។ ហើយចុងក្រោយ ត្រូវជ្រោយឡើងវិញនូវទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយព្រះអម្ចាស់តាមរយៈការអធិស្ឋាន ហើយការរស់នៅដោយបរិសុទ្ធ និងរក្សាចិត្តរបស់យើងចេញពីផ្លូវគ្រលីកគ្រលុក ដែលនាំមកនូវភាពអន្តរាយដល់យើង ។

## ការចាំយាមរង់ចាំការយាងមកវិញរបស់ព្រះគ្រីស្ទ

ពេលវេលា និងហេតុការណ៍ជុំវិញការយាងមកវិញរបស់ព្រះគ្រីស្ទត្រូវគេពិភាក្សាវែកញែកជាច្រើន តាំងតែពីព្រះគ្រីស្ទបានយាងទៅស្ថានសួគ៌។ គ្មានការសង្ស័យឡើយ គ្រប់ទាំងសម័យកាលមានហេតុផលក្នុងការជឿថា

---

[11] *ម៉ាកុស ១៣:៥*

[12] *លូកា ១២:១*

[13] *១ យ៉ូហាន ៤:៧-៣*

ការយាងមកវិញរបស់ព្រះគ្រីស្ទ ជិតមកដល់ហើយ ។ ដូច្នេះយើងមិនគួរផ្តោតចិត្តខ្វល់ខ្វាយពីរឿងថ្ងៃ ឬម៉ោងនៃការយាងមករបស់ព្រះអង្គពេកទេ ។ ការដែលសំខាន់ គឺយើងគ្រាន់តែប្រុងប្រៀបរៀបចំខ្លួនរបស់យើងរង់ចាំពេលដែលព្រះគ្រីស្ទយាងមកវិញម្តងទៀតតែប៉ុណ្ណោះ ។

ការធ្វេសប្រហែសនាំមកនូវភាពអន្តរាយ ។ ដូចជាអ្នកយាមដែលលង់លក់នៅក្នុងប៉ុស្តិ៍យាមរបស់ខ្លួន ។ គ្រោះថ្នាក់នឹងធ្លោះទៅរកអស់អ្នកដែលអោបក្រសោបកិច្ចការនៅក្នុងលោកនេះ ដោយមិនបានដឹងពីសេចក្តីត្រូវការនៃការប្រុងប្រៀបជាស្រេចខាងវិញ្ញាណ ។ ដូចជាការពិពណ៌នារឿងប្រៀបធៀបរបស់ស្រីៗល្ងង់ដែលគ្មានប្រេងនៅក្នុងចង្កៀងរបស់ខ្លួន និង អ្នកបំរើដែលភ័យខ្លាចមិនបានប្រើនូវអំណោយទានរបស់គេ(ម៉ាថាយ ២៥) ការប្រថុយប្រថានដោយមិនគិត និងគ្មានជំនឿ គឺជាការមួយធំពេកក្នុងការធ្វើមិនដឹងមិនឮ ។

> *"គ្មាន ការសោកស្តាយ*
> *គ្មាន ទិប្បជិសារី*
> *គ្មាន ការរាថយ"*

ក្នុងនាមយើងដែលជាកូននៃពន្លឺ យើងត្រូវតែមានការប្រុងប្រៀបជានិច្ច មិនមែនដូចអស់អ្នកដែល "ដេកលក់" នោះទេ ពួកគេមិនបានប្រុងប្រយ័ត្នខ្លួន ទីបំផុតទទួលចំណែកជាមួយសេចក្តីងងឹត ។ ដូចជា ព្យុហយាត្រាឆ្លងកាត់ពិភពលោកនេះ សកម្មភាពរបស់យើងត្រូវតែផ្តោតលើសេចក្តីក្លាហានដាក់ទុនជីវិត អំណោយទាន និងធនធានរបស់យើងសំរាប់នគររបស់ព្រះ ។ យើងមានតួនាទីក្នុងការបំផ្លាស់បំប្រែនិស្ស័យរបស់លោកិយនៅលើផែនដីនេះឲ្យមានស្ថេរភាពឡើងវិញសំរាប់ព្រះរាជ្យអស់កល្បរបស់ព្រះជាម្ចាស់ ។ ហើយដើម្បីធ្វើដូច្នេះបាន យើងត្រូវប្រុងប្រៀបខ្លួនជាស្រេច ដើម្បីទទួលពេលវេលាដែល "រូបកាយដ៏ពុករលួយនេះ បានប្រដាប់ដោយសេចក្តីមិនពុក

វល្លួយវិញ ហើយរូបកាយដែលតែងតែស្លាប់នេះ បានប្រដាប់ដោយសេចក្ដីដែលមិនចេះស្លាប់វិញ[១៤] ។

ព្រះគ្រីស្ដយាងមកសំរាប់អ្នកបំរើដែលប្រុងប្រៀបខ្លួនរង់ចាំការយាងមកយ៉ាងឆាប់របស់ព្រះអង្គ ។ អ្នកបំរើដែលចង់បានផ្ទះដ៏សុខសាន្តអស់កល្បជានិច្ច អ្នកបំរើដែលអត់ធ្មត់ចំពោះការលំបាកជាជាងការត្រេកត្រអាលជាមួយអំពើបាប អ្នកបំរើដែលទទួល និងស្វាគមន៍សេចក្ដីសន្យាដ៏អស់កល្បជានិច្ចមកពីនាយ និងអ្នកបំរើដែលប្រើអស់ទាំងកម្លាំងរបស់ខ្លួន ដើម្បីមិនឲ្យកើតមានសេចក្ដីសៅហ្មងណាមួយឡើយ ។

ហេតុផលជាងនោះទៅទៀត ការប្ដេជ្ញាពិនិត្យមើលចិត្តរបស់យើង រក្សាគំនិតរបស់យើងចេញពីការបង្រៀនមិនត្រឹមត្រូវ ហើយប្រុងប្រៀបជាស្រេចសំរាប់ការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ដ ។ ការប្ដេជ្ញាទាំងអស់នេះ គឺហ៊ុំព័ទ្ធដោយព្រះគុណារបស់ព្រះជាម្ចាស់ដែលនឹងផ្ដល់ឲ្យយើងចូលទៅក្នុងព្រះរាជ្យដ៏អស់កល្បរបស់ព្រះអង្គដោយអំណារ ។ ដោយមានទស្សនៈបែបនេះ ពេលយើងមានបញ្ហាត្រូវអោយតំម្លៃបញ្ហានោះ ទុក្ខលំបាកដ៏ខ្លីអាចឲ្យទ្រាំទ្របាន ការលំបាកទាំងឡាយផ្ដល់ឲ្យយើងមានឱកាសនឹងសរសើរព្រះជាម្ចាស់ទៅវិញ ។ អំឡុងពេលយើងធ្វើដំណើរនៅលើផែនដីនេះ សូមឲ្យសេចក្ដីសន្យានៃការស្មោះត្រង់របស់អ្នកបំរើក្នុង China ring បានពិតនៅក្នុងចិត្តរបស់យើង គឺគ្មានការសោកស្ដាយ គ្មានវិប្បដិសារី និងគ្មានការរាថយ ។ សូមឲ្យការនេះក្លាយជាភ្លេងជាតិរបស់យើង នៅពេលដែលយើងរស់នៅក្នុងជីវិតដែលប្រកបដោយការចាំយាមសំរាប់សិរីល្អរបស់ព្រះជាម្ចាស់ជានិច្ច ។

---

[14] ១ កូរិន. ១៥:៥៣



*លោក អ៊ួន សិលា*

# ជួបជាមួយលោកគ្រូ ង៉ូវ វ៉ន



*លោកគ្រូ ង៉ូវ វ៉ន*

លោកគ្រូ ង៉ូវ វ៉ន កើតនៅឆ្នាំ ១៩២៨ ក្នុងគ្រួសារកសិករមួយ ជាគ្រីស្ទបរិស័ទនៅក្នុងភូមិក្លាមហា ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ នៅពេលដែលគាត់អាយុ ១៧ឆ្នាំ គាត់បានថ្វាយខ្លួនទទួលជឿព្រះយេស៊ូ។

នៅឆ្នាំ ១៩៥០ គាត់បានចូលទៅរៀនក្នុងសាលាព្រះគម្ពីរ នៅតាខ្មៅ ខេត្តកណ្ដាល អស់រយៈពេល ៤ឆ្នាំ ។ ក្រោយពេលចេញពីសាលាព្រះគម្ពីរ គាត់បានធ្វើការជាគ្រូផ្សាយដំណឹងល្អជាមួយអង្គការ C&MA ។

គាត់បានរៀបការក្នុងឆ្នាំ ១៩៥២ ជាមួយស្ត្រីគ្រីស្ទបរិស័ទម្នាក់ ឈ្មោះ ជឿន គីមណុន ។ គាត់មានកូនទាំងអស់៩នាក់ កាលពីនៅសម័យ ប៉ុល ពត ពួកវាបានសម្លាប់កូនគាត់ ១នាក់ រួមទាំងកូនប្រសាប្រុស និងចៅទៀតផង។ សព្វថ្ងៃនៅរស់ចំនួន ៨នាក់ មានកូនប្រុស ៣នាក់ និងកូនស្រី ៥នាក់ ។ កូន

របស់គាត់ទាំងអស់សុទ្ធសឹងជាអ្នកជឿព្រះយេស៊ូ ។ ភរិយារបស់គាត់ (ជៀន គីមណុន) បានធ្វើមរណៈកាល ក្នុងឆ្នាំ ១៩៨៣ ។ លុះដល់ឆ្នាំ ១៩៨៦ គាត់បានរៀបការជាមួយស្ត្រីគ្រីស្ទបរិស័ទម្នាក់ទៀតឈ្មោះ លី គីមនី ជាស្ត្រីមេម៉ាយដោយប្តី និងកូន ត្រូវពួកប៉ុលពតសម្លាប់អស់ ។

គាត់ទាំងពីរនាក់ប្តីប្រពន្ធ បានពួតដៃគ្នាផ្តើមបំរើព័ន្ធកិច្ចថ្វាយព្រះជាម្ចាស់នៅក្នុងខេត្តកំពង់ធំ ចាប់តាំងពីឆ្នាំ ១៩៩០ រហូតមកដល់សព្វថ្ងៃ ។

កាលពីជំនាន់ដែលគាត់ជឿព្រះអង្គ មានការបៀតបៀនយ៉ាងខ្លាំងពីសំណាក់អ្នកមិនជឿ តែគាត់មុឹងម៉ាត់ប្រកាន់ជំនឿយ៉ាងមុតមាំ មិនចុះចាញ់ចំពោះការមើលងាយមើលថោករបស់ពួកអ្នកផងទាំងនោះទេ ។ លោកគ្រូ ង៉ូវ វ៉ន ជាអ្នកជឿព្រះយេស៊ូនៅសម័យមុនស្រុកខ្មែរធ្លាក់ចូលក្នុងភ្លើងសង្គ្រាម និងក្នុងកណ្តាប់ដៃពួកខ្មែរក្រហម ។ ព្រះជាម្ចាស់បានទុកឲ្យគាត់មានជីវិតរស់នៅ ដើម្បីធ្វើបន្ទាល់ប្រាប់ដល់យើងគ្រប់គ្នាអំពីព្រះគុណដ៏វិសេសអស្ចារ្យនៃព្រះជាម្ចាស់របស់យើង ។

បន្ទាប់ពីរបបខ្មែរក្រហមរលំដួល លោកគ្រូ ង៉ូវ វ៉ន បានរៀបចំការថ្វាយបង្គំជារបៀបឯករាជ្យ គ្មាននិកាយជួយគាំទ្រឡើយ គឺមានតែមិត្តភក្តិចាស់ៗរបស់គាត់នៅឯបរទេសបានផ្តល់លុយកាក់តិចតួច ។ គាត់បានសន្សំទិញដីមួយកន្លែងដើម្បីសាងសង់ព្រះវិហារនៅក្នុងឆ្នាំ ១៩៩៨ ។ រហូតមកដល់ឆ្នាំ ១៩៩៩ ទើបគាត់សំរេចចិត្តចូលរួមជាមួយនិកាយបាប់ទីស្ទ ។ សព្វថ្ងៃព្រះវិហារគាត់មានឈ្មោះថា "ព្រះវិហារ បាប់ទីស្ទ១-កំពង់ធំក្រុង" ។

នៅពេលដែលខ្ញុំសួរគាត់ថា ហេតុអ្វីបានជាលោកគ្រូសំរេចចិត្តទទួលជឿព្រះយេស៊ូ? ព្រោះអ្នកស្រុកអ្នកភូមិនៅជុំវិញគេមិនជឿដូចលោកគ្រូផង ។ គាត់ឆ្លើយថា ដោយសារឪពុករបស់គាត់ជាអ្នកជឿលើព្រះយេស៊ូ ហើយដោយខ្លាចឪពុកគាត់ផង គាត់ចេះតែជឿបំពេញចិត្តឪពុក ។ ដំបូងគាត់មិនបានយល់ដឹងអ្វីទាំងអស់អំពីរឿងជំនឿរបស់គ្រីស្ទបរិស័ទ ។ ប៉ុន្តែ ក្រោយពីគាត់

បានចូលរៀននៅសាលាព្រះគម្ពីរ ទើបគាត់បានយល់ច្បាស់អំពីជំនឿរបស់គ្រីស្តបរិស័ទ ជាពិសេសជាងនេះទៅទៀត ក្រោយពីបានរស់នៅឆ្លងកាត់យុគសម័យដ៏ខ្មៅងងឹតនៃរបបខ្មែរក្រហម ទើបគាត់បានឃើញពីព្រះគុណដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ដែលព្រះអង្គថែរក្សាគាត់ បានធ្វើឲ្យគាត់ស្គាល់ព្រះអង្គរិតតែច្បាស់ថែមទៀត ។

កាលគាត់ទើបនឹងជឿព្រះដំបូង គាត់តែងនិយាយនឹងឪពុករបស់គាត់ថា ហេតុអ្វីទៅជឿព្រះយេស៊ូទៅវិញ មនុស្សមួយស្រុកគេជឿលើព្រះពុទ្ធ ចុះម្តេចបានជាយើងមកជឿព្រះយេស៊ូតែឯងទៅវិញ? ។ គាត់ហ៊ានសួរឪពុកដូច្នេះ ព្រោះគាត់អាងថា ជីតាគាត់កាន់ខាងគាត់ ។ លោកគ្រូ វ៉ន បានបង្ហើបឲ្យដឹងទៀតថា កាលពីនៅក្មេងគាត់ខ្មាសគេណាស់ ព្រោះគ្រួសាររបស់គាត់ជឿព្រះយេស៊ូ ។

កាលពីសម័យដែលគាត់ជឿព្រះយេស៊ូ មុនសម័យខ្មែរក្រហម មានគ្រីស្តបរិស័ទប្រហែលជា ១៥នាក់ ប៉ុណ្ណោះ នៅទូទាំងខេត្តកំពង់ធំទាំងមូល។ នៅពេលខ្មែរក្រហមមកដល់ គេបានចាប់គាត់ទៅដាក់គុកអស់ ២២ថ្ងៃ ដោយគេចោទគាត់ថាជា CIA (សេអ៊ីអា) របស់អាមេរិក ។ ហេតុផល ព្រោះកាលពីសម័យមុនពេលខ្មែរក្រហមមកដល់ បេសកជនរបស់អង្គការ C&MA លោក ហា ម៉ុង និង លោក ភីធើរ៍ សិន និងគ្រូខ្មែរមួយចំនួនទៀតដែលធ្លាប់ចុះទៅផ្សាយដំណឹងល្អដល់ខេត្ត កំពង់ធំ បានជួបជាមួយនឹងគាត់ ទើបមានការចោទប្រកាន់បែបនោះ ។ ព្រះជាម្ចាស់បានដោះគាត់ឲ្យរួចពីកណ្តាប់ដៃខ្មែរក្រហម ហើយពួកគេបានជន្លៀសគាត់ និងគ្រួសារចេញពីភូមិកំណើតទៅរស់នៅក្នុងភូមិល្បើក ដែលមានចម្ងាយប្រមាណជាង ៨០ គីឡូម៉ែត្រ ។ គាត់មានការងារជាកងភ្ជួរស្រែ ។ សម័យនោះ ខ្មែរក្រហមព្យាយាមចង់សម្លាប់គាត់ពីរដង ប៉ុន្តែព្រះជាម្ចាស់បានដោះគាត់ឲ្យរួចពីកណ្តាប់ដៃខ្មែរក្រហមទាំងពីរដង ។ នៅពេលខ្មែរក្រហមសួរគាត់ថា តើគាត់ជាសេអ៊ីអា

(CIA) របស់អាមេរិកមែនឬ? គាត់និយាយជាមួយនឹងពួកវាថា *"ខ្ញុំជាអ្នកជឿលើព្រះយេស៊ូ ហើយពួកអាមេរិកនោះ ក៏ជាអ្នកជឿលើព្រះយេស៊ូដែរ ពួកនោះគេជឿព្រះយេស៊ូមុនខ្ញុំ គេមកផ្សាយដំណឹងពីព្រះយេស៊ូដើម្បីឲ្យខ្ញុំជឿដូចគេដែរ ខ្ញុំជឿព្រះ ខ្ញុំមិនមែនជឿលើអាមេរិកកាំងទេឡើយ"*។ ពេលនោះពួកខ្មែរក្រហមនៅស្ងៀម គេមិននិយាយអ្វីទាំងអស់ គាត់ជឿថា មិនមែនគាត់ពូកែនិយាយឲ្យខ្មែរក្រហមស្តាប់នោះឡើយ ប៉ុន្តែនេះគឺព្រះចេស្តារបស់ព្រះជាម្ចាស់ទៅវិញទេ ដែលធ្វើឲ្យខ្មែរក្រហមចិត្តទន់មិនសម្លាប់គាត់ ។

នៅក្នុងឆ្នាំ ១៩៨០ គាត់បានមកដល់ភូមិកំណើតវិញ ពេលនោះគ្មានសល់ពួកអ្នកជឿម្នាក់សោះ ។ នៅក្នុងខេត្តកំពង់ធំ មានតែគ្រួសារគាត់តែប៉ុណ្ណោះដែលជាអ្នកជឿព្រះយេស៊ូ ហើយនៅសល់ពីស្លាប់ក្នុងរបប ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ របស់ពួកខ្មែរក្រហម ។ នៅពេលដែលគាត់មកដល់ភូមិកំណើត គាត់បានជិះកង់ស្វះស្វែងរកគ្រីស្តបរិស័ទក្នុងទូទាំងខេត្ត កំពង់ធំ និងរហូតទៅដល់ខេត្ត សៀមរាប ទើបបានជួបគ្រីស្តបរិស័ទមួយចំនួនតូចនៅសល់ក្នុងខេត្ត សៀមរាប នោះ ។

លុះដល់ឆ្នាំ ១៩៨០ និង ១៩៨៨ ទើបគាត់ចាប់ផ្តើមប្រមូលគ្នាប្រជុំថ្វាយបង្គំនៅក្នុងផ្ទះរបស់គាត់ ហើយគាត់បានទៅភ្នំពេញជួបទាក់ទងគ្រីស្តបរិស័ទមួយចំនួននៅទីនោះ ដើម្បីរកព្រះគម្ពីរបានខ្លះពី លោកស្រី អាល្លីស កំប៉ុង ។ គាត់បានជិះកង់ទៅជួបបងប្អូនគ្រីស្តបរិស័ទនៅ ខេត្ត កំពង់ចាម ខ្លះទៀត ។ គ្រប់ព័ន្ធកិច្ចបំរើថ្វាយព្រះជាម្ចាស់តាំងពីមុនមក រហូតដល់សព្វថ្ងៃ លោកគ្រូមិនបានទទួលប្រាក់ខែទេ ជីវិតជាកសិករ ធ្វើស្រែបណ្តើរ ផ្សាយដំណឹងល្អបណ្តើរ ប្រពន្ធរបស់គាត់នៅផ្ទះលក់ដូរបន្តិចបន្តួច ។

ខ្ញុំបានបន្តសួរគាត់ថា *"បើប្រៀបសន្ទុះនៃការរីកចំរើនលូតលាស់របស់ក្រុមជំនុំមុនស្រុកទេសស្រុតធ្លាក់ចុះ មកជាមួយក្រុមជំនុំសម័យបច្ចុប្បន្ន តើក្រុមជំនុំសម័យណាលូតលាស់ជាងគេ?"* ក្រុមជំនុំសព្វថ្ងៃលូតលាស់លឿន

ណាស់ នៅគ្រប់ទីកន្លែងមានក្រុមជំនុំកើតឡើងផុលផុសដុះដូចផ្សិត សូម្បី ទីជនបទដាច់ស្រយាល ក៏មានក្រុមជំនុំដែរ ។ តើមកពីហេតុអ្វី? ឆ្លើយតបនឹង សំនួរនេះ លោកគ្រូបាននិយាយថា ព្រោះការផ្សាយដំណឹងល្អសព្វថ្ងៃមាន លក្ខណៈគ្រប់ជ្រុងជ្រោយ និងមានសន្ទុះខ្លាំងក្លាណាស់ ។

ទី១ នៅសម័យស្រុកទេសស្រុតធ្លាក់ចុះ មនុស្សរត់បែកខ្ញែកគ្នា អ្នក ខ្លះបានរត់ទៅរស់នៅប្រទេសទីពីរ អ្នកខ្លះទៀតក៏រត់ឆ្លងទៅរហូតដល់ ប្រទេសទីបី ឯខ្លះទៀតក៏ទទួលរងមរណៈភាពទៅ ។ អ្នកទាំងនោះបានជឿ ព្រះយេស៊ូ បន្ទាប់ពីស្រុកទេសបានសុខសាន្ត ពួកគេបានវិលត្រឡប់មករស់ នៅភូមិកំណើត ឬចូលមកលេងស្រុកទេសវិញ ក៏បានប្រកាសផ្សាយដំណឹង ល្អដល់ញាតិមិត្តបងប្អូនរបស់គេ អំពីព្រះគុណដ៏អស្ចារ្យដែលព្រះជាម្ចាស់ បានជួយសង្គ្រោះអាយុជីវិតគេ ស្របពេលនោះដែរ ពួកគេបានចែករំលែក និងផ្តល់នូវអ្វីដែលគេមាន ឲ្យដល់ញាតិមិត្តបងប្អូនដែលកំពុងខ្វះខាត ធ្វើឲ្យ ដំណឹងល្អរឹតតែមានឥទ្ធិពលធំធេងឡើង នេះជាលក្ខណៈមួយដែលហ៊ាន និយាយថាជា *"ដំណឹងល្អគ្រប់ជ្រុងជ្រោយ"* ។

ទី២ មនុស្សសព្វថ្ងៃនេះ ក៏មានការស្រេកឃ្លានព្រះបន្ទូលជាងមុន សម័យស្រុកទេសធ្លាក់ចុះដែរ ។ ការផ្សាយដំណឹងល្អពីមុន គឺច្រើនតែពួក បរទេសមកផ្សាយ ដល់ពេលមានអ្នកជឿ គេថាពួកនេះជឿព្រះបារាំង ។ ក្រោយពីសង្គ្រាមមក ដំណឹងល្អមានទម្ងន់ខ្លាំងមែនទែន ខ្ញុំជឿថា បើព្រះជា ម្ចាស់មិនប្តូរផែនការរបស់ព្រះអង្គឲ្យរាស្ត្រខ្មែររងទុក្ខលំបាកដោយឆ្លងកាត់ សង្គ្រាមនោះទេ ប្រហែលជាដំណឹងល្អនៅតែយឺត មិនលឿនដូចសព្វថ្ងៃនេះ ទេ ។ គ្រូគង្វាលដែលនៅសេសសល់ក្រោយពីសង្គ្រាម និងពីរបប ប៉ុល ពត មានតែពីរនាក់គត់ គឺ លោកគ្រូ ង៉ូវ វ៉ន និង លោកគ្រូ សៀង អង់ ។ កាលពី ជំនាន់ ប៉ុល ពត លោកគ្រូ សៀង អង់ បានភៀសខ្លួនទៅនៅប្រទេស វៀតណាម គាត់មិនបានរស់នៅជាមួយខ្មែរក្រហមដូចលោកគ្រូ ង៉ូវ វ៉ន ទេ។

ខ្ញុំបានសួរគាត់ថា តើគាត់មានការតូចចិត្តដែរឬទេ ដែលព្រះជាម្ចាស់បណ្តោយឲ្យប្រទេសរបស់យើងធ្លាក់ក្នុងភ្លើងសង្គ្រាមនោះ? គាត់បែរជាអរព្រះគុណព្រះជាម្ចាស់ទៅវិញ ដោយគាត់និយាយថា បើព្រះជាម្ចាស់មិនបណ្តោយឲ្យខ្មែររងទុក្ខទេ ក៏ខ្មែរនៅតែមិនប្រែចិត្តលឿនដូចសព្វថ្ងៃនេះដែរ គាត់រាប់ការរងទុក្ខនោះ ជាព្រះពរទៅវិញទេ ។

ចំពោះបេសកជនសព្វថ្ងៃ ប្រៀបទៅនឹងបេសកជនជំនាន់មុនសង្គ្រាម តើមានលក្ខណៈខុសប្លែកគ្នាយ៉ាងណា? លោកគ្រូ ង៉ូវ វ៉ន បានឆ្លើយថា កាលសម័យនោះ បេសកជនមួយចំនួនដែលមកធ្វើការនៅស្រុកខ្មែរយើងមានចិត្តចង្អៀតចង្អល់ មិនមានចិត្តទូលាយដូចបណ្តាបេសកជនសព្វថ្ងៃនេះឡើយ ។ បេសកជនជំនាន់នោះមិនចុះដល់ជនបទទេ គេចូលចិត្តរស់នៅតែក្នុងទីក្រុងធំ ។ ឧទាហរណ៍ជាក់ស្តែង កាលពីឆ្នាំ ១៩៦៥ ដល់ឆ្នាំ ១៩៦៦ មានបេសកជនមួយគ្រួសារគត់ គឺលោក ថោម ស៊ិន និងភរិយាបានរួមដំណើរជាមួយខ្ញុំ (លោកគ្រូ ង៉ូវ វ៉ន) ទៅប្រកាសផ្សាយដំណឹងល្អទូទាំងភូមិភាគឦសាន្តនៃប្រទេសកម្ពុជាយើង ។ គំរូមិនល្អរបស់បេសកជនមួយចំនួន គឺគាត់បញ្ជាក់ថា សេចក្តីស្រឡាញ់មានតែនៅក្នុងព្រះគម្ពីរ ដែលជាមូលហេតុធ្វើឲ្យបេសកកម្មផ្សាយដំណឹងល្អមានភាពយឺតយ៉ាវ និងមិនទូលំទូលាយ ។

យើងខ្ញុំសូមអរព្រះគុណព្រះអម្ចាស់ ដែលបានចាត់បេសកជនគំរូល្អៗមកបំពេញការងារថ្វាយទ្រង់ក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ អស់លោកទាំងនោះបានបង្ហាញនូវការរាប់អានចំពោះយើងទុកដូចជាបងជាប្អូន ផ្សារភ្ជាប់មនោសញ្ចេតនារស់រវើកជាមួយគ្រីស្តបរិស័ទនៅតាមជនបទឆ្ងាយៗ... នេះជាសេចក្តីស្រឡាញ់ពិត ដូចព្រះបន្ទូលនៃព្រះអម្ចាស់ដែលបញ្ជាឲ្យ លោក សាវ័ក ប៉ូល ចារទុកក្នុងគម្ពីរ កូរិនថូសទី១: ជំពូក១៣ បានបញ្ជាក់ពីការមិនរើសអើង មិនបែងចែកវណ្ណៈ មិនប្រកាន់ពូជសាសន៍ ដូចមានចែងក្នុងព្រះគម្ពីរ ហើយអស់លោកទាំងនោះភាគច្រើនបានសម្តែងនូវគំរូល្អដល់បងប្អូនយើង

ដូចជាអ្វីដែលពួកគេបានបង្រៀន ព្រមទាំងឆ្លុះបញ្ចាំងពីឥទ្ធិពល និងព្រះចេស្ដានៃព្រះបន្ទូលដែលបានចែងក្នុងព្រះគម្ពីរប៊ីប ។ ហេតុដូច្នេះហើយ ទើបដំណឹងល្អរបស់បេសកជនសម័យនេះមានទម្ងន់ និងស៊ីជម្រៅ (គ្រប់ជ្រុងជ្រោយ) ។ ការរីកចំរើនរបស់ក្រុមជំនុំសម័យនេះ ក៏ជាផ្នែកមួយដែលបេសកជនបានរួមចំណែកផងដែរ ។

ពេលដែលខ្ញុំសួរគាត់ថា ក្នុងចំណោមព័ន្ធកិច្ចបំរើព្រះអង្គទាំងអស់ តើព័ន្ធកិច្ចមួយណា ដែលគាត់គិតថាអាចជួយស្ដារប្រទេសជាតិយើងបាន? គាត់ឆ្លើយថា គឺព័ន្ធកិច្ចយុវជន និងកុមារ ។ ព្រោះបើពង្រឹងព័ន្ធកិច្ចនេះបានល្អ គឺមានយុវជនកោតខ្លាចដល់ព្រះជាម្ចាស់បានច្រើន ហើយពេលមានយុវជនកោតខ្លាចព្រះ គឺនាំឲ្យមានអ្នកដឹកនាំល្អ និងអាចមានអ្នកដឹកនាំគ្រីស្ទបរិស័ទនៅក្នុងស្រទាប់អ្នកដឹកនាំប្រទេស ។ នៅពេលនោះប្រទេសយើងនឹងបានរីកចំរើនដោយទទួលព្រះពរពីព្រះជាម្ចាស់ ។ សំណូមពររបស់គាត់ គឺសូមអំពាវនាវដល់បេសកជន អង្គការផ្សេងៗ ឲ្យជួយផ្ដោតសំខាន់ក្នុងព័ន្ធកិច្ចកុមារ និងយុវជន ។ ព្រោះប្រទេសខ្មែរក្រោយពីសង្គ្រាមមកមនុស្សស្លាប់ច្រើន ហើយចំនួនប្រជារាស្ដ្រដែលមានសព្វថ្ងៃនេះ គឺភាគច្រើនជាយុវជន ។ ហេតុផលដែលធ្វើឲ្យគាត់អាចឈរមាំមួនបានក្នុងជំនឿ គឺដោយព្រោះគាត់ជឿព្រះយេស៊ូតាំងពីកាលដែលគាត់នៅជាយុវជន ។ ទោះបីជាគាត់បានរស់នៅឆ្លងកាត់ការរងទុក្ខលំបាកវេទនា ការធ្វើទុក្ខបុកម្នេញយ៉ាងណាក៏ដោយ ក៏គាត់អាចឈរនៅរឹងមាំបានដែរ ព្រោះព្រះបន្ទូលចាក់ឫសយ៉ាងជ្រៅនៅក្នុងចិត្តរបស់គាត់ ។

គាត់បានសម្ដែងនូវការពេញចិត្ត និងអរគុណដល់ព្រះជាម្ចាស់ដែលបានចាត់អង្គការទស្សនៈពិភពលោក ឲ្យចុះមកជួយនៅក្នុង ខេត្តកំពង់ធំ នេះ គឺអង្គការបានបង្កលក្ខណៈរៀងរាល់ខែឲ្យមានការប្រកបគ្រូគង្វាល ផ្ដល់ការហ្វឹកហ្វឺនដល់គ្រូគង្វាល និងមានគម្រោងកម្មវិធីហ្វឹកហ្វឺន ធីម៉ូថេ បានចុះមកបង្រៀនរួមជាមួយបេសកជនដទៃទៀត ។ សូមព្រះប្រទានពរ!

HONEYCOMB 3/3 (October 2002): 135–139



*UON Seila*

# Meet Ngov Vorn



*NGOV Vorn*

Pastor Ngov Vorn was born in 1928. He was raised by a Christian farmer who lived in Kdam Ha village, Chhouk Kasarch subdistrict, Baray district, Kompong Thom province. He has one younger sister. Ngov Vorn gave his life to Jesus when he was 17 years old.

In 1950 he took up studies at the Takmau Bible School in Kandal province. After graduating he worked as an evangelist with Christian and Missionary Alliance.

In 1952 he married a Christian woman, Choeun Kim Nonn. Nine children were born into this family. They lost one daughter, along with her husband and their children, in the Pol Pot time. But eight children—three sons and five daughters—survived. All are Christians. After his wife Kim Nonn passed away in 1983, he married a Christian widow, Ly Kim Ny, whose husband had died in Pol Pot regime. Together they have served the Lord in Kompong Thom since 1990.

There was intense persecution around the time he believed in Jesus, but he is strong in persevering in his faith regardless of whether people look down on him. Pastor Ngov Vorn retained his faith throughout the Khmer Rouge years. God spared his life to testify to us about his amazing grace.

After the Khmer Rouge regime fell, Pastor Vorn set up an independent worship place. No denomination supported the work, but friends from overseas provided some money. He saved it, bought a plot of land, and built a church building in 1998. He named the church "First Baptist Church of Kompong Thom Town." In 1999 he joined with the Baptists.

When asked why he believed in Jesus when his community did not, he answered that he originally did so to please his believing father. At first he knew very little about Christianity, but during Bible school he learned a great deal. In addition, surviving the terror of Khmer Rouge regime taught him even more clearly about the amazing grace of God, who took care of him and drew him closer.

When he first came to faith he frequently asked his father, "Why do we believe in Jesus while everyone else believes in Buddha?" He dared to ask such a question because he was somewhat of a favorite of his grandfather, and he knew that his grandfather would take his side. In recalling this question, Pastor Vorn is dropping a hint to us that in his younger years he was embarrassed because of his family's faith.

Before the Khmer Rouge era there were only fifteen Christians in the whole of Kompong Thom province. After the fall of Phnom Penh, he was arrested and jailed for twenty-two days because they accused him of being an American CIA informer. The reason for this is that before the war, missionaries from Christian and Missionary Alliance—Hamong and Peterson and some Khmer evangelists—used to come to Kompong Thom to hold evangelistic rallies, and they would come to see him. But God delivered him from the hand of Khmer Rouge, and he was evacuated about forty kilometers from his home village to La Boeuk. There he was designated to work in the plowing corps.

The Khmer Rouge twice tried to kill him, and they demanded, "Are you an American CIA agent?" He answered, "I believe in Jesus, as do the Americans. They believed before I did, and came to tell me

about him. But I do not believe in Americans." Then Khmer Rouge stayed mum. He was not sure what would happen next, because he felt he had spoken eloquently to the Khmer Rouge. But the power of God eased the hearts of the Khmer Rouge soldiers so that they did not kill him.

In 1980 when he returned to his home village, he found that no other Christians had survived. He and his family were the only Kompong Thom Christians that made it through the dark age of three years, eight months, and twenty days. He bicycled throughout Kompong Thom and Siem Reap to search for any remnant Christians, and eventually met a handful in Siem Reap.

Between 1980 and 1988 he worshiped God in his own house, but then went to Phnom Penh to contact other Christians. While there he got some Bibles from Alice Compain. He also cycled to Kompong Cham and met with some Christians in that place. For all these ministries he never received any salary. He was a farmer—and his wife sold things in her small business—all the time he was serving the Lord.

I asked him, "If we compare church growth before the country fell into Khmer Rouge hands with the present rate, in which era did the church grow more rapidly? At present the church is growing rapidly everywhere, emerging like a mushroom even in remote areas. Why?" He answered, because evangelism today is holistic and there is a stronger drive toward evangelism.

When the country was first at war, people scattered everywhere. Some moved to a second country, and of these a portion then went to a third. Still others died. Those who moved to a third country came to believe in Jesus. After peace returned to Cambodia they repatriated, or came to visit their relatives. When they did, they shared with their relatives the good news about God's amazing grace in saving their lives. Because it was now relatives who were sharing and not just foreigners, because many of these relatives had dramatic testimonies of God's deliverance during their escapes, and because these relatives had freely chosen to become Christians in the more affluent West, and not as a ploy to get rice, the gospel had a much greater impact.

Second, people thirst for the Word of God nowadays more than they did before the fall of the country. Previously most evangelists were

only foreigners; therefore when people believed they were labeled as believing in the French God. After the war the gospel had more impact. I believe if God did not let the Cambodian people go through the agony of the civil war, maybe the gospel would not advance as fast as it is doing today. There are two pastors today who survived the war and the Pol Pot regime—Pastor Gnov Vorn and Pastor Seang Aung. Seang Aung escaped to Vietnam during the Pol Pot time, while Gnov Vorn stayed here in Cambodia.

I asked him if he felt sorry that God let Cambodia go through such a war? He said praise the Lord, if God did not allow the Khmer people to go through that suffering, there would not be the rapid spread of repentance and faith that we see today. From this perspective he sees the suffering during the civil war as a blessing from God.

What is the difference between missionaries today when compared with those of the past? Pastor Gnov Vorn answered that in the past missionaries who came to work in Cambodia were narrow-minded, not like those of today. They did not want to go to the countryside. They liked to live in towns and cities. For example in 1965–66 there was only one missionary family, Thompson and his wife, who accompanied Pastor Gnov Vorn to the northeast to share the gospel. Another bad example was a handful of missionaries who preached about love from their Bibles, but did not practice love in their lives. So progress in sharing the good news was slow and not widespread.

We are so grateful to God that he has sent good missionaries to do his work in Cambodia today. They are very friendly to us, and show brotherly love to us and to other Christians in remote areas. This is the real love that God commands in his word—and about which Paul wrote in 1 Corinthians 13—that we should love without discrimination or regard to social status. Most missionaries in the present day set good examples for us, and what they have taught reflects the power of God and His word in the Bible. Therefore the gospel that the missionaries share today has more weight and is more holistic. Present church growth is in part the fruit of the missionaries' labor

When asked which ministry can most help restore Cambodian society, he replied youth and children's ministry. If that ministry is well developed, youth will fear God. If they fear God they will become good

leaders, and if we have good Christian government leaders, our country will prosper and be blessed. Pastor Gnov Vorn requests that missionaries from various organizations focus mainly on children's and youth ministry. In the war Cambodia lost a lot of people, and the present population is very young. The reason that he has been able to stand firm in faith so long is because he believed in Jesus when he was young. Even though he went through suffering and persecution, he can stand firm in faith because the word of God was rooted deep in his heart.

He is very grateful that God sent World Vision to Kompong Thom. World Vision initiated a monthly pastors' fellowship. Training of Timothys has helped with pastors' training. May God bless those who came to help us!